សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការអនុវត្តទោស និងការព្យួរទោស

ស្រាវជ្រាវចាប់ពីថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២១ ដល់ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២១

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ : **ទីវ ស៊ាវម៉ី**
**ហាក់ សុវណ្ណរ៉ូហ្សា**

សាស្ត្រាចារ្យណែនាំ
លោក **ជួន ម៉ុនធី**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ២១

ឆ្នាំចូលសិក្សា ២០១៧
ឆ្នាំសរសេរសារណា ២០២១

# **សេចក្តីថ្លែងអំណរគុណ**

យើងខ្ញុំឈ្មោះ **ទីវ ស៊ាវម៉ី** និងឈ្មោះ **ហាក់ សុវណ្ណរ៉ូហ្សា** ជានិស្សិតឆ្នាំទី៤ ជំនាន់ទី២១ ថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។

**សូមថ្លែងអំណរគុណ និងសំដែងនូវកតញ្ញូតាធម៌ចំពោះ ៖**

លោកឪពុក **សែម វុទ្ធី** លោកឪពុក **ស៊ុយ ឈុនហាក់**

អ្នកម្តាយ **តុន សុគន្ធា** អ្នកម្តាយ **សេង សុវណ្ណារី**

ជាកិច្ចបឋមកូនៗសូមលំឱនកាយក្រាបប្រណិប័តន៍ និងសម្តែងនូវកត្តញ្ញូតាធម៌ និងកតវេទីយ៉ាងខ្ពង់ខ្ពស់ចំពោះមាតាបិតា និងរបស់កូនៗដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា និងទូន្មានប្រៀនប្រដៅប្រកបដោយព្រហ្មវិហារធម៌ ព្រមទាំងបានលើកទឹកចិត្តផ្នែកស្មារតី និងគាំទ្រផ្នែកធនធាន ដែលជាហេតុធ្វើឲ្យនាងខ្ញុំទាំងពីរ បានបន្តការសិក្សាគ្រប់ភូមិសិក្សារហូតមកដល់ឆ្នាំទី៤ នៃថ្នាក់បរិញ្ញាបត្រនេះដោយជោគជ័យ។ កូនៗសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ចំពោះគុណនូបការៈយ៉ាងធំធេងបំផុតរបស់លោកអ្នកទាំងពីរ។ គុណនូបការៈរបស់លោកទាំងពីរ គឺពិតជាធំធេងណាស់ដែលធ្វើឲ្យកូនៗបំភ្លេចមិនបាន នឹងស្ថិតក្នុងចិត្តរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យឡើយ។

សូមគោរពថ្លែងអំណរគុណផងដែរចំពោះ **ឯកឧត្តមសាកលវិទ្យាធិការ** សាកលវិទ្យាធិការរងព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ គណៈគ្រប់គ្រងសាលា ព្រមទាំងមន្រ្តីគ្រប់ផ្នែកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានខិតខំក្នុងការដឹកនាំគ្រប់គ្រង បង្ហាត់បង្រៀន និងសម្របសម្រួលដល់យើងខ្ញុំឲ្យទទួលបាននូវចំណេះដឹង បទពិសោធន៍យ៉ាងច្រើនអនេក ទាំងក្នុងវិស័យនីតិសាស្រ្ត និងវិស័យយុត្តិធម៌ ជាពិសេសទទួលបាននូវការតម្រង់ទិសចំណេះដឹងអំពីស្ថានភាពជាក់ស្តែងក្នុងសង្គមនាពេលបច្ចុប្បន្ន ដែលបានធ្វើឲ្យយើងខ្ញុំក្លាយជាយុវជន និស្សិត និងពលរដ្ឋល្អនៅក្នុងសង្គម ដើម្បីជាសសរទ្រូងដ៏រឹងមាំមួយនៃសង្គម និងប្រទេសជាតិទាំងមូល។

សូមគោរពថ្លែងអំណរគុណដល់លោកគ្រូ **ជួន ម៉ុនធី** ជាសាស្រ្តាចារ្យណែនាំ ដែលបានបង្ហាត់បង្រៀនយើងខ្ញុំក្នុងការរៀបចំឯកសារសារណាលើប្រធានបទ **ការអនុវត្តទោស និងការព្យួរទោស** ដោយទទួលបាននូវលទ្ធផលប្រកបដោយផ្លែផ្កា ដោយលោកបានចំណាយនូវពេលវេលាដ៏មានតម្លៃ ដើម្បីជួយប្រឹក្សា និងផ្តល់នូវអនុសាសន៍ល្អៗក្នុងការការតាក់តែងស្នាដៃសារណានេះឡើងកាន់តែល្អ និងកាន់តែរលូន។

សូមគោរពថ្លែងអំណរគុណចំពោះលោក **ឃន ម៉េងឡុង** ជាមិត្តនិស្សិតរួមជំនាន់ ដែលបានជួយរៀបចំផ្នែកបច្ចេកទេស និងរចនាបទនានានៅក្នុងសារណាបញ្ចប់ការសិក្សាមួយនេះ ដើម្បីឲ្យកិច្ចការស្រាវជ្រាវនេះកាន់តែល្អ ស្របទៅតាមរចនាសម្ព័ន្ធ និងបទដ្ឋានទម្រង់លក្ខណៈស្តង់ដាដែលសាកលវិទ្យាល័យបានកំណត់។

ជាចុងបញ្ចប់ នាងខ្ញុំទាំងពីររូបសូមប្រសិទ្ធិពរជ័យ បួងសួងដល់វត្ថុស័ក្តសិទ្ធិទាំងអស់ដែលមាននៅក្នុងលោកនេះឲ្យជួយតាមថែរក្សាដល់មាតាបិតា ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលា និងមន្ត្រីបុគ្គលិកគ្រប់ផ្នែកទាំងអស់ឲ្យជួបប្រទះតែពុទ្ធិពរទាំងបួនប្រការពោលគឺៈ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

បន្ទាប់ពីបានធ្វើការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី២១ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំសិក្សា ២០១៧-២០២១ អស់រយៈពេល ៤ឆ្នាំកន្លងមក ដោយការខិតខំសិក្សារៀនសូត្រ និងការផ្ដល់ដំបូន្មានល្អៗ ពីសំណាក់លោក-លោកស្រីសាស្ត្រាចារ្យ នៅក្នុងសាកលវិទ្យាល័យបានធ្វើឲ្យយើងខ្ញុំទាំងពីររូបទទួលបានការអនុញ្ញាតពីសាកលវិទ្យាល័យ ក្នុងការសរសេរណាបញ្ចប់ការសិក្សាក្រោមប្រធានបទ << **ការអនុវត្តទោស និងការព្យួរទោស** >>។

ប្រធានបទមួយនេះ កើតឡើងចេញពីចម្ងល់ និងការចង់ដឹងឲ្យកាន់តែច្បាស់លាស់ហើយស៊ីជម្រៅ ទើបយើងខ្ញុំជ្រើសរើសយកប្រធានបទស្ដីពី **ការអនុវត្តទោស និងការព្យួរទោស** មកធ្វើការបកស្រាយ ដើម្បីស្វែងយល់អំពីគោលការណ៍ និងសារៈសំខាន់របស់ប្រធានបទមួយនេះបន្ថែម។ ពិសេសការសរសេរសារណាបញ្ចប់ការសិក្សានេះត្រូវបានស្ថិតក្រោមការណែនាំពីសំណាក់លោកសាស្ត្រាចារ្យ **ជួន ម៉ុនធី** ដែលលោកសាស្ត្រាចារ្យបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការចែករំលែកនូវចំណេះដឹង បទពិសោធន៍ និងដំបូន្មានល្អៗសម្រាប់ជាពុទ្ធិដល់យើងខ្ញុំ។ ការសិក្សាស្រាវជ្រាវចំពោះប្រធានបទនេះធ្វើឡើងដោយផ្អែកទៅតាមច្បាប់ និងបទប្បញ្ញត្តិដែលចូលជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាមានដូចជាក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងកម្រងឯកសារស្នាដៃ សៀវភៅ បទឧបទ្ទេសរបស់សាស្ត្រាចារ្យ និងអ្នកជំនាញវិស័យច្បាប់នានាផងដែរ។

ក្រោមការចង្អុលបង្ហាញពីសំណាក់លោកសាស្ត្រាចារ្យផ្ទាល់ យើងខ្ញុំទាំងពីរបានខិតខំធ្វើការសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ ក្នុងការចងក្រង រៀបរៀងឡើងនូវកិច្ចការមួយនេះប្រកបដោយស្មារតីខ្ពស់ និងទទួលខុសត្រូវជាទីបំផុត ដើម្បីជាគុណប្រយោជន៍សម្រាប់ប្អូនៗ និស្សិតជំនាន់ក្រោយ ក៏ដូចជាប្រជាពលរដ្ឋទូទៅដែលចង់ស្វែងយល់ពីនីតិវិធីនៃការអនុវត្តទោស និងការព្យួរទោសបានជ្រាបឲ្យកាន់តែច្បាស់ និងអភិវឌ្ឍចំណេះដឹងរបស់ខ្លួនបន្ថែមមួយកម្រិតទៀត។ ចំពោះកិច្ចការស្រាវជ្រាវនេះ គឺជាសមិទ្ធផលមួយដែលយើងខ្ញុំបានព្យាយាមសរសេរទាំងកម្លាំងកាយ និងកម្លាំងចិត្ត ជម្នះរាល់ឧបសគ្គដែលបានកើតមានរហូតបង្កើតបានជាស្នាដៃមួយនេះឡើង។ ក្នុងនោះផងដែរ ប្រាកដជាមានចំណុចខ្វះខាតជាក់ជាពុំខាន អាស្រ័យហេតុនេះ យើងខ្ញុំសូមធ្វើការអភ័យទោសទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ មិត្តអ្នកអាននានាក្នុងករណីដែលកិច្ចការស្រាវជ្រាវនេះមានកំហុសឆ្គងណាមួយទាំងអត្ថន័យ អក្ខរាវិរុទ្ធ ចំណុចលើស ឬខ្វះខាតនូវខ្លឹមសារត្រង់ចំណុចណាមួយដែលកើតឡើងដោយអចេតនាក្នុងស្នាដៃស្រាវជ្រាវមួយនេះ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរពិតជាមានសេចក្ដីសោមនស្សរីករាយ ក្នុងការទទួលយករាល់មតិរិះគន់ ការទិតៀនក្នុងន័យស្ថាបនាពីគ្រប់មជ្ឈដ្ឋាននានា និងការផ្ដល់យោបល់ផ្សេងៗ ដើម្បីកែលម្អរាល់កំហុសឆ្គង ចំណុចខ្វះ

ខាតរបស់អត្ថបទស្រាវជ្រាវមួយនេះឲ្យកាន់តែមានលក្ខណៈល្អប្រសើរថែមមួយកម្រិតទៀត ក៏ដូចជាអភិវឌ្ឍសមត្ថភាពចំណេះដឹងឲ្យបានល្អប្រសើរជាងមុនទ្វេដង។ សូមអរគុណ!

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**ការអនុវត្តទោស**

**១.១. សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ** ........................................ ៤

**១.១.១. អត្ថន័យនៃទោស** ........................................ ៤

១.១.១.១. អត្ថន័យតាមបែបអក្សរសាស្ត្រ ........................................ ៤

១.១.១.២. អត្ថន័យតាមបែបនីតិសាស្ត្រ ........................................ ៤

**១.១.២. ប្រភេទនៃទោសព្រហ្មទណ្ឌ** ........................................ ៥

១.១.២.១. មូលទោស ........................................ ៥

១.១.២.១.១. ទោសដាក់ពន្ធនាគារ ........................................ ៥

១.១.២.១.២. ទោសពិន័យជាប្រាក់ ........................................ ៦

១.១.២.២. ទោសបន្ថែម ........................................ ៦

១.១.២.២.១. ប្រភេទនៃទោសបន្ថែម ........................................ ៧

១.១.២.៣. ទោសជំនួស ........................................ ៨

១.១.២.៣.១. ទោសការងារសហគមន៍ ........................................ ៨

១.១.២.៣.២. ការស្តីបន្ទោស ........................................ ៩

**១.១.៣. គោលបំណងនៃទោស** ........................................ ១០

**១.២. នីតិវិធីនៃការអនុវត្តទោស** ........................................ ១០

**១.២.១. អត្ថន័យនៃការអនុវត្តទោស** ........................................ ១០

**១.២.២. ប្រភេទនៃការអនុវត្តទោស** ........................................ ១១

១.២.២.១. ការអនុវត្តមូលទោស ........................................ ១១

១.២.២.១.១. ការអនុវត្តមូលទោសចំពោះនីតិជន ........................................ ១៣

១.២.២.១.២. ការអនុវត្តទោសទូទៅចំពោះអនីតិជន ........................................ ១៤

១.២.២.១.៣. ការអនុវត្តមូលទោសចំពោះអនីតិជន ........................................ ១៦

១.២.២.២. ការអនុវត្តទោសបន្ថែម ........................................ ១៧

១.២.២.២.១. ការអនុវត្តទោសបន្ថែមចំពោះនីតិជន ........................................ ១៨

១.២.២.២.២. ការអនុវត្តទោសបន្ថែមចំពោះអនីតិជន ........ ១៨
១.២.២.៣. ការអនុវត្តទោសជំនួស ........ ១៩
១.២.២.៣.១. ការអនុវត្តទោសសហគមន៍ចំពោះនីតិជន ........ ១៩
១.២.២.៣.២. ការអនុវត្តការស្ដីបន្ទោសចំពោះនីតិជន ........ ២១
១.២.២.៣.៣. ការអនុវត្តទោសសហគមន៍ចំពោះអនីតិជន ........ ២២
**១.២.៣. ការប្រកាសទោស** ........ ២៣
១.២.៣.១. ការប្រកាសមូលទោស ........ ២៤
១.២.៣.២. ការប្រកាសទោសបន្ថែម ........ ២៤
១.២.៣.២.១. ការប្រកាសទោសបន្ថែមលើមូលទោស ........ ២៥
១.២.៣.២.២. ការប្រកាសទោសបន្ថែមជំនួសមូលទោស ........ ២៥
១.២.៣.៣. ការប្រកាសទោសជំនួស ........ ២៥
**១.៣. បែបបទ និងផលប៉ះពាល់ផ្សេងៗដល់ការអនុវត្តទោស** ........ ២៧
**១.៣.១. អាជ្ញាយុកាលនៃទោស** ........ ២៧
១.៣.១.១. ដែនអនុវត្តអាជ្ញាយុកាលនៃទោស ........ ២៧
១.៣.១.២. រយៈពេលអាជ្ញាយុកាលនៃទោស ........ ២៨
**១.៣.២. ការបន្ធូរបន្ថយទោស និងការលើកលែងទោស** ........ ២៨
១.៣.២.១. លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងលើកលែងទោស ........ ២៩
១.៣.២.១.១. លក្ខខណ្ឌបុគ្គលិកលក្ខណៈរបស់ទណ្ឌិត ........ ៣០
១.៣.២.១.២. អាជ្ញាយុកាលកំណត់ក្នុងការបន្ធូរបន្ថយទោស ........ ៣០
១.៣.២.២. នីតិវិធីក្នុងការបន្ធូរបន្ថយទោស និងលើកលែងទោស ........ ៣២
**១.៣.៣. ការលើកលែងទោសជាទូទៅ** ........ ៣៤
១.៣.៣.១. ច្បាប់ស្ដីពីការលើកលែងទោសជាទូទៅ ........ ៣៤
១.៣.៣.២. អានុភាពនៃការលើកលែងទោសជាទូទៅ ........ ៣៥
១.៣.៣.៣. មរណភាពរបស់ជនជាប់ទោស ........ ៣៦

## ជំពូកទី២

## ការព្យួរទោស

**២.១. សញ្ញាណទូទៅនៃការព្យួរទោស** ........ ៣៧
**២.១.១. អត្ថន័យ** ........ ៣៧

**២.១.២. ប្រភេទនៃការព្យួរទោស** ....................................................... ៣៨
២.១.២.១. ការព្យួរទោសធម្មតា ....................................................... ៣៨
២.១.២.២. ការព្យួរទោសសាកល្បង ....................................................... ៣៩
**២.២. បែបបទនៃការប្រកាសការព្យួរទោស** ....................................................... ៤០
**២.២.១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា** ....................................................... ៤០
២.២.១.១. ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម ....................................................... ៤០
២.២.១.១.១. លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន ....................................................... ៤១
២.២.១.១.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ ....................................................... ៤១
២.២.១.១.៣. ការព្យួរទោសមួយផ្នែក ....................................................... ៤១
២.២.១.១.៤. ការដកហូតការព្យួរទោស ....................................................... ៤២
២.២.១.១.៥. ការមិនដកហូតការព្យួរទោស ....................................................... ៤៣
២.២.១.១.៦. ការទុកជាអសារបង់នូវការផ្តន្ទាទោស ....................................................... ៤៣
២.២.១.២. ការចោទប្រកាន់ចំពោះបទលហុ ....................................................... ៤៤
២.២.១.២.១. លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន ....................................................... ៤៤
២.២.១.២.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ ....................................................... ៤៤
២.២.១.២.៣. ការដកហូតការព្យួរទោស ....................................................... ៤៤
២.២.១.២.៤. ការមិនដកហូតការព្យួរទោស ....................................................... ៤៥
២.២.១.២.៥. ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស ....................................................... ៤៥
**២.២.២. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង** ....................................................... ៤៦
២.២.២.១. រយៈពេលនៃការព្យួរទោសសាកល្បង ....................................................... ៤៦
២.២.២.២. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក ....................................................... ៤៦
២.២.២.២.១. វិធានការត្រួតពិនិត្យ ....................................................... ៤៦
២.២.២.២.២. កាតព្វកិច្ចដោយឡែក ....................................................... ៤៧
២.២.២.២.៣. ការកែប្រែកាតព្វកិច្ចដោយឡែក ....................................................... ៤៨
២.២.២.៣. ការដកហូត និង ការចាត់ទុកជាអសារបង់ ....................................................... ៤៩
២.២.២.៣.១. ការដកហូត ....................................................... ៤៩
២.២.២.៣.២. ការចាត់ទុកជាអសារបង់ ....................................................... ៥០
**សេចក្តីសន្និដ្ឋាន** ....................................................... ៥១

**អនុសាសន៍**......................................................................................................................................................៥៣
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំនៃការស្រាវជ្រាវ

ប្រទេសកម្ពុជាយើងជាប្រទេសមួយដែលធ្លាប់បានឆ្លងកាត់នូវភ្នក់ភ្លើងនៃសង្គ្រាមស៊ីវិលអស់ជាច្រើនសតវត្ស ដែលធ្វើឲ្យបាត់បង់នូវសណ្តាប់ធ្នាប់ សន្តិសុខសង្គម ខូចខាតហេដ្ឋារចនាសម្ព័ន្ធយ៉ាងធ្ងន់ធ្ងរ រួមទាំងការជាន់ឈ្លី ធ្វើបាប ការគៀបសង្កត់ពីសំណាក់អ្នកមានអំណាចផ្សេងៗ។ បន្ទាប់ពីសង្គ្រាមត្រូវបានបញ្ចប់ ប្រទេសកម្ពុជាយើងបាននឹងកំពុងខិតខំស្តារនូវរាល់ហេដ្ឋារចនាសម្ព័ន្ធ កសាងអភិវឌ្ឍសណ្តាប់ធ្នាប់សង្គមជាតិទាំងមូល មិនតែប៉ុណ្ណោះរាជរដ្ឋាភិបាលក៏បានខិតខំប្រឹងប្រែងកសាងមុខមាត់របស់ប្រទេសកម្ពុជាយើងឡើងវិញលើឆាកអន្តរជាតិទាំងថ្នាក់តំបន់ និងថ្នាក់សកល។ ក្នុងកំឡុងពេលនោះប្រទេសកម្ពុជាយើងបានអនុវត្តនូវច្បាប់រដ្ឋធម្មនុញ្ញដែលត្រូវបានអនុម័តដោយព្រះរាជាណាចក្រកម្ពុជាផ្ទាល់ ហើយបានប្រកាសឲ្យប្រើនៅក្នុងឆ្នាំ ១៩៩៣ មកម្ល៉េះ។ រាជរដ្ឋាភិបាលបានចាត់ទុកវិស័យច្បាប់ជាទិសដៅអាទិភាពក្នុងការអភិវឌ្ឍដោយបានបញ្ចូលវិស័យនេះទៅក្នុងយុទ្ធសាស្ត្រចតុកោណ ពោលគឺគោលនយោបាយរបស់ជាតិ ដែលត្រូវបានគេស្គាល់ថាជាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលមានកំណត់នៅក្នុងស្នូលនៃយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេសជាតិសព្វថ្ងៃ។ អត្ថបទច្បាប់ជាច្រើនត្រូវបានតាក់តែងឡើងដោយផ្អែកលើតម្រូវការសង្គមសព្វថ្ងៃ ដែលជួយសម្រួលដល់បញ្ហាចំណោះដឹងបទពិសោធន៍ក្នុងជីវភាពរស់នៅរបស់បងប្អូនប្រជាពលរដ្ឋជាច្រើនដែលកំពុងជួបប្រទះការលំបាក ព្រមទាំងជាចក្ខុវិស័យក្នុងការអភិវឌ្ឍជាតិនាពេលអនាគតផងដែរ។

បើយោងទៅតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងយ៉ាងច្បាស់អំពីអំណាចតុលាការក្នុងការគ្រប់គ្រងទៅលើរឿងក្តីទាំងអស់ រួមទាំងផ្នែករដ្ឋបាលផងដែរ។ អំណាចតុលាការមានសិទ្ធិក្នុងការសម្រេចសេចក្តីពាក់ព័ន្ធជាមួយនឹងវិវាទដែលកើតមានឡើងនៅក្នុងស្ថាប័ន ក្នុងការរកយុត្តិធម៌ជូនប្រជាពលរដ្ឋដែលជាជនរងគ្រោះតាមនីតិវិធីដែលច្បាប់បានកំណត់ ហើយចៅក្រមគឺជាអ្នកដែលមានសិទ្ធិនៅក្នុងការជម្រះក្តីដោយគោរពទៅតាមច្បាប់ និងសម្បជញ្ញៈរបស់ខ្លួន។ តុលាការព្រហ្មទណ្ឌ គឺជាអ្នកទទួលបន្ទុកដោះស្រាយបញ្ហាដែលពាក់ព័ន្ធទៅនឹងរឿងក្តីព្រហ្មទណ្ឌតែប៉ុណ្ណោះ ពោលគឺតុលាការមានសិទ្ធិក្នុងការដាក់ទណ្ឌកម្ម ឬអនុវត្តការព្យួរទោសទៅលើជនណាមួយដែលបានប្រព្រឹត្តល្មើស និងក្រមព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិព្រហ្មទណ្ឌ។

ជាគោលការណ៍ នៅពេលមានបទល្មើសមួយកើតមានឡើងមុននឹងឈានដល់ការជំនុំជម្រះ គឺទាមទារឲ្យបំពេញនីតិវិធីជាច្រើនតាមដំណាក់កាលជាមុនសិនដូចជាកិច្ចស៊ើបអង្កេត កិច្ចចោទប្រកាន់ និងកិច្ចស៊ើបសួរជាដើម ដើម្បីស្វែងរកភស្តុតាង និងការពិតនៃរឿងក្តីទាំងនោះមុននឹងចេញសេចក្តីសម្រេច។ នៅពេលតុលាការប្រកាសពីការផ្តន្ទាទោស ទោសអាចត្រូវបានអនុវត្ត ឬមិនត្រូវបានអនុវត្ត អាស្រ័យដោយតុលាការពិនិត្យមើលទៅលើស្ថានភាពនៃបទល្មើស និងលក្ខណៈសម្បត្តិរបស់ជនជាប់ចោទ ឬជនដែលត្រូវផ្តន្ទាទោសនោះ។ ទោសព្រហ្មទណ្ឌដែល

អាចយកមកអនុវត្តមាន៣ គឺមូលទោស ទោសបន្ថែម និងទោសជំនួស ដែលការអនុវត្តទោសទាំង៣នេះមានលក្ខខណ្ឌខុសៗពីគ្នា។

## ២. ចំណោទបញ្ហា

ទោសព្រហ្មទណ្ឌមានសារៈសំខាន់ចំពោះចារីទាំងឡាយណាដែលមានពិរុទ្ធភាពពីបទល្មើសព្រហ្មទណ្ឌណាមួយ ដែលត្រូវបានចោទប្រកាន់ហើយឈានដល់ការសម្រេចសេចក្តីដោយតុលាការព្រហ្មទណ្ឌនូវទណ្ឌកម្មចំពោះពិរុទ្ធជន។ ម្យ៉ាងវិញទៀត ទណ្ឌកម្មព្រហ្មទណ្ឌអាចនាំឲ្យមាននូវទោសទណ្ឌចំពោះជនដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ហើយក្នុងការប្រកាសសេចក្តីសម្រេច គឺមានតែតុលាការនោះទេ ដែលមានសមត្ថកិច្ចក្នុងការសម្រេចផ្តន្ទាទោសដល់ជនដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។[1]

ហេតុនេះហើយ ទើបយើងខ្ញុំលើកយកប្រធានបទអំពីការអនុវត្តទោស និងការព្យួរទោស មកសរសេរនៅក្នុងសារណានេះ គឺដើម្បីចង់បង្ហាញដល់អ្នកអាន ដូចជានិស្សិតជំនាន់ក្រោយៗទៀតឲ្យយល់ដឹងបន្ថែមថាអ្វីទៅជាការអនុវត្តទោស? អ្វីទៅជាការព្យួរទោស? តើការនីតិវិធីនៃការអនុវត្តត្រូវអនុវត្តយ៉ាងដូចម្តេច? មានផលប៉ះពាល់អ្វីខ្លះដល់ការអនុវត្តទោស? ហើយលក្ខខណ្ឌនៃការព្យួរទោសមានអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវសារណានេះឡើងគឺក្នុងគោលបំណងដើម្បីធ្វើការពង្រឹង និងពង្រីកនូវសមត្ថភាពបន្ថែមពីសារៈសំខាន់នៃទោសព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលទាក់ទងជាមួយនឹងនីតិវិធីរបស់តុលាការក្នុងការអនុវត្តទោសណាមួយ ដែលជាចំណេះដឹង និងបទពិសោធន៍ដ៏ល្អមួយដល់យើងខ្ញុំទាំងពីរ និងជាទុនមួយសម្រាប់ទុកជាឯកសារដល់និស្សិតជំនាន់ក្រោយៗទៀត។ លើសពីនេះទៅទៀត អ្នកសិក្សាក៏អាចស្វែងយល់បន្ថែមអំពីសេចក្តីសម្រេចរបស់តុលាការក្នុងការអនុវត្តទោស ឬការព្យួរទោសបែបណាចំពោះទណ្ឌិតដែលមានបញ្ញត្តិនៅក្នុងច្បាប់ជាធរមាន។

## ៤. ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទដែលបានលើកឡើងនៅក្នុងចំណោទបញ្ហាខាងលើ យើងខ្ញុំទាំងពីរបានខិតខំធ្វើការសិក្សាស្រាវជ្រាវដោយផ្អែកទៅលើឯកសារតាមច្បាប់ និងបទប្បញ្ញត្តិដែលចូលជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជាមានដូចជាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ និងលិខិតបទដ្ឋានគតិយុត្តនានា ព្រមទាំងកម្រងឯកសារ ស្នាដៃ សៀវភៅ បទឧបទ្ទេសរបស់សាស្ត្រាចារ្យ និងអ្នកជំនាញវិស័យច្បាប់នានាផ្នែកនីតិឯកជនផងដែរ ទើបសរសេរនូវសារណានេះឡើងបានចំនួន ០២ ជំពូក។ នៅក្នុងសារណានេះនឹង

[1] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦។

បង្ហាញអំពីប្រភេទនៃទោស និងការអនុវត្តទោសទៅលើរូបវន្តបុគ្គល ក៏ដូចជាលក្ខខណ្ឌនៃការព្យួរដែលជាផ្នែកមួយនៃទោសព្រហ្មទណ្ឌផងដែរ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះឡើង យើងខ្ញុំបានដកស្រង់ និងប្រមូលឯកសារមួយចំនួនចេញពីក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ច្បាប់ពន្ធនាគារ សៀវភៅមេរៀនដែលសាស្ត្រាចារ្យផ្នែកច្បាប់បានចងក្រង និងតាមប្រព័ន្ធអ៊ីនធើណេតចេញពីព័ត៌មានមួយចំនួន រួមទាំងការសាកសួរពិគ្រោះជាមួយសាស្ត្រាចារ្យណែនាំ និងសាស្ត្រាចារ្យច្បាប់នៅសាកលវិទ្យាល័យផ្ទាល់។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ខ្លឹមសារនៃប្រធានបទនេះ បានបែងចែកដូចខាងក្រោម ៖

- សេចក្តីផ្តើម
- ជំពូកទី ១ ស្តីអំពី ការអនុវត្តទោស។
- ជំពូកទី ២ ស្តីអំពី ការព្យួរទោស។

# ជំពូកទី១

# ការអនុវត្តទោស

# ជំពូកទី១
# ការអនុវត្តទោស

## ១.១. សញ្ញាណទូទៅនៃទោសព្រហ្មទណ្ឌ

នៅក្នុងច្បាប់ព្រហ្មទណ្ឌ ការកំណត់នូវបទល្មើសនីមួយៗទៅតាមបញ្ញត្តិដែលមានចែង គឺមានច្រើនប្រភេទដែលទាក់ទងនឹងឆន្ទានុសិទ្ធិរបស់ចៅក្រមក្នុងការកាត់ក្តីបទល្មើសនីមួយៗ។ ក្នុងនោះ ចៅក្រមត្រូវផ្តន្ទាទោសចារីដែលបានប្រព្រឹត្តបទល្មើសផ្ទុយនឹងច្បាប់ទៅតាមទោសរបស់ជននោះ។ ដូច្នេះការស្វែងយល់ពីនិយមន័យ គឺជាការចាំបាច់មុនឈានទៅដល់ប្រភេទនៃទោសព្រហ្មទណ្ឌ។

### ១.១.១. អត្ថន័យនៃទោស

#### ១.១.១.១. អត្ថន័យតាមបែបអក្សរសាស្ត្រ

យោងតាមវចនានុក្រមសម្តេច **ជួន ណាត** ទោសគឺជាពាក្យបាលីសំក្រឹត មានន័យថា ការប្រទូស្តកំហឹង សម្អប់ កំហុសៈ មនុស្សមានទោស ចិត្តប្រកបដោយទោស។

#### ១.១.១.២. អត្ថន័យតាមបែបនីតិសាស្ត្រ

ទោស គឺសំដៅដល់ទោសព្រហ្មទណ្ឌ ជាទណ្ឌកម្មដែលកំណត់ដោយច្បាប់រដ្ឋ ដែលផ្តល់អំណាចដល់អង្គការតុលាការជាអ្នកមានសមត្ថកិច្ចក្នុងការប្រកាសផ្តន្ទាទៅលើបុគ្គលណា ដែលបានប្រព្រឹត្តផ្ទុយនឹងក្រមព្រហ្មទណ្ឌ ឬបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានណាមួយ ដោយផ្អែកទៅលើទម្ងន់នៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់បុគ្គលដែលប្រព្រឹត្តបទល្មើស។

ម្យ៉ាងវិញទៀត ទោសព្រហ្មទណ្ឌពុំមានមូលដ្ឋានណាដែលផ្អែកទៅលើលក្ខខណ្ឌសង្គមនោះទេ មិនថា (រូបសម្បត្តិ, ឋានៈ និងទ្រព្យធន, អ្នកមាន, អ្នកក្រ, អ្នកដែលមានឋានៈ ឬគ្មានឋានៈនោះទេ សុទ្ធតែត្រូវផ្តន្ទាទោសដូចគ្នា) ប្រសិនបើបុគ្គលនោះបានប្រព្រឹត្តនូវបទល្មើស ដែលខុសពីច្បាប់ព្រហ្មទណ្ឌបានចែង។[2]

ជាការពិតទោសព្រហ្មទណ្ឌ គឺសំដៅលើទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ហើយគេចាត់ទុកទោសទាំងនោះ គឺជាបទល្មើសដែលចេញមកពីកំហុស ឬអំពើរបស់ចារីផ្ទាល់ ឬសហចារីដែលចារីបានប្រព្រឹត្តអំពើដែលល្មើសនឹងច្បាប់ ហើយបានជះឥទ្ធិពលអាក្រក់ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសង្គម។ តួនាទីនៃទោសគឺដើម្បីបង្រ្កាប កែប្រែ និងបង្ការនូវអំពើដែលជាបទល្មើស។ ចំពោះការដាក់ទោសជនដែលបានប្រព្រឹត្តអំពើខុសច្បាប់ទាំងនោះ ត្រូវចាំបាច់រកឲ្យឃើញនូវពិរុទ្ធភាព និងធាតុផ្សំនៃបទល្មើសរបស់ជននោះសិន ដើម្បីកំណត់អំពីប្រភេទនៃបទល្មើស ឬទោសនោះ។ ប្រសិនបើរកមិនឃើញនូវបទល្មើសទេ នោះពុំមានកម្មវត្ថុក្នុងការផ្តន្ទាទោសឡើយ ព្រោះបើយោងតាមគោលការណ៍នីត្យានុកូលភាពនៃទោស និងគោលការណ៍នីត្យានុកូលភាពនៃបទល្មើស

[2] https://ciclg.com/cn/article/137, (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១)។

ដែលត្រូវបានចាត់ទុកថាគ្មានទោស គ្មានបទល្មើស បើគ្មានច្បាប់ចែង។[3] តាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើសព្រហ្មទណ្ឌនេះ អំពើណាមួយដែលអាចជាបទល្មើសបាន លុះត្រាតែអំពើនោះមានចែងក្នុងច្បាប់ជាធរមាន ហើយទោសដែលអាចប្រកាសបាន លុះត្រាតែទោសនោះបានចែងនៅក្នុងច្បាប់ផងដែរ។ ហេតុដូច្នេះហើយបានជានៅក្នុងក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ ២០០៩ បានចែងអំពីនិយមន័យ, ធាតុផ្សំនៃបទល្មើស និងអំពីទោសជាច្រើន ដើម្បីឲ្យមានភាពងាយស្រួលក្នុងការអនុវត្តទោសទាំងនោះស្របទៅតាមបទដ្ឋានគតិយុត្ត ក៏ដូចជាស្របតាមបទប្បញ្ញត្តិ និងគោលការណ៍នៃច្បាប់ផងដែរ។

## ១.១.២. ប្រភេទនៃទោសព្រហ្មទណ្ឌ

ក្រមព្រហ្មទណ្ឌបានចែងទោសជា ៣ ប្រភេទដូចជា៖

- មូលទោស
- ទោសបន្ថែម
- ទោសជំនួស។

### ១.១.២.១. មូលទោស

មូលទោស គឺជាទោសចម្បងដែលតុលាការតែងតែយកមកប្រើប្រាស់ក្នុងការកាត់ក្តីដាក់ទោស និងប្រកាសទោសចំពោះជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើស។ រាល់អំពើដែលចាត់ទុកជាបទល្មើសត្រូវតែមានជាប់មូលទោសជានិច្ច ក៏ប៉ុន្តែក្នុងករណីខ្លះតុលាការអាចប្រើប្រាស់ទោសជំនួស ឬ ទោសបន្ថែមជំនួសឲ្យមូលទោសបាន។

មូលទោស ត្រូវបានគេធ្វើការបែងចែកជាពីរប្រភេទរួមមានដូចជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[4] ការពិន័យត្រូវគិតជាប្រាក់រៀល។[5]

#### ១.១.២.១.១. ទោសដាក់ពន្ធនាគារ

ទោសដាក់ពន្ធនាគារ គឺជាទោសដែលលុបបំបាត់នូវសិទ្ធិសេរីភាពទាំងអស់ជាមូលដ្ឋានហើយជាប្រភេទទោសដែលមានរយៈពេលយូរ ចាប់ពី១ថ្ងៃ រហូតដល់៣០ឆ្នាំ ឬអស់មួយជាជីវិត អាស្រ័យទៅតាមបទល្មើសដែលជននោះបានប្រព្រឹត្ត។ ទោសដាក់ពន្ធនាគារ អាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[6] ទោសដាក់ពន្ធនាគារត្រូវគិតចិរវេលា ១ (មួយ) ថ្ងៃត្រូវគិត ២៤ (ម្ភៃបួន) ម៉ោង ១(មួយ) ខែ ត្រូវគិត ៣០ (សាមសិប) ថ្ងៃ និង១

[3] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣។

[4] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣ កថាខណ្ឌទី១។

[5] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣ កថាខណ្ឌទី១។

[6] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៦ កថាខណ្ឌទី២។

(មួយ) ឆ្នាំ ត្រូវគិត ១២ (ដប់ពីរ) ខែ[7] ហើយរយៈពេលនៃទោសគឺត្រូវគិតចាប់ពីថ្ងៃដែលបានកាត់ទោសតទៅ។

នៅពេលដែលតុលាការបានប្រកាសឲ្យជនណាម្នាក់ជាប់ពន្ធនាគារហើយ នោះថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្នត្រូវដកទាំងស្រុងចេញពីថិរវេលានៃទោសជាប់ពន្ធនាគារដែលត្រូវទទួលរងនោះ។ ចំពោះទណ្ឌិតដែលបានទទួលទោសនៅក្នុងពន្ធនាគារចប់សព្វគ្រប់ហើយ ជននោះនឹងត្រូវបានដោះលែងឲ្យមានសេរីភាពសារជាថ្មីវិញ ក៏ប៉ុន្តែចំពោះទណ្ឌិតដែលទោសរបស់ខ្លួនត្រូវបញ្ចប់នៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ ឬ ថ្ងៃឈប់សម្រាកផ្សេងៗ ទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តបានកំណត់ត្រូវតែដោះលែងឲ្យមានសេរីភាពវិញនៅមុនថ្ងៃឈប់សម្រាកនោះ។[8]

**១.២.១.២. ទោសពិន័យជាប្រាក់**

ទោសពិន័យជាប្រាក់ គឺតម្រូវឲ្យទណ្ឌិតបង់នូវចំនួនប្រាក់ដែលច្បាប់បានកំណត់ទៅតាមការប្រកាសទោសរបស់ចៅក្រម ហើយទឹកប្រាក់ត្រូវកំណត់ជាប្រាក់រៀល។ ចំនួនទឹកប្រាក់ដែលបានបង់ ហៅបានថាជាប្រាក់ពិន័យ គឺត្រូវបង់ចូលថវិការដ្ឋ។[9] ប្រាក់ពិន័យដែលទទួលបានត្រូវរក្សាទុកនូវក្នុងធនាគារជាតិដោយចូលជាប្រាក់របស់រដ្ឋ មិនមែនជាប្រាក់សំណងដែលត្រូវបង់ទៅឲ្យជនរងគ្រោះនោះទេ។

ឧទាហរណ៍ ៖ ក្នុងករណីបង្ករបួសស្នាមដោយចេតនា ប្រសិនបើចៅក្រមរកឃើញថាមានពិរុទ្ធភាពពិតមែន ជនល្មើសអាចត្រូវទទួលទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៣ (បី) ឆ្នាំ និងពិន័យជាប្រាក់ពី ២ លានរៀល ទៅ៦លានរៀល។[10] ២លានរៀល ទៅ ៦លានរៀលនេះ គឺជាទោសព្រហ្មទណ្ឌដែលត្រូវបង់ទៅឲ្យរដ្ឋ ទោះបីមាន ឬក៏គ្មានដើមបណ្តឹងរដ្ឋប្បវេណី ក៏ជនល្មើសត្រូវតែបង់ដែរ។ ក៏ប៉ុន្តែការបង្ករបួសស្នាមតែងតែមានជនរងគ្រោះ ដូច្នេះបើសិនជនរងគ្រោះទាមទារសំណងជំងឺចិត្ត ចៅក្រមអាចសម្រេចឲ្យជនល្មើសបង់សំណងជំងឺចិត្តឲ្យជនរងគ្រោះបន្ថែមពីលើប្រាក់ពិន័យដែលត្រូវបង់ទៅឲ្យរដ្ឋ។[11]

**១.១.១.២. ទោសបន្ថែម**

ទោសបន្ថែម គឺជាទោសដែលតុលាការយកមកប្រើនៅក្នុងការប្រកាសបន្ថែមទៅលើមូលទោស ដោយសំដៅដល់ទោសដែលត្រូវដាក់បញ្ចូល ឬដាក់ជំនួសទៅក្នុងមូលទោស។ ក្នុងករណីខ្លះទោសបន្ថែម ដែលត្រូវបានបន្ថែមលើមូលទោសដោយចៅក្រម ពុំមានការប្រកាសទោសច្បាស់លាស់នោះទេ។ ទោសបន្ថែមត្រូវបានបង្កើតឡើងក្នុងគោលបំណងកម្រិតនូវទណ្ឌកម្មឲ្យសមស្របទៅតាម បទល្មើសដែលបានប្រព្រឹត្តជាក់ស្តែង ដើម្បីធានាដល់ការអនុវត្តដែលគេហៅថា **គោលការណ៍ឯកត្តកម្មនៃទោស។**[12] ចំពោះទោសនេះផងដែរ ចៅក្រមអាចធ្វើការ

---

[7] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៩ ។
[8] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥០។
[9] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥២។
[10] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២១៧។
[11] នាទីយល់ដឹងពីច្បាប់ និងជំនួញ, ក្រមព្រហ្មទណ្ឌខ្មែរ ៖ ប្រភេទនៃទោសព្រហ្មទណ្ឌ និងការអនុវត្ត រៀបរៀងដោយ លោក សេង ឌីណា។
[12] ទំព័រស្វែងយល់ពីច្បាប់ , ប្រភេទនៃទោស រៀបរៀងដោយ ន.ស.រ , មករា ឆ្នាំ២០១៧ ទំព័រទី ១០។

ប្រកាសមួយ ឬច្រើនទៅតាមឆន្ទានុសិទ្ធិរបស់ចៅក្រមដោយផ្អែកតាមច្បាប់ ហើយការប្រកាសទោសត្រូវតែមានភាពច្បាស់លាស់។[13]

ជាការពិតណាស់ ទោសនេះត្រូវស្ថិតនៅក្រោមគោលការណ៍នីត្យានុកូលភាព ពោលគឺទោសនេះនៅតែត្រូវបានប្រកាសឡើងដរាបណាទោសនេះ ត្រូវបានចែងដោយច្បាប់ព្រហ្មទណ្ឌផ្អែកទៅលើកាលៈទេសៈ និងស្ថានទម្ងន់នៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ឬកិរិយាមាយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសចំពោះជនរងគ្រោះជាដើម។[14] ទោសបន្ថែមមាននៅក្នុងនីតិកម្មខ្មែរពីបុរាណ ដោយនៅក្នុងនោះមានទោសជាច្រើនដែលទាក់ទងនឹងទោសខាងផ្លូវចិត្ត និងទោសនាំឲ្យខូចកិត្តិយស។[15]

### ១.១.២.២.១. ប្រភេទនៃទោសបន្ថែម

ប្រភេទនៃទោសបន្ថែមមាន ៖[16]

១ - ការដកសិទ្ធិខ្លះជាពលរដ្ឋ។

២ - ការហាមឃាត់ចំពោះការប្រកបវិជ្ជាជីវៈណា ដែលបទល្មើសនោះបានប្រព្រឹត្តនៅក្នុងពេលដែលប្រកបវិជ្ជាជីវៈនេះ។

៣ - ការហាមឃាត់ចំពោះការបើកបរយានយន្តគ្រប់ប្រភេទ។

៤ - ការព្យួរលិខិតបើកបរ។

៥ - ការហាមឃាត់ចំពោះការស្នាក់នៅ។

៦ - ការហាមឃាត់ចំពោះការចាកចេញពីដែនដីនៃព្រះរាជាណាចក្រកម្ពុជា។ ទណ្ឌិតត្រូវតែប្រគល់លិខិតឆ្លងដែនរបស់ខ្លួនទៅក្រឡាបញ្ជីនៃតុលាការ ហើយលិខិតឆ្លងដែននោះត្រូវបានរក្សាទុកតាមលក្ខខណ្ឌដែលកំណត់ដោយការរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[17]

៧ - ការហាមឃាត់ចំពោះការចូល និងការស្នាក់នៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជាចំពោះទណ្ឌិត ដែលជាជនបរទេស។

៨ - ការរឹបអូសឧបករណ៍សម្ភារៈ ឬវត្ថុដែលប្រើប្រាស់ក្នុងពេលប្រព្រឹត្តបទល្មើស ឬដែលទុកសម្រាប់ប្រព្រឹត្តបទល្មើស។

៩ - ការរឹបអូសវត្ថុ ឬមូលនិធិ ដែលជាកម្មវត្ថុនៃបទល្មើស។

---

[13] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០០។

[14] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៦។

[15] មេរៀននីតិព្រហ្មទណ្ឌ , ខែធ្នូ ឆ្នាំ២០០៧ , ទំព័រ ៥៤។

[16] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៣។

[17] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦០។

១០ - ការរឹបអូសផលទុន ឬ ទ្រព្យសម្បត្តិ ដែលជាផលកើតចេញពីបទល្មើស។

១១ - ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬ ចលនវត្ថុ ដែលនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។

១២ - ការរឹបអូសយានជំនិះដែលជារបស់ទណ្ឌិត។

១៣ - ការហាមឃាត់ចំពោះការកាន់កាប់ ឬ ការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ។

១៤ - ការបណ្តេញចេញពីលទ្ធកម្មសាធារណៈ។

១៥ - ការបិទគ្រឹះស្ថានដែលប្រើប្រាស់ ដើម្បីត្រៀម ឬប្រព្រឹត្តបទល្មើស។

១៦ - ការហាមឃាត់ចំពោះការធ្វើអាជីវកម្មនៅក្នុងគ្រឹះស្ថាន ដែលបើកចំហសម្រាប់សាធារណជន ឬដែលប្រើប្រាស់ដោយសាធារណជន។

១៧ - ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស។

១៨ - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មាន។

១៩ - ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍។

ក្រៅពីទោសបន្ថែមដែលបានរៀបរាប់ខាងលើ ក៏មានទោសបន្ថែមដែលមានចែងក្នុងច្បាប់ដោយឡែកដែរ។ ទោសបន្ថែមទាំងឡាយ ដែលមានចែងនៅក្នុងចំណុច ១, ២, ៣, ៤, ៥, ៦ និង ៧ ខាងលើនេះត្រូវអនុវត្តនៅពេលផុតទោសពន្ធនាគារ លើកលែងតែមានសេចក្តីសម្រេចផ្ទុយរបស់តុលាការ។[18]

**១.១.២.៣. ទោសជំនួស**

ទោសជំនួស គឺសំដៅទៅលើទោសដែលតុលាការយកមកប្រកាសជំនួសមូលទោស ប្រសិនបើតុលាការយល់ឃើញថាទោសនោះមិនអាចប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ពិន័យជាប្រាក់បាននោះទេ។[19] នៅពេលមានករណីនេះកើតឡើង តុលាការនឹងប្រើទោសការងារសហគមន៍ ឬការស្តីបន្ទោសមកប្រកាសជំនួសឲ្យមូលទោសវិញ។ តុលាការដែលប្រកាសទោសការងារសហគមន៍ ឬការស្តីបន្ទោស ពុំអាចប្រកាសទោសពន្ធនាគារ ឬទោសពិន័យបានទេ[20] ព្រោះតុលាការពុំអាចប្រកាសទោសជំនួសទាំងពីរនេះ ត្រួតគ្នាឡើយ។ មូលហេតុដែលសម្រេចអំពីទោសជំនួសបាន គឺដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ គេអាចពិនិត្យទៅលើស្ថានភាពកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ដើម្បីមិនអនុវត្តទោសដែលជាមូលដ្ឋានដោយយកទោសជំនួសមកអនុវត្តវិញ។[21]

**១.១.២.៣.១. ទោសការងារសហគមន៍**

ទោសការងារសហគមន៍ គឺជាកាតព្វកិច្ចដែលជនជាប់ចោទត្រូវបំពេញនៅការងារមួយដែលគ្មានប្រាក់

[18] សំណួរចម្លើយសម្រាប់ការត្រៀមប្រលងរៀបចំដោយបណ្ណាគារភក្តីឡង់ , ចេញថ្ងៃទី ២៦ /១២/២០១៦។

[19] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៨។

[20] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៨។

[21] សំណួរចម្លើយសម្រាប់ការត្រៀមប្រលងរៀបចំដោយបណ្ណាគារភក្តីឡង់ , ចេញថ្ងៃទី ២៦ /១២/២០១៦។

កម្រៃនិងបានជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិបុគ្គល សាធារណៈផ្សេងៗទៀត ដល់សហគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[22] ការងារដែលជននោះត្រូវបានដាក់ឲ្យធ្វើអាចប្រែប្រួលរយៈពេលចាប់ពី ៣០ (សាមសិប) ម៉ោង រហូតដល់២០០ (ពីររយ) ម៉ោង។[23] ការងារនេះមិនមែនជាប្រយោជន៍នៃរូបវន្តបុគ្គលនោះទេ ព្រោះជនដែលត្រូវអនុវត្តទោសនេះអាចជួយជាប្រយោជន៍រួមដល់រដ្ឋ និងសង្គមទាំងមូល។

ម៉្យាងវិញទៀត ការងារសហគមន៍ ត្រូវតែស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារជាអាទិ៍ ការងារនៅពេលយប់ អនាម័យ សន្តិសុខ និងការងាររបស់ស្ត្រីជាដើម។ ការងារសហគមន៍អាចត្រួតគ្នាជាមួយនឹងការអនុវត្តសកម្មភាពវិជ្ជាជីវៈ។[24] រដ្ឋជាអ្នករ៉ាប់រងចេញសោហ៊ុយជួសជុលសំណងការខូចខាតនានា ដែលបង្កឡើងដោយទណ្ឌិតនៅពេលកំពុងអនុវត្តការងារសហគមន៍។[25] លើសពីនេះទៅទៀតព្រះរាជអាជ្ញាមានតួនាទីជាអ្នកកំណត់នូវទោសការងារសហគមន៍នេះចំពោះទណ្ឌិត នៅពេលដែលតុលាការសម្រេចសេចក្តីឲ្យជននោះទទួលទោសនេះ។

**១.១.២.៣.២. ការស្តីបន្ទោស**

ការស្តីបន្ទោស តុលាការគ្រាន់តែធ្វើការស្តីបន្ទោសដល់ជនល្មើស ដែលបានប្រព្រឹត្តបទល្មើស ប៉ុន្តែមិនផ្តន្ទាទោសដាក់ពន្ធនាគារ ឬ ទោសពិន័យជាប្រាក់ឡើយ កាលបើជនល្មើសបានសងការខូចខាតរួចរាល់ហើយ។[26] ការស្តីបន្ទោសទាំងនោះភាគច្រើន តុលាការប្រើទៅលើអនីតិជនណាដែលមានអាយុចាប់ពី ១៤ឆ្នាំឡើង និងក្រោម ១៨ឆ្នាំ ព្រោះជននោះត្រូវបានគេយល់ឃើញថាខ្វះសមត្ថភាពក្នុងការប្រព្រឹត្តបទល្មើសដោយឯកឯង។ តុលាការអាចប្រកាសទោសនេះទៅលើអនីតិជនបាន ដោយការព្រមាន ប្រដៅអំពីទោសកំហុសឆ្គងដែលគាត់បានប្រព្រឹត្ត ហើយព្រមានថាកុំឲ្យគាត់ប្រព្រឹត្តបទល្មើសតទៅទៀត។[27]

តុលាការអាចធ្វើការប្រកាសការស្តីបន្ទោស កាលបើជនជាប់ចោទរងទោសដាក់ពន្ធនាគារ ដែលមានអតិបរមាតិចជាង ឬស្មើនឹង ០៣ឆ្នាំ ហើយប្រសិនបើបានបំពេញលក្ខខណ្ឌបីយ៉ាងដូចខាងក្រោម៖[28]

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈបង្កដោយបទល្មើសបានបញ្ចប់។
- ការខូចខាតត្រូវបានជួសជុលហើយ និង
- ជនជាប់ចោទបង្ហាញការធានាក្នុងការចូលរួមរស់ក្នុងសង្គមវិញ។

---

[22] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ កថាខណ្ឌទី២។

[23] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ កថាខណ្ឌទី២។

[24] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧៤។

[25] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧៥។

[26] https://ciclg.com/cn/article/137, (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១)។

[27] យោងតាមប្រសាសន៍របស់ **ឯកឧត្តម កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌនៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តី ក្រមព្រហ្មទណ្ឌ ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០។

[28] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧៦ ។

### ១.១.៣. គោលបំណងនៃទោស

ទោសត្រូវបានប្រកាសដោយតុលាការ គ្មានទោសណាមួយដែលអាចយកមកអនុវត្តបានឡើយ ប្រសិនបើទោសនោះមិនត្រូវបានប្រកាសដោយតុលាការ។[29]ម្យ៉ាងវិញទៀត ទោសត្រូវបានគេសំដៅដល់ទណ្ឌកម្មមួយដែលត្រូវបានប្រកាសដោយតុលាការសម្រាប់ធ្វើការអនុវត្តចំពោះបុគ្គលណា ដែលបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ហើយទោសត្រូវបានប្រកាសដោយឈរលើមូលដ្ឋានព្យសនកម្មនៃបទល្មើស ដែលបានបង្កឲ្យមានការខូចខាតដល់ជនរងគ្រោះ ឬសណ្តាប់ធ្នាប់សង្គម។

គោលបំណងនៃទោសមានដូចខាងក្រោម៖[30]

- ជួយរកយុត្តិធម៌ឲ្យជនរងគ្រោះ ឬ អ្នកទទួលរងព្យសនកម្ម
- ការពារសិទ្ធិសេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ជាពិសេសផលប្រយោជន៍សាធារណៈ
- បង្រៀនឲ្យមនុស្សមានការទទួលខុសត្រូវខ្លួនឯង
- ដាក់ទោសទណ្ឌកម្មដល់ជនណាដែលបានល្មើសនឹងច្បាប់ ឲ្យសមទៅនឹងកំហុសទៅលើអំពើដែលខ្លួនបានប្រព្រឹត្ត
- ទប់ស្កាត់ ព្រមានដល់ជនមិនល្អគ្រប់រូប និងបញ្ឈប់ជាបន្ទាន់នូវការប្រព្រឹត្តបទល្មើសទាំងបច្ចុប្បន្ន និងអនាគត
- ជួយផ្តល់នូវចំណេះដឹង ការអប់រំ និងដំបូន្មាន ដែលអាចយកមកប្រើប្រាស់នឹងអនុវត្តដល់ជនល្មើស ឬទណ្ឌិតពេលចូលទៅរស់នៅក្នុងសង្គមវិញ។

## ១.២. នីតិវិធីនៃការអនុវត្តទោស

### ១.២.១. អត្ថន័យនៃការអនុវត្តទោស

ច្បាប់ព្រហ្មទណ្ឌគឺបានកំណត់នូវបទល្មើសជាច្រើនដែលចង្អុលបង្ហាញពី លក្ខណៈសម្បត្តិរបស់បុគ្គលណាមួយដែលអាចត្រូវបានប្រកាសថាជាជនល្មើស និងកំណត់ទោសទៅលើជននោះ ដើម្បីឲ្យជននោះចូលមកទទួលទោសចំពោះបទល្មើសដែលខ្លួនបានប្រព្រឹត្ត។[31] ទោសដែលអាចប្រកាសបាន ទាល់តែមានចែងក្នុងច្បាប់។ តាមគោលការណ៍នីត្យានុកូលភាពនៃបទល្មើសព្រហ្មទណ្ឌ អំពើដែលជាបទល្មើស នៅពេលដែលអំពើនោះមាន

[29] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៦ ។

[30] https://m.facebook.com/permalink.php?story_fbid=1204217719612119&id=1081941058506453&locale2=ar_AR, (ចូលទស្សនាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១)។

[31] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១ (កថាខណ្ឌទី១) ។

ចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន។[32]

**១.២.២. ប្រភេទនៃការអនុវត្តទោស**

ចំពោះការអនុវត្តទោសត្រូវបានបែងចែងទៅតាមប្រភេទ និងស្ថានទម្ងន់នៃបទល្មើស និងទោសនីមួយៗ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌមានដូចជាការអនុវត្តមូលទោស ទោសបន្ថែម និងការអនុវត្តទោសជំនួស។

**១.២.២.១. ការអនុវត្តមូលទោស**

មូលទោស គឺជាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។[33] ចំពោះទោសនេះផងដែរ នៅពេលដែលបទល្មើសមួយត្រូវបានផ្តន្ទាទោសតាមរយៈតុលាការឲ្យជាប់ពន្ធនាគារ ឬពិន័យជាប្រាក់ហើយ នោះច្បាប់នឹងកំរិតទោសនោះទៅជាអប្បបរមា និងអតិបរមានៃមូលទោសនោះ។[34] ការកំរិតអប្បបរមា និងអតិបរមាអាចជួយទណ្ឌិតក្នុងការបន្ថយទោសឲ្យស្រាល ហើយក៏អាចបន្ថែមទម្ងន់ទោសឲ្យកាន់តែខ្លាំង អាស្រ័យទៅតាមលក្ខខណ្ឌនៅក្នុងក្រមព្រហ្មទណ្ឌបានបញ្ញត្តិ។

នៅពេលដែលបុគ្គលណាម្នាក់បានប្រព្រឹត្តបទល្មើសណាមួយហើយ បុគ្គលនោះនឹងត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដែលឆ្លងកាត់នីតិវិធីជាច្រើន រហូតដល់ការប្រកាសឲ្យអនុវត្តមូលទោស។ ចំពោះការប្រកាសមូលទោសរបស់តុលាការអាចធ្វើទៅបានអាស្រ័យទៅលើ ***នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ។***[35]

ជាទូទៅបទល្មើសត្រូវបានចាត់ថ្នាក់ជា បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនោះ។[36] ការកំណត់បទល្មើសទៅតាម បទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ គឺត្រូវពិនិត្យមើលទៅលើការប្រកាសមូលទោសរបស់តុលាការ ដែលទាក់ទងនឹងអតិបរមានៃការដាក់ទោសពន្ធនាគារទៅតាមការកំណត់ដោយច្បាប់ក្នុងក្រមព្រហ្មទណ្ឌ។

បទល្មើសទាំង ៣ប្រភេទដែលក្រមព្រហ្មទណ្ឌកំពុងចូលជាធរមានបានចែងដូចខាងក្រោម៖

- **បទឧក្រិដ្ឋ** គឺទោសដែលជាប់ពន្ធធានាគារលើសពី៥ឆ្នាំ និងក្រោម ឬស្មើ ៣០ឆ្នាំ ហើយអាចជាប់ទោសរហូតដល់មួយជីវិតអាស្រ័យទៅតាមទម្ងន់នៃទោសហើយទោសនេះអាចពិន័យជាប្រាក់ផងដែរ ។[37]

[32] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣ (កថាខណ្ឌទី១) ។

[33] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៣ ។

[34] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៤ (កថាខណ្ឌទី១) ។

[35] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៨។

[36] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២ (កថាខណ្ឌទី២)។

[37] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា៤៦។

ឧទាហរណ៍ ៖ បទឃាតកម្មគិតទុកជាមុន។ ឃាតកម្មគិតទុកជាមុន គឺជាអំពើសម្លាប់មនុស្សដោយគិតទុកជាមុន ឬដោយការពួនស្ទាក់ ដែលជាគម្រោងបង្កើតឡើងមុនអំពើបៀតបៀនទៅលើជនរងគ្រោះ។[38] បទល្មើសនេះត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត។[39]

– **បទមជ្ឈិម** គឺបទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលលើសពី៦ (ប្រាំមួយ) ថ្ងៃ និងក្រោម ឬ ស្មើនឹង ៥(ប្រាំ) ឆ្នាំ។[40] ទោសនេះអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។[41]

ឧទាហរណ៍ ៖ បទហិង្សាដោយចេតនា ។ ជនល្មើសអាចត្រូវទទួល ទោសដាក់ពន្ធនាគារ ពី ១ឆ្នាំ ទៅ ៣ឆ្នាំ និងពិន័យជាប្រាក់ ពី ២ លានរៀលទៅ ៦ លានរៀល[42] នេះគឺជាទោសព្រហ្មទណ្ឌ ដែលត្រូវបង់ទៅឲ្យរដ្ឋ។ ទោះបីមាន ឬក៏គ្មានដើមបណ្តឹងរដ្ឋប្បវេណី ក៏ជនល្មើសត្រូវតែបង់ដែរ។ ចៅក្រមអាចសម្រេចឲ្យជនល្មើសបង់នូវសំណង និងថ្លៃខូចខាតឲ្យទៅជនរងគ្រោះ បន្ថែមពីលើលុយពិន័យបង់ទៅឲ្យរដ្ឋ បើសិនជាជនរងគ្រោះទាមទារសំណងជំងឺចិត្ត។

– **បទលហុ** គឺជាបទល្មើសដែលបែងចែកជាពីរករណី ចំពោះករណីទី១ បើមើលទៅតាមអតិបរមាទោសដាក់ពន្ធនាគារដែលត្រូវរងនោះ មានរយៈពេលក្រោម ឬស្មើនឹង៦ (ប្រាំមួយ) ថ្ងៃ។[43] រីឯករណីទីពីរវិញ បទល្មើសត្រូវផ្តន្ទាទោសត្រឹមតែពិន័យជាប្រាក់តែប៉ុណ្ណោះ។[44]

ឧទាហរណ៍ ៖ បទស្រវឹងជាក់ស្តែង ដែលជនល្មើសអាចត្រូវទទួលទោសដោយពិន័យជាប្រាក់ពី ៥.០០០ (ប្រាំពាន់) រៀលទៅ ១០.០០០ (មួយម៉ឺន) រៀល។[45]

ចំពោះការទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលដែលជាកម្មវត្ថុនៃការទទួលខុសត្រូវមានពីរ គឺរូបវន្តបុគ្គល និងនីតិបុគ្គលចំពោះរូបវន្តបុគ្គលការអនុវត្តមូលទោសទៅលើនីតិជនខុសពីអនីតិជន។

[38] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា២០០ (កថាខណ្ឌទី១ និងកថាខណ្ឌទី២)។
[39] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២០០ (កថាខណ្ឌទី៤)។
[40] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៧ (កថាខណ្ឌទី១)។
[41] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៧ (កថាខណ្ឌទី២)។
[42] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២១៧។
[43] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៨ (កថាខណ្ឌទី១)។
[44] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៨ (កថាខណ្ឌទី២)។
[45] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៩៧។

ដោយទ្បែកអនីតិជនក្រោម អាយុ១៨ឆ្នាំ មិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

### ១.២.២.១.១. ការអនុវត្តមូលទោសចំពោះនីតិជន

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨(ដប់ប្រាំបី) ឆ្នាំឡើងទៅ។[46] ជាគោលការណ៍ មូលទោសអាចអនុវត្តទៅបាននៅពេលដែលមានការប្រកាសមូលទោសចំពោះជនជាប់ចោទ ដែលបានប្រព្រឹត្តល្មើសនឹងច្បាប់ ហើយគ្រប់ករណីដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារផង និង ពិន័យផង តុលាការអាចប្រកាស៖[47]

- ទោសដាក់ពន្ធនាគារផង និងពិន័យជាមួយគ្នា
- ឬ ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ
- ឬ ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

ម្យ៉ាងទៀត បើគិតទៅតាមបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុវិញ នីតិជនដែលបានប្រព្រឹត្តល្មើសនឹង ច្បាប់ដែលនាំឲ្យមានផលប៉ះពាល់ដល់សង្គមសាធារណៈវិញមានដូចខាងក្រោម ៖

- **មូលទោសចំពោះនីតិជនទៅលើបទឧក្រិដ្ឋ ៖**

នីតិជនត្រូវអនុវត្តទោសដាក់ពន្ធនាគារលើសពី ៥ឆ្នាំ និងក្រោមឬស្មើនឹង ៣០ឆ្នាំ។[48] ក្នុងនោះជននោះ អាចជាប់ពន្ធនាគារអស់មួយជីវិតផងដែរ អាស្រ័យទៅលើអតិបរមានៃទោសដែលខ្លួនបានប្រព្រឹត្ត[49] ក្រៅពីទោស ពន្ធនាគារ ជននោះត្រូវផ្តន្ទាទោសពិន័យជាប្រាក់ទៅតាមអប្បរមា ឬអតិបរមានៃមូលទោសរបស់ខ្លួន។ ប្រាក់ពិន័យ ត្រូវបង់ជាប្រាក់រៀល ហើយប្រាក់ពិន័យដែលទទួលបានត្រូវបង់ចូលថវិការដ្ឋ។[50]ការកំណត់ប្រភេទគតិយុត្តនៃបទ ល្មើសទាំងនេះត្រូវបានកំណត់ដោយប្រភេទ និងថិរវេលានៃទោសដែលត្រូវទទួលរងជានិច្ច។

- **មូលទោសចំពោះនីតិជនទៅលើបទមជ្ឈិម ៖**

នីតិជនដែលបានប្រព្រឹត្តបទល្មើសជាបទមជ្ឈិម នៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវរងនោះ មានរយៈពេលលើសពី ០៦ថ្ងៃ និងក្រោម ឬស្មើនឹង ០៥ ឆ្នាំ។[51] នីតិជនអាចជាប់ពន្ធនាគារលើស ពី ០៦ថ្ងៃ និងក្រោម ឬស្មើ ០៥ ឆ្នាំអាស្រ័យទៅតាមការវិនិច្ឆ័យរបស់តុលាការ និងអាស្រ័យទៅតាមកម្រិតបទ ល្មើសដែលខ្លួនបានប្រព្រឹត្ត។ ជាការពិតណាស់ទោសជាប់ពន្ធនាគារអាចប្រកាសជាមួយនឹងទោសពិន័យផងដែរ

[46] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៨។
[47] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៧។
[48] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៦ (កថាខណ្ឌទី២)។
[49] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៦ (កថាខណ្ឌទី១)។
[50] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥២។
[51] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៧ (កថាខណ្ឌទី១)។

ដូច្នេះនីតិជនត្រូវបានផ្តន្ទាទោសបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ[52] អាស្រ័យទៅតាមការស្នើសុំរបស់ជនរងគ្រោះ ឬសេចក្តីសម្រេចរបស់តុលាការ។

– **មូលទោសចំពោះនីតិជនទៅលើបទលហុ ៖**

នីតិជនដែលបានប្រព្រឹត្តបទល្មើសជាបទលហុ គឺអាចដាក់ទោសពន្ធនាគាររយៈពេលក្រោម ឬស្មើនឹង ០៦ថ្ងៃអាស្រ័យទៅតាមអតិបរមានៃទោសដែលខ្លួនបានប្រព្រឹត្ត។[53] ក្នុងនោះតុលាការអាចប្រកាសឲ្យជនល្មើសជាប់ពន្ធនាគារ និងផ្តន្ទាទោសបន្ថែមដោយពិន័យជាប្រាក់ផងដែរ។ ជួនកាលជននោះត្រូវបានផ្តន្ទាទោសឲ្យទទួលត្រឹមតែទោសពិន័យតែប៉ុណ្ណោះ អាស្រ័យទៅតាមការយល់ឃើញរបស់តុលាការ។[54]

ដូច្នេះហើយ មូលទោសនៃបទល្មើសទាំងបីខាងលើនេះ គឺត្រូវធ្វើឡើងយ៉ាងច្រើនដំណាក់កាល ដើម្បីធ្វើការកំណត់នូវចរិតលក្ខណៈ និងប្រភេទគតិយុត្តនៃបទល្មើសនីមួយៗ ដោយយោងទៅតាមក្រមព្រហ្មទណ្ឌ ប្រភេទ និងថិរវេលានៃទោសដែលត្រូវបានទទួលរង។

### ១.២.២.១.២. ការអនុវត្តទោសទូទៅចំពោះអនីតិជន

អនីតិជន គឺសំដៅទៅលើជនដែលមានអាយុក្រោម ១៨ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស ហើយត្រូវបានគេយល់ឃើញថាជាជនខ្វះខាតនូវសមត្ថភាពចំណេះដឹងផ្នែកប្រាជ្ញា និងស្មារតីក្នុងការធ្វើអ្វីមួយដោយខ្លួនឯង។[55] នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាក៏បានកំណត់ថា ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌអាចធ្វើឡើងបាន លុះត្រាតែមាន អាយុចាប់ពី១៨ឆ្នាំឡើងទៅ។ យោងតាមគោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌ នៅពេលដែលមានបទល្មើសកើតឡើង ទោះបីអំពើនោះប្រព្រឹត្តឡើងដោយចេតនា ឬអចេតនាក្តី ក៏វាបណ្តាលឲ្យមានព្យសនកម្មដល់បុគ្គលដទៃទៀត ដែលនេះហើយធ្វើឲ្យមានការចេញនូវលក្ខខណ្ឌចម្បងអំពីការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនេះ។

វិធានការអនុវត្តទោសចំពោះអនីតិជនដែលប្រព្រឹត្តបទល្មើស ជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ[56] ដោយហេតុថាក្នុងករណីដែលមានអនីតិជនអាយុក្រោម ១៨ ឆ្នាំ បានប្រព្រឹត្តបទល្មើសដែលមានស្ថានទម្ងន់ទោសធ្ងន់ធ្ងរណាមួយ ហើយនាំឲ្យមានផលពិបាក និងប៉ះពាល់ខ្លាំងទៅលើសង្គម។ ក៏ប៉ុន្តែមានបញ្ញត្តិបន្ថែមថាតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់

[52] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៧ (កថាខណ្ឌទី៣)។

[53] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៨ (កថាខណ្ឌទី១)។

[54] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤៨ (កថាខណ្ឌទី២)។

[55] ច្បាប់ស្តីពីយុត្តិធម៌អនីតិជន, លេខ នស/រកម/០៧១៦/០០៩, ៣០ ឧសភា ២០១៦, មាត្រា ៤ (កថាខណ្ឌទី៣)។

[56] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩ (កថាខណ្ឌទី១)។

អនីតិជនតម្រូវ។[57] ដូច្នេះមានន័យថាអនីតិជនដែលមានអាយុ ១៤ ឆ្នាំដល់ក្រោម១៨ ឆ្នាំ អាចទទួលខុសត្រូវទោសព្រហ្មទណ្ឌចំពោះអំពើរបស់ខ្លួនដែលបានប្រព្រឹត្ត ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវឲ្យទទួលខុសត្រូវ។

ចំពោះពាក្យថាកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន មិនបានកំណត់ឲ្យបានច្បាស់លាស់នៅក្នុងក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឡើយ ដូចនេះហើយនៅពេលជួបប្រទះនូវករណីណាមួយដែលច្បាប់បានផ្តល់សិទ្ធិពិសេសដល់តុលាការ ដែលគេហៅបានថាជាឆន្ទានុសិទ្ធិក្នុងការគិតពិចារណាទៅលើទង្វើរបស់អនីតិជនដែលបានប្រព្រឹត្តអំពើល្មើសនឹងច្បាប់ថាគួរមានទោសឬអត់ ហើយគួរតែយកទោសណាមកអនុវត្តលើជននោះដើម្បីឲ្យមានភាពសុក្រិត។[58]

ជាទូទៅរាល់អនីតិជន ដែលបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងច្បាប់ព្រហ្មទណ្ឌ ហើយមានអាយុចាប់ពី១៤ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ តុលាការអាចសម្រេចដាក់ត្រឹមតែវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភតែប៉ុណ្ណោះ ដែលមានដូចខាងក្រោម៖[59]

១. ការប្រគល់អនីតិជនឲ្យទៅឪពុកម្តាយអាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសាកសមនឹងទំនុកចិត្ត។

២. ការប្រគល់អនីតិជនឲ្យទៅសេវាសាធារណៈ ដែលសម្រាប់ទទួលបន្ទុកអនីតិជន។

៣. ការប្រគល់អនីតិជនឲ្យទៅអង្គការឯកជន ដែលមាននីតិសម្បទានៅក្នុងការទទួលអនីតិជន។

៤. ការប្រគល់អនីតិជនឲ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកជន។

៥. ការដាក់អនីតិជន ឲ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ម្យ៉ាងទៀត តុលាការត្រូវចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈកិច្ចធ្វើការតាមដានអនីតិជន។ បុគ្គលនោះត្រូវធ្វើរបាយការណ៍ស្តីពីកិរិយាមារយាទរបស់អនីតិជនឲ្យបានទៀងទាត់ដល់ព្រះរាជអាជ្ញា។ បុគ្គលនោះផ្តល់ព័ត៌មានដល់ព្រះរាជអាជ្ញាអំពីព្រឹត្តិការណ៍ទាំងអស់ ដែលអាចនាំឲ្យមានការកែប្រែនូវវិធានការនេះ។[60]

ផ្ទុយទៅវិញប្រសិនបើតុលាការយល់ឃើញថា កាលៈទេសៈរបស់បទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជន តម្រូវឲ្យអនីតិជនទទួលខុសត្រូវព្រហ្មទណ្ឌ នោះការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជនក៏នៅតែមិនអាចស្ថិតនៅលើគោលការណ៍ស្មើភាពដូចនីតិជនដែរ។[61] ចំពោះករណីនេះ អនីតិជនមានរបបករណីពិសេសមួយ

[57] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៣៩ (កថាខណ្ឌទី២)។

[58] យល់ដឹងផ្នែកច្បាប់ ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន រៀបរៀងដោយ លោកមេធាវី សេង ឈុនលី និងលោក ឡេង ពុទ្ធិតារា ជាសមាជិកក្រុមការងាររៀបចំ និងផ្សព្វផ្សាយអត្ថបទច្បាប់ នៃក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ។

[59] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤០។

[60] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៤១។

[61] នាទីច្បាប់ , ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន , អត្ថបទដោយកញ្ញា អ៊ុំ ច័ន្ទលក្ខិណា , ចុះថ្ងៃអង្គារ ទី១០ ខែមីនា ឆ្នាំ២០២០។

ដែលមានលក្ខណៈដាច់ដោយឡែកពីនីតិជន ដែលរបបពិសេសនៃទោសនោះត្រូវបានចែងក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ ចាប់ពីមាត្រា ១៦០ ដល់មាត្រា ១៦៦ ។ ក្នុងនោះគេសង្កេតឃើញថាទោសដែលត្រូវយកមកអនុវត្តលើអនីតិជន អាចមានភាពប្រែប្រួលទៅតាមបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះ។ ម្យ៉ាងទៀតការប្រែប្រួលទាំងនោះអាចបណ្តាលមកពីបរិស្ថាន សង្គម ឬការវិវត្តរបស់ជនល្មើសខ្លួនឯងផ្ទាល់ ដែលបានបង្កឲ្យមានឧក្រិដ្ឋកម្មផ្សេងៗ។

### ១.២.២.១.៣. ការអនុវត្តមូលទោសចំពោះអនីតិជន

ក្នុងករណីនេះ អនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំដល់ក្រោម ១៨ ឆ្នាំ ហើយជននោះបានប្រព្រឹត្តបទល្មើសណាមួយដូចដែលមានចែងក្នុងបទប្បញ្ញត្តិនៃច្បាប់ នោះតុលាការត្រូវពិនិត្យ និងធ្វើការពិចារណាទៅលើកាលៈទេសៈនៃបទល្មើស និងបុគ្គលិកលក្ខណៈរបស់អនីតិជននោះជាមុនសិន។ ប្រសិនបើតុលាការបានពិនិត្យឃើញថាមានបុគ្គលិកលក្ខណៈដែលបានតម្រូវគ្រប់គ្រាន់ហើយនោះ តុលាការនឹងប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជននោះដោយយោងតាមឆន្ទានុសិទ្ធិរបស់ខ្លួន។ ដូច្នេះ តុលាការនឹងប្រកាសអំពីទណ្ឌកម្មព្រហ្មទណ្ឌទាំងនោះ។[62] ចំពោះការសម្រេចដាក់ទោសទៅលើអនីតិជនណាមួយ តុលាការបានធ្វើការពិនិត្យយ៉ាងដិតដល់រហូតដល់ដំណាក់កាលចុងក្រោយ មុននឹងសម្រេចកាត់ទោសទៅលើជននោះ។

ការសម្រេចដាក់ទោសទៅលើអនីតិជន គឺអាចស្ថិតក្នុងស្ថានភាពនៃការប្រព្រឹត្តបទល្មើសរបស់អនីតិជននោះដោយការប្រព្រឹត្តបទល្មើសនោះមានលក្ខណៈសាហាវឃោរឃៅខ្លាំង ឬមានការប៉ះពាល់ធ្ងន់ធ្ងរដល់សង្គម និងអាយុជីវិតអ្នកដទៃ។ គួរបញ្ជាក់ផងដែរថាទោសរបស់អនីតិជនស្មើនឹងពាក់កណ្តាលនៃមនុស្សពេញវ័យ។

ឧទាហរណ៍ ៖ ប្រសិនបើអនីតិជនបានប្រព្រឹត្តនូវបទល្មើសរំលោភសេពសន្ថវៈ ហើយបទល្មើសនេះត្រូវបានកំណត់ឲ្យមានការផ្តន្ទាទោសដាក់ពន្ធនាគារពី៥ (ប្រាំ) ឆ្នាំ ទៅ១០ (ដប់) ឆ្នាំ។[63] ក្នុងករណីដែលធាតុផ្សំនៃបទល្មើសត្រូវបានបំពេញគ្រប់តាមលក្ខខណ្ឌដែលមានចែងក្នុងបទល្មើសខាងលើរួចហើយ តុលាការបានសម្រេចប្រកាសផ្តន្ទាទោសជនជាប់ចោទដែលជា អនីតិជននោះឲ្យជាប់ពន្ធនាគាររយៈពេល ៨ឆ្នាំ។ យ៉ាងណាមិញ ផ្អែកទៅលើគោលការណ៍ឯកត្តកម្មនៃទោសដោយបុគ្គលិកលក្ខណៈនៃជនជាប់ចោទជាអនីតិជន បានសេចក្តីថាទោសដែលបានប្រកាសនោះនឹងត្រូវបន្ថយចុះពាក់កណ្តាល ពោលគឺជនជាប់ចោទនឹងត្រូវទទួលរងនូវការផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៤ ឆ្នាំ តែប៉ុណ្ណោះ។

ម្យ៉ាងវិញទៀតកាលណាតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅមូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ ៖[64]

[62] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦០។

[63] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ២៣៩ (កថាខណ្ឌទី២) ។

[64] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦០។

- អតិបរមានៃទោសដាក់ពន្ធនាគារពាក់កណ្តាល។
- ប្រសិនបើអតិបរមានៃទោសនោះគឺជាទោសដាក់ពន្ធនាគារអស់មួយជីវិតអតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ។
- អប្បបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាលប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ។
- អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល។ ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមានអានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមចិរវេលាមួយស្មើ ឬតិចជាង៥ ឆ្នាំនោះ បទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល។

ក្រៅពីទោសដែលជាមូលដ្ឋាន តុលាការក៏អាចធ្វើការសម្រេចពិចារណាអំពីទោសបន្ថែម ដែលអាចប្រកាសចំពោះទណ្ឌិតដែលជាអនីតិជននោះបានថែមទៀតផង។

#### ១.២.២.២. ការអនុវត្តទោសបន្ថែម

ចំពោះទោសបន្ថែម គឺត្រូវធ្វើឡើងបន្ថែមលើមូលទោស ប៉ុន្តែពុំមែនធ្វើឡើងដោយស្វ័យប្រវត្តិនោះទេ។ ទោសបន្ថែមត្រូវបានធ្វើការបន្ថែមលើមូលទោស ក្នុងករណីដែលទោសបន្ថែមនោះ ត្រូវបានប្រកាសយ៉ាងច្បាស់លាស់ដោយចៅក្រម ។ នៅក្នុងក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ បានរាយជាបញ្ជីទោសបន្ថែមជាច្រើន ដែលអាចអនុវត្តចំពោះរូបវន្តបុគ្គល ដើម្បីអនុញ្ញាតឲ្យមានឯកត្តកម្មដ៏ប្រសើរមួយ និងមានការសម្របទៅនឹងប្រភេទនៃបទល្មើស និងស្ថានភាពផ្ទាល់ខ្លួនរបស់ចារីផងដែរ។

ទោសបន្ថែមអាចជាការដកសិទ្ធិពលរដ្ឋខ្លះដូចជា៖[65]

¤ ការដកសិទ្ធិបោះឆ្នោត

¤ សិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត

¤ សិទ្ធិបំពេញការងារជាមន្ត្រីក្របខ័ណ្ឌមុខងារសាធារណៈ

¤ សិទ្ធិទទួលការចាត់តាំងជាអ្នកជំនាញ ជាអាជ្ញាកណ្តាល ឬជាអាណត្តិគាហករបស់តុលាការ

¤ សិទ្ធិទទួល និងពាក់គ្រឿងឥស្សរិយយសទាំងអស់

¤ សិទ្ធិធ្វើជាសាក្សី ដែលទទួលសម្បថនៅមុខតុលាការជាដើម។

ទោសបន្ថែមក៏អាចជា ការរឹបអូសឧបករណ៍ដែលប្រើប្រាស់ក្នុងការប្រព្រឹត្តបទល្មើស ឬការរឹបអូសទ្រព្យសម្បត្តិដែលបានមកពីការប្រព្រឹត្តនូវបទល្មើសឬការហាមមិនឲ្យចាកចេញ ឬចូលមកក្នុងប្រទេសកម្ពុជា ប្រសិនបើ

[65] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៥។

ជនល្មើសជាជនបរទេស។[66] ការប្រកាសទោសបន្ថែម អាចអនុវត្តបានលុះត្រាតែទោសនោះត្រូវបានចែងដោយច្បាស់ លាស់ចំពោះបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ដែលត្រូវបានចោទប្រកាន់។[67] ទោសបន្ថែមអាចប្រកាសក៏បាន មិនប្រកាសក៏បាន[68] ប៉ុន្តែប្រសិនបើច្បាប់បានចែងយ៉ាងជាក់លាក់ នោះទោសបន្ថែមត្រូវបានចៅក្រមយកមកប្រកាសជាដាច់ខាត ព្រោះវាជាកាតព្វកិច្ចរបស់តុលាការមិនអាចមិនប្រកាសបាននោះទេ។

ការប្រកាសទោសបន្ថែមពុំមានលក្ខណៈដាច់ខាតនោះទេ គ្រាន់តែតុលាការត្រូវយកទោសបន្ថែមដែលមានយកមកថ្លឹងថ្លែង ពិចារណាជាមុនសិន មុននឹងសម្រេចថាប្រកាស ឬមិនប្រកាសទោស ព្រោះដើម្បីឲ្យទម្ងន់នៃបទល្មើសមានភាពសមស្របទៅនឹងកាលៈទេសៈដែលពាក់ពន្ធនឹងបទល្មើស។

### ១.២.២.២.១. ការអនុវត្តទោសបន្ថែមចំពោះនីតិជន

ម្យ៉ាងវិញទៀតចំពោះនីតិជន ទោសបន្ថែមនេះត្រូវបានតុលាការបង្គាប់ឲ្យរៀបចំកែប្រែ ឬលុបចោលនូវទោសណាមួយ ឬច្រើនពេលណាក៏បាន អាស្រ័យទៅតាមលក្ខខណ្ឌមួយចំនួនដូចជា៖[69]

- នៅពេលដែលបទល្មើសត្រូវបានបញ្ឈប់ ហើយលែងបង្កឲ្យមានភាពច្របូកច្របល់ដល់សណ្ដាប់ធ្នាប់ក្នុងសង្គម។
- ព្យសនកម្មត្រូវបានសងការខូចខាត និងជួសជុលឡើងវិញ។
- សេចក្តីសម្រេចរៀបចំការកែប្រែ ឬលុបចោលមានលក្ខណៈអនុគ្រោះដល់ជនល្មើសដោយបញ្ជូនជននោះទៅរស់នៅក្នុងសង្គមសាជាថ្មី។

តុលាការទទួលបានពាក្យប្តឹងពីអយ្យការតាមគំនិតផ្តួចផ្តើមរបស់ខ្លួនផ្ទាល់ ឬតាមពាក្យប្តឹងរបស់ទណ្ឌិត បន្ទាប់មកតុលាការនឹងប្រកាសនូវសេចក្តីសម្រេច នៅពេលបើកសវនាការជាសាធារណៈក្រោយពីបានស្តាប់យោបល់របស់តំណាងអយ្យការ ទណ្ឌិត និងមេធាវីរបស់ទណ្ឌិតនោះ។

### ១.២.២.២.២. ការអនុវត្តទោសបន្ថែមចំពោះអនីតិជន

ទោសបន្ថែម គឺសំដៅលើទោសមួយប្រភេទ ដែលតម្រូវឲ្យបន្ថែមទៅលើមូលទោស។[70] ទោសបន្ថែមដែលអាចយកទៅអនុវត្តលើអនីតិជនបានមានខាងក្រោម ៖[71]

- ការរឹបអូសឧបករណ៍សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅប្រព្រឹត្ត

[66] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៣។

[67] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៤ (កថាខណ្ឌទី១)។

[68] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៤ (កថាខណ្ឌទី២)។

[69] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៥២។

[70] នីតិព្រហ្មទណ្ឌទូទៅ, រៀបរៀងដោយ សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ, ទំព័រ ៣០៦។

[71] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៥១។

បទល្មើស។

- ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស។
- ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាកើតចេញពីបទល្មើស។
- ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទៅកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត។
- ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ។

ទោសបន្ថែមទាំងនេះអាចយកមកអនុវត្តបានទៅលើអនីតិជន ប៉ុន្តែវាគ្រាន់តែជាវិធានការមួយដែលមានវត្ថុបំណងក្នុងការអប់រំជាជាងការបង្រ្កាប។ ទោសបន្ថែមនេះធ្វើឡើងដោយមានការពិនិត្យ ពិចារណាទៅលើស្ថានភាព និងកាលៈទេសៈនៃការប្រព្រឹត្តបទល្មើសរបស់ចៅក្រមជំនុំជម្រះមុននឹងសម្រេចផ្តន្ទាទោស ដើម្បីជៀសវាងការអនុវត្តទោសដែលជាមូលដ្ឋាន ឬមានផលប៉ះពាល់ផ្សេងៗដល់អនីតិជនដែលជាទណ្ឌិត។ ក្នុងនោះដោយផ្អែកទៅលើគោលការណ៍មនុស្សធម៌ ចៅក្រមអាចយកទោសការងារសហគមន៍មកអនុវត្តចំពោះអនីតិជនវិញ។

### ១.២.២.៣. ការអនុវត្តទោសជំនួស

ទោសជំនួស គឺជាទោសដែលអនុញ្ញាតឲ្យចៅក្រមលើកយកមកពិចារណានៅក្នុងការជ្រើសរើសចំពោះទណ្ឌកម្មនូវកាលៈទេសៈយ៉ាងច្រើនបំផុតតាមលទ្ធភាពដែលអាចធ្វើបានដោយទាក់ទងទៅនឹងអំពើ ព្រមទាំងបុគ្គលិកលក្ខណៈរបស់ទណ្ឌិតនោះ។ ចៅក្រមមានសិទ្ធិក្នុងការប្រើប្រាស់ទោសនេះជំនួសឲ្យមូលទោសដោយចៅក្រមមិនចាំបាច់ប្រកាសនូវមូលទោស (ទោសដាក់ពន្ធនាគារ ឬទោសពិន័យជាប្រាក់) ក៏បានព្រោះគាត់បានប្រកាសទោសជំនួសនេះជំនួសឲ្យមូលទោសតែម្តង។[72]

ជាក់ស្តែងទោសជំនួស គឺសម្រេចដោយតុលាការហើយតុលាការតម្រូវឲ្យជនជាប់ចោទនោះ បំពេញការងារក្នុងចិរវេលាចន្លោះពី៣០ (សាមសិប) ម៉ោងទៅ២០០ (ពីររយ) ម៉ោងដោយមិនទទួលបានប្រាក់កម្រៃនោះទេ។[73] ចំពោះនីតិជន និងអនីតិជន ទោសជំនួសត្រូវបានបែងចែកជាពីរដូចគ្នាគឺ ទោសការងារសហគមន៍ និងការស្តីបន្ទោស។

#### ១.២.២.៣.១. ការអនុវត្តទោសការងារសហគមន៍ចំពោះនីតិជន

ជនដែលត្រូវអនុវត្តទោសនេះ គឺតម្រូវឲ្យជននោះបំពេញការងារក្នុងចិរវេលាចន្លោះពី ៣០ (សាមសិប) ម៉ោងទៅ២០០ (ពីររយ) ម៉ោង ដោយមិនទទួលបានប្រាក់កម្រៃនោះទេ ព្រោះការងារនេះគឺបានជួយជាប្រយោជន៍ជាច្រើនដល់សង្គមទាំងមូល ជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬជាប្រយោជន៍ចំពោះនីតិបុគ្គលនៃ

---

[72] យោងតាមប្រសាសន៍របស់ **ឯកឧត្តម កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌនៅក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តី ក្រមព្រហ្មទណ្ឌ ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា ឆ្នាំ២០១០។

[73] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ (កថាខណ្ឌទី២)។

នីតិសាធារណៈផ្សេងៗ ទៀតដល់សមាគម ឬដល់អង្គការមិនមែនជារដ្ឋាភិបាល។[74]

ជាក់ស្តែងការងារសហគមន៍នេះអាចប្រែប្រួលរយៈពេលម៉ោងធ្វើការងារចាប់ពី៣០ (សាមសិប)ម៉ោង ទៅ ២០០ (ពីររយ) ម៉ោងអាស្រ័យទៅតាមការងារនីមួយៗ ដែលជននោះត្រូវបានគេចាត់ចែងឲ្យធ្វើ។ តុលាការមិនបានប្រកាសពីមូលទោសទេ ក៏ប៉ុន្តែលោកអាចប្រកាសអំពីទោសជំនួសស្តីពីការងារសហគមន៍ ប្រសិនបើជននោះមានវត្តមាននៅក្នុងសវនាការ ពេលតុលាការកំពុងប្រកាសសេចក្តីសម្រេចនោះ ហើយជននោះបានយល់ព្រមទទួលយកនូវការងារសហគមន៍ នោះដោយមិនមានការតវ៉ាប្រឆាំងនឹងសេចក្តីសម្រេចនោះ។[75] បន្ទាប់មកតុលាការនឹងប្រកាសទោសការងារសហគមន៍ដោយកំណត់អំពីរយៈពេលនៃការងារនោះ ដូចជារយៈពេល ៥០ (ហាសិប) ម៉ោងដើម្បីទុកជាប្រយោជន៍សាធារណៈមួយដល់ជននោះ ដើម្បីឲ្យជននោះយកទៅអនុវត្ត។[76]

លើសពីនេះទៅទៀត នៅពេលដែលតុលាការប្រកាសទោសការងារសហគមន៍នោះ រួចព្រះរាជអាជ្ញានឹងចង្អុលបង្ហាញអំពីនីតិបុគ្គលរូបណាដែលទទួលប្រយោជន៍ការងារសហគមន៍នោះ ហើយព្រះរាជអាជ្ញានឹងសម្រេចឲ្យជននោះធ្វើការងារមួយចំនួនដូចជា បោសសំរាមនៅសាលារាជធានីភ្នំពេញ ឬជួយដល់ការងារកាកបាទក្រហមជាដើម ដោយការងារទាំងនេះត្រូវស្ថិត ក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញា។[77] ការងារសហគមន៍នេះត្រូវបានរៀបចំដោយព្រះរាជអាជ្ញា[78] ដែលមានតួនាទីក្នុងការកំណត់រយៈពេលណាមួយដល់ជនជាប់ចោទក្នុងការអនុវត្តការងារដែលតុលាការបានផ្តល់ឲ្យអនុវត្ត។ ប៉ុន្តែការងារនេះព្រះរាជអាជ្ញាមិនមែនចេះតែដាក់ពេលវេលាឲ្យជននោះធ្វើឥតឈប់ឈរនោះទេ ព្រះរាជអាជ្ញានឹងកំណត់រយៈពេលដែលសមស្របដល់ជននោះក្នុងការបំពេញការងាររបស់ខ្លួន ព្រោះជនទាំងនោះត្រូវទុកពេលវេលាខ្លះ ក្នុងការរកស៊ីនៅកន្លែងផ្សេងទៀតដើម្បីចិញ្ចឹមជីវិតរបស់ខ្លួនគាត់ និងចិញ្ចឹមជីវិតរបស់គ្រួសារពួកគាត់ផងដែរ។[79]

ដូច្នេះ ការងារសហគមន៍នេះនៅតែជាប្រយោជន៍ដល់រដ្ឋ ព្រោះរដ្ឋមិនបានបាត់បង់សមាជិករបស់ខ្លួនក្នុងការជួយបំពេញការងារទាំងនេះ ហើយចំពោះការចំណាយរបស់រដ្ឋក៏ត្រូវបានកាត់បន្ថយមានដូចជាការចំណាយទៅលើការចិញ្ចឹមថែរក្សា (ពេលឈឺត្រូវយកទៅមន្ទីរពេទ្យ) សល់កន្លែងនៅក្នុងគុក (ដោយមិនចាំបាច់សាងសង់បន្ថែម) និងមិនមានការចំណាយទៅលើមនុស្សផ្សេងៗ ក្នុងការគ្រប់គ្រងជនទាំងនោះ។[80] កត្តាមួយទៀតគឺជននោះមានសិទ្ធិចេញមកខាងក្រៅពន្ធនាគារ ដើម្បីធ្វើការរកស៊ី ដែលបានរួមចំណែកក្នុងការជួយដល់គ្រួសារ

---

[74] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ (កថាខណ្ឌទី២)។

[75] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០១។

[76] ក្រមព្រហ្មទណ្ឌ, រៀបរៀង និងវាយអត្ថបទដោយ កៅសីហា, ទោសព្រហ្មទណ្ឌ, ទំព័រ ១០៧។

[77] ក្រមព្រហ្មទណ្ឌ, រៀបរៀង និងវាយអត្ថបទដោយ កៅសីហា, ទោសព្រហ្មទណ្ឌ, ទំព័រ ១០៨។

[78] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៣។

[79] ក្រមព្រហ្មទណ្ឌ, រៀបរៀង និងវាយអត្ថបទដោយ កៅសីហា, ទោសព្រហ្មទណ្ឌ, ទំព័រ ១០៧។

[80] ក្រមព្រហ្មទណ្ឌ, រៀបរៀង និងវាយអត្ថបទដោយ កៅសីហា, ទោសព្រហ្មទណ្ឌ, ទំព័រ ១០៧។

របស់ពួកគេដែលកំពុងតែជួបការលំបាកក្នុងការរកប្រាក់ចំណូលប្រចាំថ្ងៃ ហើយចំពោះការងារទាំងនោះគឺមិនមានផលប៉ះពាល់ដល់រដ្ឋនោះទេ។[81] ជាពិសេសនៅពេលដែលជននោះយល់ព្រមទទួលធ្វើការងារទាំងនោះតាមធម្មតាមនុស្ស បែបនេះ គឺងាយអប់រំកែប្រែគាត់ខ្លាំងណាស់។[82]

**ចំណាំ** ៖ ការងារសហគមន៍នេះ មិនអាចបំពេញជាប្រយោជន៍នៃរូបវន្តបុគ្គលនោះទេ[83] ម្យ៉ាងវិញទៀត បុគ្គលឯកជនក៏មិនអាចយកជនដែលធ្វើការងារនេះទៅបម្រើផលប្រយោជន៍របស់ខ្លួននោះទេ ព្រោះច្បាប់បានចែងអំពីការហាមមិនឲ្យមានករណីទាំងនេះកើតមានឡើង។

### ១.២.២.៣.២. ការអនុវត្តការស្តីបន្ទោសចំពោះនីតិជន

ការស្តីបន្ទោស គឺជាប្រភេទទោសដែលប្រើប្រាស់ទៅលើបទល្មើសស្រាល ហើយចៅក្រមសម្រេចមិនប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់នោះទេ ប៉ុន្តែចៅក្រមធ្វើការព្រមាន ប្រដៅអប់រំទៅជនដែលបានប្រព្រឹត្តល្មើសនឹងច្បាប់នោះឲ្យចេះកែប្រែ និងចេះគិតពិចារណាទទួលស្គាល់ពីកំហុសរបស់ខ្លួន ហើយសន្យាថានឹងឈប់ប្រព្រឹត្តបទល្មើសតទៅទៀត។[84]

ទោសនេះភាគច្រើនតុលាការប្រើប្រាស់ទៅលើកុមារ ឬអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំឡើងដល់ក្រោម១៨ឆ្នាំ ព្រោះគេយល់ឃើញថាកុមារ ឬអនីតិជន គឺជាជនដែលមិនសូវមានការគិតពិចារណាបានវែងឆ្ងាយដូចមនុស្សចាស់ឡើយ។[85] ការអនុវត្តទោសនេះចំពោះអនីតិជន គឺជាឆន្ទានុសិទ្ធិរបស់ចៅក្រម ប៉ុន្តែចៅក្រមត្រូវបញ្ជាក់ប្រាប់ដល់ជននោះថានឹងមិនមានការអនុគ្រោះទោសណាមួយទៀតទេ ប្រសិនបើជននោះនៅតែប្រព្រឹត្តអំពើមិនល្អដែលនាំឲ្យប៉ះពាល់ដល់សង្គម និងអ្នកដទៃ។

ខ្លឹមសារផ្សេងៗ ដែលនាំឲ្យមានផលអវិជ្ជមាន ទាក់ទងទៅនឹងការស្តីបន្ទោស៖[86]

- ទោសជំនួសខ្លះមានកម្មវត្ថុជាការដកហូតនូវសេរីភាពដើរហើរពីទណ្ឌិត ឬគ្រាន់តែកម្រិតនូវសេរីភាពជាមូលដ្ឋានរបស់ទណ្ឌិតតែប៉ុណ្ណោះ។
- ទោសខ្លះប៉ះពាល់ដល់បេតិកភណ្ឌរបស់ទណ្ឌិត។

---

[81] ក្រមព្រហ្មទណ្ឌ, រៀបរៀង និងវាយអត្ថបទដោយ កៅសីហា, ទោសព្រហ្មទណ្ឌ, ទំព័រ ១០៨។

[82] យោងតាមប្រសាសន៍របស់ **ឯកឧត្តម ហ៊ី សោភា** រដ្ឋលេខាធិការលំដាប់ថ្នាក់ទីមួយនៃក្រសួងយុត្តិធម៌ស្តីពីប្រភេទនៃទោស ចុះថ្ងៃទី ១៨ ខែសីហា ឆ្នាំ ២០១០។

[83] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧៣។

[84] យោងតាមប្រសាសន៍របស់ **ឯកឧត្តម កើត រិទ្ធ** អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌនៅ ក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ស្តីក្រមព្រហ្មទណ្ឌ ដែលរៀបចំឡើងដោយក្រសួងយុត្តិធម៌សហការជាមួយនឹងក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជាឆ្នាំ២០១០។

[85] ទោសព្រហ្មទណ្ឌ, រៀបរៀង និងវាយអត្ថបទដោយៈ កៅ សីហា បេក្ខបណ្ឌិតច្បាប់ និងជាសាស្ត្រាចារ្យច្បាប់, ទំព័រ ១១១។

[86] លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ កែសម្រួលដោយលោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត, នីតិព្រហ្មទណ្ឌទូទៅ, ឆ្នាំ២០១២, ទំព័រ ៣៣៤។

- ទោសខ្លះទៀតបានបង្ខំឲ្យទណ្ឌិតធ្វើអំពើអ្វីមួយ។
- ទោសខ្លះធ្វើឲ្យមានផលប៉ះពាល់ដល់សិទ្ធិមួយចំនួនរបស់ទណ្ឌិត។
- ទោសខ្លះបង្កឲ្យមានផលប៉ះពាល់ដល់កិត្តិយសរបស់ទណ្ឌិត។

### ១.២.២.៣.៣. ការអនុវត្តទោសសហគមន៍ចំពោះអនីតិជន

ទោសការងារសហគមន៍ជាកាតព្វកិច្ចដែលត្រូវបំពេញក្នុងចិរវេលាចន្លោះពី ៣០ម៉ោង ទៅ ២០០ម៉ោង និងមានរយៈពេលមិនអាចលើសពី ០១ ឆ្នាំនូវការងារគ្មានកម្រៃ និងបានជាប្រយោជន៍ដល់រដ្ឋ រដ្ឋបាលថ្នាក់ក្រោមជាតិ ឬនីតិបុគ្គលនៃនីតិបុគ្គលសាធារណៈផ្សេងៗទៀតដល់សហគមន៍ ឬដល់អង្គការមិនមែនរដ្ឋាភិបាល។[87]

ចំពោះអនីតិជនទោសនេះអនុវត្តខុសប្លែកគ្នាពីការអនុវត្តទោសការងារសហគមន៍ទៅលើនីតិជន ក្នុងនោះមានលក្ខខណ្ឌមួយចំនួន ដែលអាចយកមកអនុវត្តទោសលើអនីតិជនបានដូចជា៖

១. ទោសការងារសហគមន៍អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ក៏ប៉ុន្តែចិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោងនោះទេ។[88] ក្នុងនេះមានន័យថា អនីតិជនដែលអាចអនុវត្តទោសនេះបានលុះត្រាតែមានអាយុចាប់ពី ១៦ឆ្នាំ រហូតដល់ក្រោម ១៨ឆ្នាំ ហើយចិរវេលានៃទោសនេះគឺត្រូវបានច្បាប់កំណត់ត្រឹមតែពាក់កណ្តាលនៃចិរវេលាដែលត្រូវអនុវត្តចំពោះនីតិជនតែប៉ុណ្ណោះ ។

២. ការងារសហគមន៍ ត្រូវតែសម្របសម្រួលទៅលើអនីតិជន ដែលមានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូនខ្លួនទៅរស់នៅក្នុងសង្គមវិញ។[89] ការសម្របសម្រួលទៅលើអនីតិជន គឺចង់សំដៅដល់ស្ថានភាពទំនាក់ទំនង និងការជ្រើសរើសការងារមួយដ៏ល្អសម្រាប់អនីតិជន ដែលវាជាផ្នែកមួយក្នុងការជួយបណ្តុះបណ្តាល អប់រំប្រាជ្ញាស្មារតី វិជ្ជាជីវៈ ការរៀនសូត្រ និងជួយកែប្រែជននោះឲ្យក្លាយទៅជាមនុស្សល្អ ដើម្បីអាចចូលមករស់នៅក្នុងសង្គមវិញបាន។

គេអាចយកត្រឹមតែទោសការងារសហគមន៍ប៉ុណ្ណោះ សម្រាប់អនុវត្តចំពោះអនីតិជនដែលមានអាយុតិចជាង ១៦ឆ្នាំ ហើយការងារនេះមិនអាចមានរយៈពេលលើសពី ១០០ ម៉ោងបានទេ ប៉ុន្តែអ្វីដែលសំខាន់គឺការងារសហគមន៍ត្រូវតែសម្របទៅនឹងចរិតលក្ខណៈរបស់អនីតិជន ហើយមានលក្ខណៈជាការបណ្តុះបណ្តាល និងសម្រួលទៅដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។[90]

---

[87] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ (កថាខណ្ឌទី២)។

[88] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦២ (កថាខណ្ឌទី១)។

[89] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦២ (កថាខណ្ឌទី២)។

[90] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦២ ។

### ១.២.៣. ការប្រកាសទោស

ការប្រកាសទោស ត្រូវបានគ្រប់គ្រងដោយគោលការណ៍ឯកត្តកម្មនៃទោស។ គោលការណ៍ឯកត្តកម្មនៃទោស គឺសំដៅទៅលើការប្រកាសទោសរបស់តុលាការ ដោយផ្អែកទៅលើស្ថានទម្ងន់ និងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាន និងបន្ទុកទៅលើមូលហេតុព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសជាអាទិ៍ចំពោះជនរងគ្រោះ។[91] ខ្លឹមសារនៃមាត្រានេះ គឺជាគោលការណ៍មូលដ្ឋាន ដែលមានបញ្ញត្តិនៃក្រមព្រហ្មទណ្ឌសម្រាប់ចៅក្រមយកមកពិចារណាអំពីស្ថានភាពរបស់ជនល្មើស ក្នុងពេលប្រព្រឹត្តបទល្មើស ក្រោយពេលប្រព្រឹត្តបទល្មើស ពិចារណាអំពីចរិតលក្ខណៈ ឬសភាពផ្លូវចិត្តរបស់ជនជាប់ចោទ និងទំហំព្យសនកម្មបង្កដល់ជនរងគ្រោះ និងសង្គមជាតិជាដើម មុននឹងធ្វើការប្រកាសទោសព្រហ្មទណ្ឌ។

ជាការពិតណាស់ មុននឹងធ្វើការសម្រេចអំពីការផ្តន្ទាទោសលើបទល្មើសនីមួយៗ តុលាការចាំបាច់សិក្សាពីមូលហេតុ និងកត្តាជុំវិញដែលនាំឲ្យមានបទល្មើស និងកិរិយាមាយាទក្រោយពេលប្រព្រឹត្តបទល្មើស ដោយគោរពនឹងភាពមិនរើសអើង និងស្មើភាពគ្នា ភាពសមាមាត្រនៃទោស និងគោលការណ៍ដោយឡែក ដោយផ្អែកលើស្ថានភាពប្រែប្រួលរបស់ជនល្មើសនីមួយៗ។[92] ផ្ទុយទៅវិញ ប្រសិនបើការប្រកាសទោសពុំបានឆ្លងកាត់ ការវិនិច្ឆ័យដោយគោរពតាមគោលការណ៍ឯកត្តកម្មនៃទោសទេ ការជំនុំជម្រះលើទោស នឹងនាំឲ្យមានភាពលម្អៀង និងភាពអយុត្តិធម៌។

ម្យ៉ាងវិញទៀត ទោសមានមុខងារដាក់ទណ្ឌកម្មលើការប្រព្រឹត្តអំពើប្រឆាំងទៅនឹងសង្គម ហើយទោសបង្កើតមកក៏ដើម្បីបង្ការទុកដល់ការប្រព្រឹត្តបទល្មើសសារជាថ្មី និងអនុគ្រោះដល់ការបញ្ជូនជនល្មើសដែលដឹងខ្លួនខុស ហើយព្រមកែប្រែក្លាយទៅជាមនុស្សល្អឲ្យមករស់នៅក្នុងសង្គមឡើងវិញ។ ការផ្តល់ឱកាសដល់ទណ្ឌិតឲ្យមករស់នៅក្នុងសង្គមឡើងវិញ គឺត្រូវធ្វើឡើងកម្រិតកំណត់ដោយច្បាប់ និងឆន្ទានុសិទ្ធិ របស់ចៅក្រមក្នុងការសម្រួលទោស។ ចៅក្រមមានភារកិច្ចក្នុងការផ្តល់សំអាងហេតុ ពន្យល់អំពីហេតុផលដែលនាំឲ្យជ្រើសរើសយកទោសណាមួយមកអនុវត្តជាក់ស្តែង គឺទាក់ទងជាមួយនឹងការប្រកាសទោសណាមួយដែលអត្ថិភាព ចំនួន ឬបែបបទនៃទោសនោះត្រូវបានចែងដោយច្បាប់។[93]

លើសពីនេះទៅទៀតគោលការណ៍នេះគឺ ជាមូលដ្ឋានសំខាន់ពាក់ព័ន្ធនឹងរបបទូទៅនៃការប្រកាសទោសរបស់តុលាការ ពោលគឺត្រូវប្រកាសទោសដោយគោរព និងផ្អែកទៅលើគោលការណ៍ឯកត្តកម្មនៃទោសដែលអាចឲ្យចៅក្រមធ្វើការពិចារណាក្នុងការសម្រេចលើការប្រកាសមូលទោស ការប្រកាសទោសជំនួស ការប្រកាសទោស

---

[91] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៦ ។

[92] មេរៀននីតិព្រហ្មទណ្ឌរៀបចំដោយផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ចុះនៅខែធ្នូ ឆ្នាំ២០០៧, ទំព័រ ៨២។

[93] មេរៀននីតិព្រហ្មទណ្ឌរៀបចំដោយផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ចុះនៅខែធ្នូ ឆ្នាំ២០០៧, ទំព័រ ៨២។

បន្ថែមលើមូលទោស ការប្រកាសទោសការងារសហគមន៍ ការព្យួរទោសធម្មតា ការព្យួរទោសសាកល្បង របបពាក់កណ្តាលសេរីភាព និងការបែងចែកទោសជាប្រភាគជាអាទិ៍។

### ១.២.៣.១. ការប្រកាសមូលទោស

គ្រប់ករណីទាំងអស់ដែលបទល្មើសត្រូវបានផ្តន្ទាទោសដាក់ ពន្ធនាគារផង និងពិន័យផងតុលាការអាចប្រកាស ៖[94]

- ទោសជាប់ពន្ធនាគារ និងទោសពិន័យត្រួតគ្នា
- ទោសដាក់ពន្ធនាគារតែមួយមុខប៉ុណ្ណោះ
- ឬក៏ទោសពិន័យជាប្រាក់តែមួយមុខប៉ុណ្ណោះ។

ចំពោះការធ្វើឯកត្តកម្មនៃទោស គឺធ្វើឡើងក្រោមលក្ខខណ្ឌតែមួយគត់ដែលត្រូវបានចែងដោយច្បាប់ ក្នុងនោះចៅក្រមអាចជ្រើសរើសប្រកាសទោសតែមួយគត់ ក្នុងចំណោមទោសដែលបានចែង (ពន្ធនាគារ ឬទោសពិន័យ) ឬអាចប្រកាសទោសទាំងពីរនេះត្រួតគ្នា។ ចៅក្រមមានកាតព្វកិច្ចគោរពតាមការកំណត់នៃច្បាប់ ពោលគឺត្រូវគិតទៅលើស្ថានភាពនៃទោសអប្បបរមានិងអតិបរមាលើកលែងតែមានយន្តការបន្ថយទោសដូចជាស្ថានសម្រាលទោសជាដើម។

### ១.២.៣.២. ការប្រកាសទោសបន្ថែម

ចំពោះទោសនេះផងដែរ កាលណាបទល្មើសមួយត្រូវផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើនទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា១០០ (ការជំនួសមូលទោស ដោយទោសបន្ថែម) នៃក្រមនេះចេញ។[95] ការប្រកាសទោសបន្ថែមគ្មានលក្ខណៈបង្ខិតបង្ខំនោះទេ ចៅក្រមមានភារកិច្ចក្នុងការសម្រេចអនុវត្តនូវកាតព្វកិច្ចបន្ថែមលើមូលទោស ប្រសិនបើចៅក្រមរកឃើញភស្តុតាងបន្ថែម។ ម៉្យាងវិញទៀត ចៅក្រមមានសិទ្ធិក្នុងការហាមឃាត់ជនល្មើសក្នុងការស្នាក់នៅទៅកន្លែងណាមួយ ឬហាមឃាត់ការអនុវត្តវិជ្ជាជីវៈរបស់ជននោះជាដើម។[96]

ចៅក្រមអាចសម្រេចជំនួសមូលទោស ដោយទោសបន្ថែមមួយ ឬច្រើនបាននៅពេលដែលជនជាប់ចោទទទួលរងនូវទោសពិន័យជាមូលទោសតែមួយគត់ និងពេលដែលជនជាប់ចោទទទួលរងនូវទោសពន្ធនាគារ

[94] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៧ ។
[95] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៩ ។
[96] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៥៣ (កថាខណ្ឌទី៥ និងកថាខណ្ឌទី២) ។

ដែលមានអតិបរមាស្មើ ឬតិចជាង០៣ឆ្នាំ។[97] ចៅក្រមនឹងសម្រេចបោះបង់មូលទោស ដើម្បីប្រកាសតែទោសបន្ថែមមួយ ឬច្រើនព្រោះចៅក្រមមិនអាចប្រកាសទោសដាក់ពន្ធនាគារឬទោសពិន័យជាប្រាក់បានទេ។[98]

ការប្រកាសទោសបន្ថែមអាចធ្វើឡើងជា ២ ករណីផ្សេងទៀតមានដូចជាការប្រកាសទោសបន្ថែមលើមូលទោស និងការប្រកាសទោសបន្ថែមជំនួសមូលទោស។

### ១.២.៣.២.១. ការប្រកាសទោសបន្ថែមលើមូលទោស

ការប្រកាសទោសបន្ថែមលើមូលទោស សំដៅដល់ការប្រកាសទោសបន្ថែមត្រួតជាមួយនឹងមូលទោស មាននន័យថាប្រកាសមូលទោសផង និងប្រកាសទោសបន្ថែមផង ដើម្បីឲ្យទណ្ឌិតអនុវត្តទាំងពីរទោសតែម្តង។[99] កាលណាបទល្មើសមួយផ្តន្ទាទោសដោយទោសបន្ថែមមួយ ឬច្រើន ទោសបន្ថែមនេះត្រូវបន្ថែមទៅលើមូលទោស លើកលែងតែបទប្បញ្ញត្តិនៃមាត្រា ១០០ (ការជំនួសមូលទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌតែប៉ុណ្ណោះ។[100]

<u>ឧទាហរណ៍</u> ៖ តុលាការបានប្រកាសមូលទោសឲ្យដាក់ពន្ធនាគារ០១ឆ្នាំ និងទោសបន្ថែមដោយហាមមិនឲ្យបើកបរយានយន្តគ្រប់ប្រភេទក្នុងរយៈពេល០២ឆ្នាំ។ ដូចនេះ ទោសទាំងពីរត្រូវអនុវត្តរួមគ្នាដោយជាប់ពន្ធនាគាររយៈពេល០១ឆ្នាំ និងមិនអាចបើកបរយានយន្តគ្រប់ប្រភេទរយៈពេល០២ឆ្នាំ។[101]

### ១.២.៣.២.២. ការប្រកាសទោសបន្ថែមជំនួសមូលទោស

ការប្រកាសទោសបន្ថែមនេះ សំដៅដល់ ការប្រកាសតែទោសបន្ថែមដោយជំនួសលើមូលទោសតែម្តងពោលគឺការប្រកាសតែទោសបន្ថែមតែឯកឯង។[102] ការប្រកាសទោសបន្ថែមជំនួសមូលទោសអាចប្រព្រឹត្តទៅបានលុះត្រាតែបានបំពេញនូវលក្ខខណ្ឌមួយចំនួនដូចជាកាលណាជនជាប់ចោទទទួលទោសពិន័យក្នុងឋានៈជាមូលទោសតែមួយគត់។[103] កាលណាជនជាប់ចោទទទួលទោសដាក់ពន្ធនាគារដែលអតិបរមាស្មើ ឬតិចជាង ៣ (បី) ឆ្នាំ។[104]

### ១.២.៣.៣. ការប្រកាសទោសជំនួស

នៅពេលដែលចៅក្រមយល់ឃើញថាទោសពន្ធនាគារ ពុំត្រូវបានបង្ហាញដោយសារមូលហេតុផ្សេងៗមកពីទោសពិន័យមិនអាចអនុវត្តបាន ដោយសារការប្រៀបធៀបទៅនឹងធនធានរបស់ជនជាប់ចោទ នោះចៅក្រមអាចប្រកាសទោសជំនួសវិញបាន ដោយប្រើទោសការងារសហគមន៍ជំនួសឲ្យមូលទោស។ ប៉ុន្តែតុលាការដែល

---

[97] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០០ (កថាខណ្ឌទី២) ។

[98] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០០ ។

[99] ទំព័រស្វែងយល់ពីច្បាប់ , ប្រភេទនៃទោស រៀបរៀងដោយ ន.ស.រ , មករា ឆ្នាំ២០១៧ ទំព័រទី ១៨។

[100] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៩។

[101] ទំព័រស្វែងយល់ពីច្បាប់ , ប្រភេទនៃទោស រៀបរៀងដោយ ន.ស.រ , មករា ឆ្នាំ២០១៧ ទំព័រទី ១៨។

[102] ទំព័រស្វែងយល់ពីច្បាប់ , ប្រភេទនៃទោស រៀបរៀងដោយ ន.ស.រ , មករា ឆ្នាំ២០១៧ ទំព័រទី ១៩។

[103] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០០ កថាខណ្ឌទី១។

[104] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០០ កថាខណ្ឌទី២។

ប្រកាសទោសការងារសហគមន៍នោះ មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់នោះទេ[105] ហើយតុលាការដែលប្រកាសការស្តីបន្ទោស ក៏មិនអាចប្រកាសទោសដាក់ពន្ធនាគារ ឬពិន័យជាប្រាក់បានដែរ។[106] ក្នុងន័យទាំងពីរខាងលើនេះ ចង់សំដៅលើការប្រកាសទោសរបស់តុលាការ ដែលពុំអាចប្រកាសទោសពីរត្រួតគ្នាឡើយ ដូច្នេះតុលាការត្រូវគោរពតាមបទប្បញ្ញត្តិនៃក្រមព្រហ្មទណ្ឌ ដោយលះបង់ការប្រកាសមូលទោស មានន័យថាទោសពន្ធនាគារ ឬទោសដែលត្រូវពិន័យជាប្រាក់ ហើយប្រកាសនូវទោសការងារសហគមន៍ ឬការស្តីបន្ទោសជំនួសវិញ។

ការប្រកាសទោសជំនួស អាចអនុវត្តបានអាស្រ័យកត្តាជាច្រើនមានដូចជា ៖

- តុលាការអាចធ្វើការប្រកាសទោសការងារសហគមន៍បាន លុះត្រាតែមានវត្តមានជនជាប់ចោទនៅក្នុងសវនាការផងដែរ។ វត្តមានរបស់ជនជាប់ចោទមានសារៈសំខាន់ណាស់ ព្រោះមុនពេលប្រកាសទោស តុលាការត្រូវជាស់តឿនដល់ជនជាប់ចោទថាជននោះអាចបដិសេធមិនធ្វើការងារនេះបាន ហើយរាល់ចម្លើយរបស់ជនជាប់ចោទត្រូវតែចុះក្នុងសេចក្តីសម្រេចរបស់តុលាការ។[107]
- តុលាការដែលប្រកាសទោសការងារសហគមន៍ ត្រូវតែកំណត់ចិរវេលានៃការងារនេះ និងរយៈពេលដែលត្រូវបំពេញ ហើយរយៈពេលនេះមិនអាចលើសពី ០១ (មួយ) ឆ្នាំនោះឡើយ។[108]
- តុលាការអាចប្រកាសទោសការងារសហគមន៍បាន កាលណាជនជាប់ចោទត្រូវទទួលការផ្តន្ទាទោស ដាក់ពន្ធនាគារដែលអតិបរមាតិចជាង ឬស្មើនឹង០៣ឆ្នាំ។[109]
- ការអនុវត្តទោសការងារសហគមន៍ត្រូវកំណត់ដោយព្រះរាជអាជ្ញា។[110]
- ព្រះរាជអាជ្ញាចង្អុលប្រាប់ឈ្មោះនីតិបុគ្គលដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ។[111] ក្នុងចំណុចនេះមានន័យថា ព្រះរាជអាជ្ញាគឺជាអ្នកចង្អុលប្រាប់អំពីឈ្មោះនីតិបុគ្គលណាមួយ ដែលត្រូវទទួលអត្ថប្រយោជន៍ពីការងារនេះ ព្រមទាំងការត្រួតពិនិត្យលើការអនុវត្តការងារនេះផងដែរ។

---

[105] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៨ (កថាខណ្ឌទី១) ។

[106] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៩៨ (កថាខណ្ឌទី២) ។

[107] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០១ ។

[108] សៀវភៅសំណួរចំម្លើយសម្រាប់ការត្រៀមប្រលង រៀបចំដោយ បណ្ណាគារភក្តីឡដំ ចេញថ្ងៃទី ២៦ /១២/២០១៦។

[109] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ៧២ កថាខណ្ឌទី១។

[110] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៣ (កថាខណ្ឌទី១) ។

[111] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៣ (កថាខណ្ឌទី២) ។

## ១.៣. បែបបទ និងផលប៉ះពាល់ផ្សេងៗដល់ការអនុវត្តទោស

### ១.៣.១. អាជ្ញាយុកាលនៃទោស

គោលការណ៍អាជ្ញាយុកាលនៃទោស គឺជារយៈពេលមួយកំណត់ដោយច្បាប់ ប្រសិនបើផុតរយៈពេល ឬអាជ្ញាយុកាល តាមច្បាប់កំណត់ហើយបុគ្គលនោះអាចបាត់បង់សិទ្ធិណាមួយរបស់ខ្លួន ឬអាចទាមទារសិទ្ធិណាមួយជាប្រយោជន៍ផ្ទាល់ខ្លួន អាស្រ័យទៅតាមការកំណត់ដែលមាននៅក្នុងបទប្បញ្ញត្តិច្បាប់។ ជាទូទៅអាជ្ញាយុកាលនៃទោសមានពីរប្រភេទគឺៈ

- អាជ្ញាយុកាលនៃបទល្មើស ឬអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ព្រះរាជអាជ្ញាពុំអាចធ្វើការចោទប្រកាន់បានទេ ឬអាចនិយាយម្យ៉ាងទៀតបានថាព្រះរាជអាជ្ញាពុំអាចដាក់បណ្តឹងអាជ្ញាឲ្យមានចលនា ឬដំណើរការទៅមុខទៀតបានឡើយ។[112] ជាគោលការណ៍អាជ្ញាយុកាលនៃបទល្មើស ចាប់ផ្តើមគិតពីថ្ងៃដែលបានប្រព្រឹត្តបទល្មើសតទៅ។
- អាជ្ញាយុកាលនៃទោស ជារយៈពេលមួយកំណត់ដោយច្បាប់ដែលផុតរយៈពេលនេះ ទោសពុំអាចអនុវត្តបានទៀតទេ ហើយអាជ្ញាយុកាលនេះគេគិតចាប់ពីពេលដែលតុលាការបានផ្តន្ទាទោសដល់ជនណាមួយបានចូលជាស្ថាពរ។[113] ម្យ៉ាងវិញទៀតអាជ្ញាយុកាលនៃទោសត្រូវបានបង្កើតឡើងមក ដោយសារមានការយល់ឃើញថាក្នុងរយៈពេលនៃអាជ្ញាយុកាលនៃទោស ទណ្ឌិតប្រាកដជាក្លាយជាមនុស្សល្អ ដឹងខ្លួនខុស ប្រព្រឹត្តតែអំពើល្អ ពោលគឺទណ្ឌិតបានកែប្រែខ្លួនដោយស្ម័យប្រវត្តិរួចហើយ ហេតុដូច្នេះមិនមានការចាំបាច់ត្រូវធ្វើការបង្ខំយកទណ្ឌិតមកអនុវត្តទោសតទៅទៀតនោះឡើយ។[114]

អាជ្ញាយុកាលនៃទោសត្រូវបានយកមកអនុវត្តទៅតាមដែនអនុវត្តអាជ្ញាយុកាលនៃទោស និងគិតទៅតាមរយៈពេលអាជ្ញាយុកាលនៃទោស។

#### ១.៣.១.១. ដែនអនុវត្តអាជ្ញាយុកាលនៃទោស

ជាក់ស្តែងនៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ។[115] មានន័យថានៅអំឡុងពេលនៃការផ្តន្ទាទោសចូលជាស្ថាពរ ហើយចៅក្រមសម្រេចឲ្យជននោះជាប់ពន្ធនាគារ ប៉ុន្តែជននោះបានគេចខ្លួនដោយរស់នៅក្នុងស្ថានភាពណាមួយ ដែលគ្មាននរណាដឹងរហូតដល់ផុតអាជ្ញាយុកាលនៃទោសដែលខ្លួនបានប្រព្រឹត្ត បើគិតចាប់តាំងពីពេលដែលជននោះបានប្រព្រឹត្តបទល្មើសបូករួមទាំងអាជ្ញាយុកាលនៃទោសដែលខ្លួនបានប្រព្រឹត្ត។

---

[112] សៀវភៅសំណួរចម្លើយសម្រាប់ការត្រៀមប្រលងរៀបចំដោយបណ្ណាគារភក្តីឡង់ ចេញថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៦។

[113] សៀវភៅសំណួរចម្លើយសម្រាប់ការត្រៀមប្រលងរៀបចំដោយបណ្ណាគារភក្តីឡង់ ចេញថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ២០១៦។

[114] នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ៤៦៤។

[115] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤២។

ដូច្នេះនៅពេលផុតអាជ្ញាយុកាលនៃទោសហើយ ទោសនោះមិនត្រូវបានយកមកអនុវត្តបានទៀតទេ ជននោះនឹងត្រូវបានរួចទោសហើយមានសិទ្ធិក្នុងការរស់នៅក្នុងសង្គមសារជាថ្មី។

ទោសអាចនឹងត្រូវផុតអាជ្ញាយុកាលបាន ដោយមិនចាំបាច់គិតពីប្រភេទនៃបទល្មើសនោះទេ ប៉ុន្តែនៅក្នុងនោះផងដែរ ក៏មានបទល្មើសខ្លះគ្មានអាជ្ញាយុកាលទេ ដោយច្បាប់បានបញ្ញត្តិឲ្យបទល្មើសទាំងនោះ ពុំមានទាំងអាជ្ញាយុកាលនៃទោស ព្រមទាំងពុំមានទាំងអាជ្ញាយុកាលនៃបណ្ដឹង។ ពិសេសចំពោះបទឧក្រិដ្ឋមួយចំនួនដែលប្រកាសពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋសង្គ្រាម មិនអាចផុតរលត់អាជ្ញាយុកាលទេ។[116] បើទោះជាជននោះបានប្រព្រឹត្តក្នុង អំឡុងពេលប៉ុន្មានក៏ដោយក៏ត្រូវតែទទួលបានការផ្ដន្ទាទោសទៅតាមច្បាប់ផងដែរ ដោយសារតែមានឥទ្ធិពលគ្រោះថ្នាក់ខ្លាំងក្លាដល់សង្គមទាំងមូល។ ម្យ៉ាងទៀត ក្រៅពីបទល្មើសខាងលើច្បាប់ពិសេសក៏អាចកំណត់អំពីភាពមិនអាចផុតរលត់អាជ្ញាយុកាលនៃទោស ចំពោះបទឧក្រិដ្ឋផ្សេងៗទៀតបានដូចគ្នា។[117]

#### ១.៣.១.២. រយៈពេលអាជ្ញាយុកាលនៃទោស

រយៈពេលអាជ្ញាយុកាលនៃទោស ត្រូវចាប់ផ្ដើមគិតពីថ្ងៃដែលសេចក្ដីសម្រេចផ្ដន្ទាទោសបានចូលជាស្ថាពរ។ រយៈអាជ្ញាយុកាលនៃទោសមានដូចជា៖[118]

- ទោសដែលប្រកាសពី បទឧក្រិដ្ឋមានអាជ្ញាយុកាល ២០ (ម្ភៃ) ឆ្នាំ។
- ទោសដែលប្រកាសពី បទមជ្ឈិមមានអាជ្ញាយុកាល ៥ (ប្រាំ) ឆ្នាំ។
- ទោសដែលប្រកាសពី បទលហុមានអាជ្ញាយុកាល ១ (មួយ) ឆ្នាំ។

ដូច្នេះហើយ ប្រសិនបើហួសអាជ្ញាយុកាលនៃទោសខាងលើហើយ ទោសនោះនឹងរលត់ ហើយជនដែលជាប់ទោសនោះនឹងមានសិទ្ធិសេរីភាពក្នុងការចូលទៅរស់នៅក្នុងសង្គមជាថ្មីម្ដងទៀត។

### ១.៣.២. ការបន្ធូរបន្ថយទោស និងការលើកលែងទោស

ការអនុគ្រោះទោសដោយការបន្ធូរបន្ថយទោស ឬការលើកលែងទោសដោយអនុលោមតាមមាត្រា២៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា លើកលែងឲ្យទណ្ឌិតរួចផុតពីការអនុវត្តទោសដែលអនុគ្រោះនោះ។[119]

ការបន្ធូរបន្ថយទោស និងការលើកលែងទោសមានអត្ថន័យខុសគ្នា ពោលគឺការបន្ធូរបន្ថយទោស គឺជាការកាត់បន្ថយទោសរបស់ទណ្ឌិតឲ្យនៅសល់រយៈពេលខ្លី និងឆាប់បញ្ចប់ទោសដែលទណ្ឌិតត្រូវអនុវត្ត។ ការលើក

---

[116] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៣ (កថាខណ្ឌទី១)។
[117] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៣ (កថាខណ្ឌទី២)។
[118] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៤។
[119] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៧។

លែងទោសមានពីរ គឺការលើកលែងទោសពីព្រះមហាក្សត្រ និងការលើកលែងទោសជាទូទៅ។[120] ការលើកលែងទោសពីព្រះមហាក្សត្រមានន័យថា គឺជាការបញ្ចប់ការអនុវត្តទោសក្នុងពន្ធនាគារដែលនៅសល់ ដោយមានការព្រះរាជទានលើកលែងទោសពីព្រះមហាក្សត្រ រីឯការលើកលែងទោសជាទូទៅវិញ គឺសំដៅទៅលើការលើកលែងទោសដល់ជនប្រព្រឹត្តឧក្រិដ្ឋជាក្រុមតាមរយៈច្បាប់អនុម័តរបស់សភា។[121]

ជាទូទៅទណ្ឌិតត្រូវបំពេញនូវលក្ខខណ្ឌមួយចំនួនជាមុនសិន ទើបអាចទទួលបាននូវការបន្ធូរបន្ថយទោស ឬលើកលែងទោស ដែលអាចបញ្ចប់នូវការអនុវត្តដែលនៅសល់ ហើយទណ្ឌិតនឹងមានសេរីភាពសារជាថ្មីក្នុងការចូលទៅរស់នៅក្នុងសង្គមវិញ។

### ១.៣.២.១. លក្ខខណ្ឌនៃការបន្ធូរបន្ថយទោស និងការលើកលែងទោស

ការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ដែលជាប់ពន្ធនាគារតែងតែធ្វើឡើងជារៀងរាល់ឆ្នាំ ប៉ុន្តែទណ្ឌិតត្រូវអនុវត្តទោសរបស់ខ្លួននៅក្នុងពន្ធនាគារទៅតាមច្បាប់កំណត់ជាមុនសិន ទើបអាចទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោសទាំងនោះបាន។ នីតិវិធីក្នុងការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត ក្នុងគោលបំណងដើម្បីធ្វើសមាហរណកម្មទណ្ឌិតនោះឲ្យចូលទៅរួមរស់ក្នុងសង្គមវិញ ឬក្នុងគោលបំណងផ្នែកមនុស្សធម៌។[122]

ជាពិសេសការបន្ធូរបន្ថយទោស និងលើកលែងទោស ក៏អាចអនុវត្តចំពោះទណ្ឌិតដែលមានវ័យចាស់ជរា ជាស្ត្រីមានគភ៌ ឬមានជំងឺរ៉ាំរ៉ៃធ្ងន់ធ្ងរ វិបល្លាសស្មារតី ឬពិការភាព ដោយមានលិខិតបញ្ជាក់ពីគ្រូពេទ្យ ដែលទទួលស្គាល់ដោយក្រសួងមានសមត្ថកិច្ច។[123] ចំពោះបញ្ហានេះ ប្រធានពន្ធនាគារគឺជាអ្នកធ្វើការបញ្ជាក់អំពីស្ថានភាព ឬលក្ខណៈរបស់ទណ្ឌិត ដោយបំពេញនូវលក្ខខណ្ឌនីមួយៗទៅតាមច្បាប់បានកំណត់ រចស្នើសុំទៅកាន់គណៈកម្មការ រាជធានី-ខេត្ត និងគណៈកម្មការក្រសួងមហាផ្ទៃ ដើម្បីត្រួតពិនិត្យ។

បច្ចុប្បន្នការអនុវត្តនីតិវិធីការបន្ធូរបន្ថយទោស និងការលើកលែងទោសចំពោះទណ្ឌិត អាចប្រព្រឹត្តទៅបានអាស្រ័យលក្ខខណ្ឌពីរ ដូចជាលក្ខខណ្ឌចរិកលក្ខណៈសម្បត្តិរបស់ទណ្ឌិត និងអាជ្ញាយុកាលកំណត់ក្នុងការបន្ធូរបន្ថយទោស ។

[120] យុត្តិធម៌ និងច្បាប់, ព្រឹត្តិបត្រមេធាវី លេខ១៣, មាសប៉ូវ៉ា, ខែមេសា-មិថុនា ឆ្នាំ២០១៧, ទំព័រទី៣។

[121] យុត្តិធម៌ និងច្បាប់, ព្រឹត្តិបត្រមេធាវី លេខ១៣, មាសប៉ូវ៉ា, ខែមេសា-មិថុនា ឆ្នាំ២០១៧, ទំព័រទី៣។

[122] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១, មាត្រា១ ។

[123] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១, មាត្រា៦ (កថាខណ្ឌទី១) ។

### ១.៣.២.១.១. លក្ខខណ្ឌបុគ្គលិកលក្ខណៈរបស់ទណ្ឌិត

ដើម្បីទទួលបាននូវការបន្ធូរបន្ថយទោស និងលើកលែងទោសទណ្ឌិតត្រូវបំពេញលក្ខខណ្ឌធំៗដូចខាងក្រោមជាមុនសិនមានដូចជា ៖

- ភ្ញាក់រលឹកខិតខំកែប្រែគំនិតមាយាទឲ្យក្លាយជាពលរដ្ឋសុចរិត ដើម្បីធ្វើសមាហរណកម្មចូលរួមរស់ក្នុងសង្គមវិញ។[124] លុះត្រាតែទណ្ឌិតនោះចេះភ្ញាក់រឭក កែប្រែខ្លួនឲ្យក្លាយទៅជាមនុស្សល្អ និងបង្ហាញឲ្យឃើញថាខ្លួនមានគំនិតមាយាទល្អក្នុងរយៈពេលជាប់ឃុំ និងមានសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។
- គោរពប្រតិបត្តិបានយ៉ាងហ្មត់ចត់ និងត្រឹមត្រូវតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងជាគំរូល្អដល់ទណ្ឌិត និងជនជាប់ឃុំទៃទៀត។[125]
- ចូលរួមអនុវត្តយ៉ាងសកម្ម និងទៀតទាត់នូវកម្មវិធីអប់រំកែប្រែ កម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីសមាហរណកម្ម[126] ដើម្បីជួយជំរុញដល់ទេពកោសល្យ និងជំនាញផ្សេងៗរបស់ជននោះឲ្យកាន់តែខ្លាំង និងងាយស្រួលក្នុងការយកទៅប្រកបមុខរបរពេលចេញទៅរស់នៅក្នុងសង្គមវិញ។

នៅពេលដែលទណ្ឌិតយល់ឃើញថា ខ្លួនបានបំពេញនៅលក្ខខណ្ឌដូចដែលមាននៅខាងលើ ក៏ប៉ុន្តែមិនបានត្រូវប្រធានពន្ធនាគារធ្វើការស្នើសុំឲ្យខ្លួនទេ នោះទណ្ឌិតមានសិទ្ធិប្តឹងតវ៉ាទៅ គណៈកម្មការថ្នាក់ជាតិដោយមានការគាំទ្រពីក្រុមការងារប្រឡងប្រណាំងនៃពន្ធនាគារ។[127]

### ១.៣.២.១.២. អាជ្ញាយុកាលកំណត់ក្នុងការបន្ធូរបន្ថយទោស

រយៈពេលនៃការបន្ធូរបន្ថយទោស ឬការលើកលែងទោសអាចអនុញ្ញាតទៅបាន លុះត្រាតែទណ្ឌិតបានអនុវត្តទោសដាក់ពន្ធនាគារទៅតាមរយៈពេលណាមួយ ដែលច្បាប់បានកំណត់ជាមុនសិន។ ចំពោះទណ្ឌិត ដែលបានជាប់ទោសដាក់ពន្ធនាគារ ទាក់ទងនឹងចិរវេលានៃទោសក្នុងការបន្ធូរបន្ថយ និងការលើកលែងទោសមានដូចជា ៖[128]

[124] ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស,លេខនស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១,, មាត្រា៥ (កថាខណ្ឌទី១, ចំណុចទី១)។

[125] ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស,លេខនស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១,, មាត្រា៥ (កថាខណ្ឌទី១, ចំណុចទី២)។

[126] ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស,លេខនស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១,, មាត្រា៥ (កថាខណ្ឌទី១, ចំណុចទី៣)។

[127] ច្បាប់ស្តីពីពន្ធនាគារ ,នស/រកម/១២១១/០២១ , អនុម័តថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១១, មាត្រា ៧៦។

[128] ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៨៨, មាត្រា៣ និងមាត្រា៤។

- ករណីបន្ធូរបន្ថយទោសលុះត្រាតែទណ្ឌិតទាំងនោះ បានទទួលទោសមួយភាគបី (១/៣) នៃទោសដាក់ពន្ធនាគារមានកំណត់ ឬទទួលទោស០៧ ឆ្នាំចំពោះទោសដាក់ពន្ធនាគារមួយជីវិត។
- ករណីលើកលែងទោសលុះត្រាតែទណ្ឌិតទាំងនោះបានទទួលទោសចំនួនពីរភាគបី (២/៣) នៃទោសដាក់ពន្ធនាគារមានកំណត់ ឬទទួលទោស ១៥ ឆ្នាំចំពោះទោសដាក់ពន្ធនាគារមួយជីវិត។

ជាងនេះទៅទៀត ការបន្ធូរបន្ថយទោសចំពោះទណ្ឌិតមានអាជ្ញាយុកាលខុសៗគ្នា ដែលត្រូវបានកំណត់ដូចខាងក្រោម ៖[129]

- ចំពោះទោសដែលកំណត់ចាប់ពី ០១ (មួយ) ឆ្នាំដល់ ១០ (ដប់) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារបានចំនួន ០៦ (ប្រាំមួយ) ខែម្តងក្នុងរយៈពេលមួយឆ្នាំ។
- ចំពោះទោសដែលកំណត់ចាប់ពី ១០ (ដប់) ឆ្នាំដល់ ១៥ (ដប់ប្រាំ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារបានចំនួន ០៩ (ប្រាំបួន) ខែម្តងក្នុងរយៈពេលមួយឆ្នាំ។
- ចំពោះទោសដែលកំណត់ចាប់ពី ១៥ (ដប់ប្រាំ) ឆ្នាំដល់ ២០ (ម្ភៃ) ឆ្នាំ អាចនឹងបន្ថយរយៈពេលជាប់ពន្ធនាគារបានចំនួន ១២ (ដប់ពីរ) ខែម្តងក្នុងរយៈពេលមួយឆ្នាំ។

ទណ្ឌិតម្នាក់អាចទទួលការបន្ធូរបន្ថយទោសច្រើនដងបានតែក្នុងលក្ខខណ្ឌដែលទណ្ឌិតនោះបានទទួលរងទោសទាំងអស់បានពាក់កណ្តាលនៃទោសដែលតុលាការបានកំណត់ ហើយការកំណត់ចំពោះទោសដាក់ពន្ធនាគារមួយជីវិតអនុញ្ញាតអាចនឹងបន្ថយទោសលើកទី១ មកត្រឹម ២០ ឆ្នាំហើយអាចបន្ធូរបន្ថយទោសច្រើនដងទៀតបានប៉ុន្តែបើទោះបីជាទណ្ឌិតនោះត្រូវបន្ធូរបន្ថយទោសច្រើនដងក៏ដោយក៏រយៈពេលនៃការទទួលទោសក្នុងពន្ធនាគារទាំងអស់ត្រូវអនុវត្តទោសឲ្យបាន ១៥ ឆ្នាំសិនដែរ។

ចំពោះទណ្ឌិត ដែលមិនបានអនុវត្តទោសដូចលក្ខខណ្ឌខាងលើក៏អាចទទួលបានការលើកលែងទោសដែរ ប៉ុន្តែក្នុងករណីនេះមិនសូវកើតមានទេព្រោះលក្ខខណ្ឌតឹងរ៉ឹងពេក។ ប៉ុន្តែក្នុងករណីចាំបាច់ប្រមុខរាជរដ្ឋាភិបាលមានបុព្វសិទ្ធិធ្វើសំណើថ្វាយព្រះមហាក្សត្រសុំលើកលែងទោសឲ្យទណ្ឌិតនៅពេលណាក៏បាន។[130] ករណីនេះទណ្ឌិតអាចលើកលែងទោសបានដោយមិនគោរពនូវលក្ខខណ្ឌខាងលើក៏បានដែរ ក៏ប៉ុន្តែទាល់តែជាករណីចាំបាច់ហើយមានសំណើពីប្រមុខរាជរដ្ឋាភិបាលថ្វាយទៅព្រះមហាក្សត្រ និងអាចធ្វើបានគ្រប់ពេលវេលាដោយមិនចាំបាច់រង់ចាំដល់ពេលមានបុណ្យជាតិធំៗនោះទេ។

[129] ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ១៩៩៨, មាត្រា៣ និងមាត្រា៤។

[130] ច្បាប់ស្តីពីពន្ធនាគារ ,លេខ នស/រកម/១២១១/០២១ , ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១, មាត្រា ៧៧។

ពិធីបុណ្យជាតិធំៗ ដែលអាចឲ្យទណ្ឌិតទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោសបានមានដូចជា៖[131]

១- បុណ្យចម្រើនព្រះជន្មព្រះមហាក្សត្រ

២- បុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ

៣- បុណ្យអុំទូក បណ្តែតប្រទីប អកអំបុក និងសំពះព្រះខែ

៤- បុណ្យឯករាជ្យជាតិ

៥- បុណ្យវិសាខបូជាជាដើម។

ម្យ៉ាងទៀតការបន្ធូរបន្ថយទោស និងការលើកលែងទោស ក៏អាចធ្វើសម្រាប់ពីធីបុណ្យនីមួយៗ ខាងលើដាច់ដោយឡែកពីគ្នា ឬរួមគ្នាផងដែរ។[132]

### ១.៣.២.២. នីតិវិធីក្នុងការបន្ធូរបន្ថយទោស និងលើកលែងទោស

ការលើកលែងទោស និងការបន្ធូរបន្ថយទោស អាចធ្វើឡើងបានអាស្រ័យទៅនឹងលក្ខណៈសម្បត្តិ និងលក្ខខណ្ឌជាច្រើនដែលទណ្ឌិតបានបំពេញ និងអនុវត្តតាមដូចបានបង្ហាញនៅខាងផ្នែកលើ។ ពិធីបុណ្យ លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការបន្ធូរបន្ថយទោស និងការលើកលែងទោសត្រូវកំណត់ដោយព្រះរាជក្រឹត្យ។[133]

ចំពោះនីតិវិធីការបន្ធូរបន្ថយទោស និងការលើកលែងទោសវិញ ដំបូងប្រធានពន្ធនាគារជាអ្នករៀបចំ និងពិនិត្យមើលបញ្ជីឈ្មោះ ទណ្ឌិតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ស្របទៅតាមលក្ខខណ្ឌ ដែលច្បាប់បានកំណត់ បន្ទាប់មកប្រធានពន្ធនាគារបញ្ជូនឯកសារពាក់ព័ន្ធទាក់ទងនឹងទណ្ឌិត ស្នើសុំទៅកាន់គណៈកម្មការរាជធានី-ខេត្ត និងកម្មាការក្រសួងមហាផ្ទៃ។ គណៈកម្មាការរាជធានី-ខេត្ត និងគណៈកម្មាការក្រសួងមហាផ្ទៃ នឹងធ្វើការត្រួតពិនិត្យ ហើយវាយតម្លៃលើឯកសារទាំងនោះ និងត្រូវរៀបចំបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងការលើកលែងទោស រួមនិងសំណុំឯកសារពាក់ព័ន្ធបញ្ជូនទៅកាន់គណៈកម្មាការថ្នាក់ជាតិដើម្បីពិនិត្យ និងវាយតម្លៃបន្ថែមទៅលើបញ្ជីឈ្មោះទណ្ឌិតស្នើសុំបន្ធូរបន្ថយទោស និងការលើកលែងទោសយ៉ាងយឺតបំផុត ៣០ (សាមសិប) ថ្ងៃមុនថ្ងៃកំណត់។[134]

គណៈកម្មាការថ្នាក់ជាតិមានតួនាទីពិសេសក្នុងការប្រជុំពិនិត្យ វិនិច្ឆ័យ និងវាយតម្លៃលើបញ្ជីឈ្មោះទណ្ឌិតនីមួយៗទៅតាមលក្ខខណ្ឌដែលមានចែងមុននឹងរៀបចំបែបបទស្នើសុំបន្ធូរបន្ថយទោស និងការលើកលែង

[131] ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១,, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ មាត្រា៣។

[132] ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១,, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១ មាត្រា៣ (កថាខណ្ឌទី៣) ។

[133] ក្រមនីតិវិធីព្រហ្មទណ្ឌ ,នស/រកម/១២១១/០២១ ចុះនៅថ្ងៃទី ១០ ខែសីហា ឆ្នាំ២០០៧, មាត្រា ៥១៣។

[134] ច្បាប់ស្តីពីពន្ធនាគារ, លេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១, មាត្រា៧៤។

ទោសជូនទៅប្រមុខរាជរដ្ឋាភិបាល។[135] រាល់ឯកសារដែលពាក់ព័ន្ធនឹងការស្នើសុំនោះ ត្រូវបានបញ្ជូនទៅដល់ប្រមុខរាជរដ្ឋាភិបាល ដើម្បីត្រួតពិនិត្យបន្ថែមសាជាថ្មីម្តងទៀត មុននឹងសម្រេចដាក់សំណើថ្វាយព្រះមហាក្សត្រសុំបន្ធូរបន្ថយទោស និងលើកលែងទោសឲ្យទណ្ឌិតយ៉ាងយឺតបំផុត ១០ (ដប់) ថ្ងៃមុនថ្ងៃកំណត់។[136]

មុនពេលទណ្ឌិតត្រូវបានដោះលែងឲ្យមានសិទ្ធិសេរីភាពរស់នៅក្នុងសង្គមសាជាថ្មីឡើងវិញ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីត្រូវរៀបចំបញ្ជូននូវព័ត៌មានទាំងនោះទៅកាន់ក្រសួងយុត្តិធម៌ជាមុនសិន ដើម្បីឲ្យក្រសួងយុត្តិធម៌ធ្វើការចាត់ចែងបញ្ជូនព្រះរាជក្រឹត្យបន្ធូរបន្ថយទោស និងការលើកលែងទោសនោះទៅកាន់ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមានសមត្ថកិច្ចក្នុងអនុវត្តបន្ត។[137]

ចំពោះទណ្ឌិត ដែលត្រូវបានលើកលែងទោស ដោយព្រះរាជក្រឹត្យនឹងត្រូវដោះលែងឲ្យមានសេរីភាពវិញភ្លាមដោយប្រធានពន្ធនាគារបន្ទាប់ពីទទួលបានដីកាបង្គាប់ឲ្យដោះលែងទណ្ឌិតរបស់ព្រះរាជអាជ្ញានៃអង្គការអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលមានសមត្ថកិច្ច។[138]

ម្យ៉ាងវិញទៀតចំពោះទណ្ឌិត ដែលត្រូវបានបន្ធូរបន្ថយទោសដោយព្រះរាជក្រឹត្យ និងលើកលែងឲ្យទណ្ឌិតនោះរួចផុតពីការអនុវត្តទោស សម្រាប់រយៈពេលដែលត្រូវបានបន្ធូរបន្ថយ ហើយព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងរាជធានី-ខេត្តដែលមានសមត្ថកិច្ច និងប្រធានពន្ធនាគារ ត្រូវធ្វើការប្រកាសផ្សព្វផ្សាយអំពីព្រះរាជក្រឹត្យបន្ធូរបន្ថយទោស ដល់ទណ្ឌិតដែលត្រូវបានបន្ធូរបន្ថយទោសនោះ។[139] ការផ្សព្វផ្សាយព្រះរាជក្រឹត្យនេះដល់ទណ្ឌិត គឺដើម្បីឲ្យទណ្ឌិតបានដឹងមុន និងងាយស្រួលក្នុងការរៀបចំខ្លួនមុនពេលត្រូវបានដោះលែង។

រីឯការបន្ធូរបន្ថយទោស និងលើកលែងទោស មិនមែនជាឧបសគ្គដល់សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលសំណងជួសជុលការខូចខាតនោះទេ លើកលែងតែមានបទប្បញ្ញត្តិផ្ទុយនឹងព្រះរាជក្រឹត្យដែលពាក់ព័ន្ធនឹងការបន្ធូរបន្ថយ និងការលើកលែងនោះ។[140] ដូច្នេះ ការអនុវត្តការបន្ធូរបន្ថយទោស និងការលើកលែងទោស នៅតែប្រព្រឹត្តប្រសិនបើទណ្ឌិតបានអនុវត្តតាមលក្ខខណ្ឌដែលច្បាប់បានកំណត់។

[135] ច្បាប់ស្តីពីពន្ធនាគារ, លេខ នស/រកម/១២១១/០២១ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១, មាត្រា៧៤។

[136] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១, មាត្រា១៣ ។

[137] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១, មាត្រា១៤ និង១៥ ។

[138] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១, មាត្រា១៦ (កថាខណ្ឌទី១) ។

[139] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១, មាត្រា១៦ (កថាខណ្ឌទី២) ។

[140] ព្រះរាជក្រឹត្យស្តីពី ការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២១, មាត្រា១៧ ។

### ១.៣.៣. ការលើកលែងទោសជាទូទៅ

ការលើកលែងទោសជាទូទៅ គឺជាសិទ្ធិផ្តាច់មុខរបស់អង្គការនីតិបញ្ញត្តិ (រដ្ឋសភា) ដូចមានចែងក្នុងមាត្រា ៩០ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ។ ការលើកលែងទោសជាទូទៅនេះ គឺជាអំណាចរបស់អង្គការនីតិបញ្ញត្តិបានផ្តល់ឲ្យទាំងទណ្ឌិត ទាំងជនល្មើស ទោះបីជាកំពុងជាប់ពន្ធនាគារក្តី ឬ មិនទាន់ជាប់ពន្ធនាគារក្តី ឬ ទើបនឹងត្រូវបានអយ្យការចោទប្រកាន់ក្តី ឬមិនទាន់ចាប់ផ្តើមចោទក្តីឲ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ និងទោសពិន័យ។[141]

ការលើកលែងជាទូទៅនេះធ្វើឡើងដើម្បីលុបបំបាត់ទោសដែលស្តែងឡើង ក្រោមរូបភាពជាច្បាប់ក្នុងគោលបំណងដោះលែងទណ្ឌិតចេញពីការជាប់ឃុំពន្ធនាគារ ឬជនល្មើសដែលមានចំនួនកាន់តែច្រើនឡើងៗ ដែលធ្វើឲ្យមានសំណុំរឿងកើនឡើងកាន់តែច្រើនហូរហែរ។ ម្យ៉ាងវិញទៀត ការលើកលែងជាទូទៅនេះមិនសំដៅទៅលើជនល្មើសណាមួយ ឬទណ្ឌិតណាមួយនោះទេ គឺគេគិតទៅលើប្រភេទ និងអំពើនៃបទល្មើសដែលជនល្មើស ឬទណ្ឌិតបានប្រព្រឹត្តតែប៉ុណ្ណោះ។[142] ក្នុងនោះការលើកលែងទោសជាទូទៅដូចមានចែងក្នុងមាត្រា ៩០ ថ្មី (ពីរ) វាក្យខណ្ឌទី៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាលុបបំបាត់ចោលនូវទណ្ឌកម្មដែលពាក់ព័ន្ធនឹងច្បាប់ស្តីពីការលើកលែងទោសជាទូទៅ។[143]

ម្យ៉ាងវិញទៀតនៅពេលដែលច្បាប់ស្តីពីការលើកលែងទោសជាទូទៅចូលជាធរមានហើយ នោះការលើកលែងទោសជាទូទៅត្រូវមានអានុភាពនៃការលើកលែងទោសជាទូទៅ ដែលនាំឲ្យមានការលុបចោលការសម្រេចទាំងស្រុង។

#### ១.៣.៣.១. ច្បាប់ស្តីពីការលើកលែងទោសជាទូទៅ

ច្បាប់ស្តីពីការលើកលែងទោសជាទូទៅអាចត្រូវបានអនុម័ត ដោយសារតែមូលហេតុចាំបាច់ច្រើនយ៉ាងដូចជា ដើម្បីកាត់បន្ថយចំនួនទណ្ឌិតក្នុងពន្ធនាគារច្រើនពេក ឬហេតុការណ៍សំខាន់ផ្សេងៗក្នុងប្រទេស។[144] ការអនុគ្រោះអាចទុកពេល ០៦ (ប្រាំមួយ) ខែ ក្រោយពីតុលាការប្រកាសឲ្យចូលជាធរមាន ហើយជនដែលជាសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអនុញ្ញាតឲ្យវិលត្រលប់មករស់នៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលក្នុងព្រះរាជាណាចក្រកម្ពុជាវិញ ដោយមិនយកទោសពៃរចំពោះបទល្មើសដែលជននោះបានប្រព្រឹត្តនោះទេ។

---

[141] នីតិព្រហ្មទណ្ឌទូទៅ , រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ាង ឡេង, ការលើកលែងទោសជាទូទៅ, ទំព័រ ១០៥ ,។

[142] នីតិព្រហ្មទណ្ឌទូទៅ , រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ាង ឡេង, លក្ខណៈនៃការលើកលែងទោសជាទូទៅ, ទំព័រ ១០៥។

[143] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៩។

[144] នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ, កែសម្រួលដោយ ចាំង ស៊ីណាត,២០១២, ៤៧៧។

ជាពិសេស ការកំណត់យ៉ាងច្បាស់លាស់ពីកាលបរិច្ឆេទនៃការប្រព្រឹត្តបទល្មើសដែលត្រូវលើកលែងទោស និងការកំណត់នូវលក្ខខណ្ឌឲ្យសមាជិកអង្គការនយោបាយ ឬជាកម្លាំងយោធានៃក្រុមកម្ពុជាប្រជាធិបតេយ្យចូលមករស់នៅក្រោមការគ្រប់គ្រងរបស់រាជរដ្ឋាភិបាល ដើម្បីទទួលបាននូវផលប្រយោជន៍ពីការលើកលែងទោសជាទូទៅនេះ។

**១.៣.៣.២. អានុភាពនៃការលើកលែងទោសជាទូទៅ**

ការលើកលែងទោសជាទូទៅលុបបំបាត់ជាស្ថាពរនូវមូលទោស និងទោសបន្ថែមនៃបទល្មើសក្នុងលក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ ក៏ប៉ុន្តែការលើកលែងទោសជាទូទៅនេះធ្វើឡើងចំពោះតែបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តមុនពេលច្បាប់នោះប្រកាសផ្សាយជាសាធារណៈតែប៉ុណ្ណោះ។[145] ជាគោលការណ៍ច្បាប់ស្ដីពីការលើកលែងទោសជាទូទៅត្រូវតែមានអានុភាពក្នុងការលុបបំបាត់នូវទោសទណ្ឌកម្មទាំងអស់ ដោយមិនឲ្យនៅសល់ឡើយ។[146]

អានុភាពនៃការលើកលែងទោសជាទូទៅតែងកើតមានឡើងចំពោះទោសដែលទទួលបានការលើកលែងទោស ហើយមិនទាន់ត្រូវបានវិនិច្ឆ័យដោយតុលាការនោះទេ ដូច្នេះបណ្ដឹងអាជ្ញានឹងត្រូវរលត់ ហើយតុលាការមិនអាចសម្រេចផ្ដន្ទាទោសលើចារីបានឡើយ។ ក្នុងការបើការលើកលែងទោសជាទូទៅ ដោយអនុលោមទៅតាមអត្រានៃទោសដែលប្រកាស តុលាការត្រូវប្រកាសទោសជាមុនសិនទើបអាចដឹងថាទោសណាដែលអាចត្រូវបានលើកលែងខ្លះ។

ម្យ៉ាងទៀតប្រសិនបើការផ្ដន្ទាទោសចូលជាស្ថាពរហើយ ក៏ការផ្ដន្ទាទោសទាំងអស់ត្រូវទុកជាឥតបានការ ដោយមិនអាចយកមកអនុវត្តបានឡើយ។[147] មួយវិញទៀត បើទណ្ឌិតកំពុងតែរងទោសដាក់ពន្ធនាគារ ទណ្ឌិតនឹងត្រូវទទួលបានការដោះលែងឲ្យមានសេរីភាពឡើងវិញភ្លាម។[148]

ចំពោះការលើកលែងទោសជាទូទៅនេះមិនមែនជាឧបសគ្គក្នុងការទាមទារសំណងជម្ងឺចិត្តពីសំណាក់ជនរងគ្រោះនោះទេ។[149] ប៉ុន្តែប្រសិនបើទណ្ឌិតបានបង់ប្រាក់ពិន័យរួចហើយ ទណ្ឌិតពុំអាចទាមទារឲ្យសងវិញនូវប្រាក់ទាំងនោះ ពេលរួចទោសនោះទេ។

---

[145] នីតិព្រហ្មទណ្ឌទូទៅ , រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ាង ឡេង, ទំព័រ ១០៥។

[146] នីតិព្រហ្មទណ្ឌទូទៅ , រៀបរៀងដោយសាស្ត្រាចារ្យ ហ៊ាង ឡេង, ទំព័រ ១០៥។

[147] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៩ (កថាខណ្ឌទី២) ។

[148] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៤៩ (កថាខណ្ឌទី៣) ។

[149] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៥១។

### ១.៣.៣.៣. មរណភាពរបស់ជនជាប់ទោស

ការរលត់ទោសដោយមូលហេតុមរណភាព គឺទាញចេញពីគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលបានបញ្ញត្តថាទោសត្រូវយកមកអនុវត្តតែចំពោះជនប្រព្រឹត្តកំហុសផ្ទាល់ខ្លួនតែប៉ុណ្ណោះ។[150] ទោសដែលអាចរលត់បាន គឺជាទោសដាក់ពន្ធនាគារ ចំណែកឯទោសពិន័យជាប្រាក់ និងការរឹបអូសផ្សេងៗទៀត នៅតែអាចបន្តអនុវត្តបានជាដដែល ពីព្រោះថាថ្វីត្បិតតែនៅពេលដែលជនជាប់ទោសបានទទួលមរណភាពហើយក៏ដោយ ក៏បេតិកភណ្ឌរបស់គាត់ទាំងទ្រព្យសម្បត្តិ និងទ្រព្យអកម្មត្រូវតែផ្ទេរទៅឲ្យសន្តតិជនរបស់គាត់តាមច្បាប់។[151]

សរុបមក សន្តតិជននៅតែជាប់កាតព្វកិច្ចនេះ ដែលតម្រូវឲ្យបង់នូវប្រាក់ពិន័យ និងត្រូវប្រគល់វត្ថុដែលត្រូវរឹបអូសមកវិញតាមរយៈអំណាចនៃសេចក្ដីសម្រេចរបស់តុលាការ។[152]

[150] នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ទំព័រ ៤៩២។

[151] នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ទំព័រ ៤៩៣។

[152] នីតិព្រហ្មទណ្ឌទូទៅ, រុន ពណ្ណារិទ្ធ, កែសម្រួលដោយ ចាំង ស៊ីណាត, ២០១២, ទំព័រ ៤៩៤។

# ជំពូកទី២
# ការព្យួរទោស

# ជំពូកទី២

# ការព្យួរទោស

## ២.១. សញ្ញាណទូទៅនៃការព្យួរទោស

### ២.១.១. អត្ថន័យ

ការព្យួរទោស សំដៅដល់ករណីដែលតុលាការបានប្រកាសអំពីការព្យួរនូវការអនុវត្តទោសចំពោះមូលទោសទៅលើជនជាប់ចោទដែលទទួលបានការជំនុំជម្រះរួច។[153] កាលណាតុលាការយល់ឃើញថាបទល្មើស, ស្ថានភាពនៃការប្រព្រឹត្តបទល្មើសរបស់ជនជាប់ចោទ, ទម្ងន់នៃទោសដែលត្រូវផ្តន្ទាទោសទៅលើជនជាប់ចោទបានបំពេញគ្រប់លក្ខខណ្ឌតាមបទប្បញ្ញត្តិនៅក្នុងក្រមព្រហ្មទណ្ឌ នោះតុលាការអាចចេញនូវសេចក្តីសម្រេចអំពីការព្យួរទោសទៅដល់ជនជាប់ចោទ។[154] ការព្យួរការអនុវត្តទោស ដែលជាមូលទោសនេះ តុលាការអាចប្រកាសការព្យួរការអនុវត្តនូវមូលទោសទាំងស្រុងឬមួយផ្នែក។[155] ចំពោះរបបគតិយុត្តនៃការព្យួរនូវការអនុវត្តទោស ក្រមព្រហ្មទណ្ឌមិនអនុញ្ញាតឲ្យធ្វើឡើយចំពោះទោសដែលជាប្រភេទទោសបន្ថែម ឬទោសជំនួស។ ម្យ៉ាងទៀត ការព្យួរទោសគឺជាការលើកចោលដោយមានលក្ខខណ្ឌនូវការអនុវត្តមូលទោសដែលត្រូវបានប្រកាសដោយតុលាការដែលមានន័យថាជាការអនុញ្ញាតឲ្យជនជាប់ពិរុទ្ធ ដែលត្រូវបានតុលាការផ្តន្ទាទោស អាចមិនអនុវត្តទោសនេះបានប្រសិនបើមិនប្រព្រឹត្តបទល្មើសថ្មីផ្សេងទៀត ក្នុងរយៈពេលដែលបានកំណត់ណាមួយ។

ស្របគ្នាផងដែរពាក់ព័ន្ធនឹង "របបនៃការព្យួរទោស" មិនត្រូវគិតអំពីបណ្តឹងរដ្ឋប្បវេណីឡើយ ព្រោះបណ្តឹងអាជ្ញា គឺជាបណ្តឹងព្រហ្មទណ្ឌ។[156] បើយោងតាមមាត្រា ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌខ្មែរឆ្នាំ ២០០៧ ស្តីអំពី "បណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី" បានចែងយ៉ាងច្បាស់ថាបណ្តឹងអាជ្ញា និងបណ្តឹងរដ្ឋប្បវេណី គឺជាបណ្តឹងពីរផ្សេងដាច់ពីគ្នា។ បណ្តឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាព(ការកើតមាន) នៃបទល្មើសបង្ហាញឲ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់។ រីឯបណ្តឹងរដ្ឋប្បវេណីមានគោលបំណងក្នុងការជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើល្មើសដល់ភាគីរងគ្រោះ ហើយអាចធ្វើឲ្យអ្នករងគ្រោះទទួលបាននូវសំណងជម្ងឺចិត្តឲ្យបានសមល្មមនឹងព្យសនកម្មដែលខ្លួនបានទទួលរង។

គោលគំនិតនៃការព្យួរទោសគឺជាការព្យួរការអនុវត្តទោសដែលត្រូវបានប្រកាសរួចហើយ ឬជាការលើកលែងនូវការអនុវត្តទោសមួយចំណែក ឬទាំងស្រុង លើកលែងតែមានការដកហូតការព្យួរទោសនោះវិញកាលណាលក្ខខណ្ឌនៃការដកហូតត្រូវបានបំពេញ។ គោលគំនិតសំខាន់មួយទៀត ជាការព្រមានមួយ

---

[152] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៤។

[154] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៤។

[155] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៨។

[156] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៥។

យ៉ាងច្បាស់លាស់ និងគ្រប់គ្រាន់ដោយដាក់មកលើទណ្ឌិតនូវការគំរាមដ៏ជាក់លាក់ ដែលជាការអនុវត្តទោសភ្លាមៗ។

សញ្ញាណនៃការព្យួរទោសនេះ មិនមែនថ្មីស្រឡាងឡើយនៅក្នុងនីតិព្រហ្មទណ្ឌខ្មែរ ព្រោះសញ្ញាណនេះធ្លាប់មានរួចមកហើយនៅក្នុងក្រមព្រហ្មទណ្ឌខ្មែរឆ្នាំ១៩២៩ នាសម័យដែលបារាំងបានដាក់អាណានិគមមកលើកម្ពុជា។ ដូចគ្នាផងដែរ សញ្ញាណនេះក៏បានលេចឡើងនៅក្នុងមាត្រា ៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលនាសម័យអ៊ុនតាក់។ គេបែងចែកការព្យួរទោសជាពីរប្រភេទគឺ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។[157]

ឧទាហរណ៍ថានៅក្នុងការជំនុំជម្រះក្តីក្នុងសវនាការជនជាប់ចោទម្នាក់ត្រូវតុលាការថ្នាក់ក្រោមផ្តន្ទាទោសដាក់ពន្ធនាគារ ១០ ឆ្នាំ ប៉ុន្តែជននោះប្តឹងមកសាលាឧទ្ធរណ៍ហើយត្រូវសាលាឧទ្ធរណ៍ឲ្យអនុវត្តទោសក្នុងពន្ធនាគារ ៨ ឆ្នាំសល់ ២ ឆ្នាំព្យួរ។ ឧបមាថាជនជាប់ចោទនោះអនុវត្តទោសក្នុងពន្ធនាគារគ្រប់ ៨ ឆ្នាំហើយដោយឡែកនៅសល់ទោសព្យួរ ២ ឆ្នាំទៀត តើគាត់ត្រូវបានដោះលែងពីពន្ធនាគារទេបើទោស ២ ឆ្នាំត្រូវព្យួរហើយនោះ? ឬក៏ចាំគ្រប់ ២ ឆ្នាំទៀតទើបតុលាការចេញដីកាដោះលែង?

ករណីនេះប្រសិនបើតុលាការប្រកាសទោស ១០ ឆ្នាំហើយទោសនោះត្រូវដាក់ពន្ធនាគារ ៨ ឆ្នាំ ឯទោសព្យួរ ២ ឆ្នាំទៀតត្រូវ បានព្យួរមានន័យថានៅពេលដែលជនជាប់ចោទអនុវត្តទោសក្នុងពន្ធនាគារ ៨ ឆ្នាំចប់ហើយហើយនៅសល់ទោសព្យួរ ២ ឆ្នាំទៀតក៏នឹងត្រូវដោះលែងជនជាប់ចោទនោះពីពន្ធនាគារដែរ។ ការដោះលែងជនជាប់ចោទពីពន្ធនាគារដោយសាររបបនៃការព្យួរទោសគឺមានអត្ថន័យ ២ ផ្សេងគ្នាដាច់ស្រឡះ ព្រោះថាការព្យួរទោសគឺតុលាការរកឃើញថាមានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថាជនជាប់ចោទបានប្រព្រឹត្តបទល្មើសដូចព្រះរាជអាជ្ញាចោទប្រកាន់ហើយតែពេលប្រកាសទោស តុលាការរកឃើញពីស្ថានសម្រាលទោស ដូចនេះតុលាការប្រកាសព្យួរទោសហើយទោសដែលប្រកាសនោះមិនអនុវត្តនៅក្នុងពន្ធនាគារទេ។

### ២.១.២. ប្រភេទនៃការព្យួរទោស

យោងតាមក្រមព្រហ្មទណ្ឌ ការព្យួរទោសត្រូវបានគេបែងចែកជាពីរប្រភេទគឺ ការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង។

#### ២.១.២.១. ការព្យួរទោសធម្មតា

ការព្យួរទោសធម្មតា គឺជាការព្យួរទោសដែលមិនមានដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើននោះទេ។[158] ការព្យួរទោសគឺជាវិធានការមួយ ដែលតុលាការអាចអនុវត្តចំពោះជនជាប់ចោទណាម្នាក់ ហើយត្រូវសម្រេចដោយប្រុងប្រយ័ត្នបំផុត។ ការព្យួរទោសធម្មតានេះ

[157] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៤ ដល់មាត្រា ១២៣។

[158] ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧, មាត្រា ២២៣ និង មាត្រា ២២៦។

មិនអាចត្រូវបានអនុវត្តចំពោះទោសគ្រប់ប្រភេទបានឡើយ។ ម្យ៉ាងទៀតការព្យួរទោសធម្មតានេះ គឺធ្វើការព្យួរទោសលក្ខណៈទូទៅ ដោយមិនតម្រូវឲ្យជនជាប់ទោសណាមួយមានកាតព្វកិច្ចពិសេសនោះទេ ក៏ប៉ុន្តែជនជាប់ទោសមិនត្រូវប្រព្រឹត្តបទល្មើសផ្សេងទៀត។ ប្រសិនបើជនជាប់ទោសបានប្រព្រឹត្តបទល្មើសណាមួយ ក្នុងអំឡុងពេលព្យួរទោស នោះការព្យួរទោសនឹងត្រូវបានដកហូត ឬលើកចេញវិញ ហើយជននោះនឹងត្រូវអនុវត្តទោសទាំងពីរ គឺអនុវត្តទាំងទោសទី១ដែលបានព្យួរ និងទោសទី២ដែលខ្លួនទើបតែបានប្រព្រឹត្តក្នុងអំឡុងពេលព្យួរទោសនេះ។

ចំពោះលក្ខខណ្ឌទាក់ទងនឹងការផ្តន្ទាទោសជាមុន ក្នុងករណីដែលមានការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះការព្យួរទោសធម្មតាអាចត្រូវផ្តល់ឲ្យបាន ប្រសិនបើជនជាប់ចោទមិនទាន់មានការផ្តន្ទាទោសជាស្ថាពរឲ្យជាប់ពន្ធនាគារក្នុងរយៈពេល៥ (ប្រាំ) ឆ្នាំមុនអំពើល្មើស។[159] ការព្យួរទោសធម្មតា ត្រូវបានយកមកអនុវត្តទៅលើទោសដូចជា៖

១ - ទោសដាក់ពន្ធនាគារកាលបើទោសដែលប្រកាសនោះតិចជាង ឬស្មើនឹង ៥ (ប្រាំ) ឆ្នាំ។

២ - ទោសពិន័យជាប្រាក់។[160]

ការប្រកាសព្យួរទោស គឺជាសិទ្ធិអំណាចរបស់តុលាការ ក៏ប៉ុន្តែទោសដាក់ពន្ធនាគារ ដែលតុលាការអាចប្រកាសព្យួរបានទាល់តែទោសដាក់ពន្ធនាគារនោះ មានរយៈពេលយ៉ាងច្រើនបំផុត ៥ ឆ្នាំ។ ប្រសិនបើជនជាប់ចោទ ត្រូវបានតុលាការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារលើសពី៥ឆ្នាំ តុលាការមិនអាចប្រកាសការព្យួរទោសនេះបានទេ។ ពិសេសបើទោះបីជាទោសពន្ធនាគារនេះមានរយៈពេលត្រឹមតែ ៥ឆ្នាំ ឬ តិចជាង ៥ឆ្នាំក៏ដោយ តុលាការអាចប្រកាសព្យួរទោសបាន លុះត្រាតែជនល្មើសមិនធ្លាប់ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគារម្តងសោះ នៅក្នុងរយៈពេល៥ឆ្នាំមុនអំពើប្រព្រឹត្តបទល្មើសថ្មីនេះ។

### ២.១.២.២. ការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង គឺជាការព្យួរទោស ដែលមានអានុភាពធ្វើឲ្យជនជាប់ទោសត្រូវស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងត្រូវគោរពកាតព្វកិច្ចដោយឡែកមួយ ឬច្រើននៅក្នុងរយៈពេលណាមួយ។ ការព្យួរទោសសាកល្បងគឺ ជារបបនៃការប្រកាសទោសមួយក្នុងចំណោមរបបនៃការប្រកាសទោសដទៃទៀត ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ ហើយមានអានុភាពដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយ ឬច្រើនក្នុងរយៈពេលសាកល្បង។[161]

ការព្យួរទោសសាកល្បង មានភាពប្រហាក់ប្រហែលទៅនឹងការព្យួរទោសធម្មតាដែរ គ្រាន់តែការព្យួរទោសប្រភេទនេះមានរយៈពេលសាកល្បងមួយ ដែលក្នុងនោះមាន រយៈពេលពី ០១ (មួយ) ឆ្នាំ ទៅ ០៣ (បី)

---

[159] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៦។

[160] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៧។

[161] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៧ (កថាខណ្ឌទី២)។

ឆ្នាំ។[162] នៅក្នុងរយៈពេលសាកល្បង (១ឆ្នាំ ទៅ៣ឆ្នាំ) ប្រសិនបើជនល្មើសមិនគោរពតាមវិធានការត្រួតពិនិត្យ ឬតាមកាតព្វកិច្ច ដែលកំណត់ដោយតុលាការទេ ការព្យួរទោសនឹងត្រូវលើកចេញវិញ ហើយជនល្មើសត្រូវតែអនុវត្តទោស។ ប្រសិនបើជនល្មើសប្រព្រឹត្តបទល្មើសថ្មីណាមួយទៀត ក្នុងរយៈពេលសាកល្បងនេះ ការព្យួរទោសក៏ត្រូវលើកចេញវិញដូចគ្នាដែរ ហើយជនល្មើសត្រូវអនុវត្តទោសសម្រាប់បទល្មើសទាំងពីរដូចករណីព្យួរទោសធម្មតាដែរ។

## ២.២. បែបបទនៃការប្រកាសការព្យួរទោស

តុលាការអាចប្រកាសការព្យួរទោសណាមួយក្នុងចំណោមការព្យួរទោសទាំងពីរ ពោលគឺការព្យួរទោសធម្មតា និងការព្យួរទោសសាកល្បង ទៅលើជនជាប់ចោទ បានលុះណាតែលក្ខខណ្ឌទាំងឡាយ ត្រូវបានបំពេញគ្រប់គ្រាន់។ លក្ខខណ្ឌនេះត្រូវបានបែងចែកជាពីរគឺលក្ខខណ្ឌនៃការព្យួរទោសធម្មតា និងលក្ខខណ្ឌនៃការព្យួរទោសសាកល្បង ។

### ២.២.១. លក្ខខណ្ឌនៃការព្យួរទោសធម្មតា

ដូចបានបញ្ជាក់ពីខាងដើម ការព្យួរទោសធម្មតាគឺជាការព្យួរទោសដែលមិនមានដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវកាតព្វកិច្ចដោយឡែកមួយឬច្រើននោះទេ។

លក្ខខណ្ឌនៃការព្យួរទោសធម្មតា តម្រូវឲ្យផ្តោតសំខាន់ទៅលើការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម និងការចោទប្រកាន់ចំពោះបទលហុផងដែរ។

#### ២.២.១.១. ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម

ការព្យួរទោសធម្មតានេះ ចៅក្រមអាចធ្វើការប្រកាសបាន លុះត្រាតែបានបំពេញនូវលក្ខខណ្ឌសំខាន់ៗ ចំនួន ២(ពីរ) ព្រមទាំងចំនុចបន្ទាប់បន្សំផ្សេងទៀត ដែលមានដូចជា៖

- លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន
- លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ
- ការព្យួរទោសមួយផ្នែក
- ការដកហូតការព្យួរទោស
- ការមិនដកហូតការព្យួរទោស
- ការទុកជាអាសារបង់នូវការផ្តន្ទាទោស។

[162] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៧ ដល់មាត្រា ១២៣។

### ២.២.១.១.១. លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន

ចំពោះការចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ តុលាការអាចប្រកាសការព្យួរទោសធម្មតាបាន លុះត្រាតែជនជាប់ចោទនេះ មិនដែលមានការផ្តន្ទាទោសជាស្ថាពរពីមុនក្នុងរយៈពេល០៥ ឆ្នាំ[163] ដោយបានន័យថា ជនជាប់ចោទទទួលបាននូវការផ្តន្ទាទោសដាក់ពន្ធនាគារ ហើយបានចូលជាស្ថាពរលើសពីរយៈពេល ០៥ឆ្នាំមុន គិតរាប់ថយក្រោយពីថ្ងៃដែលជនជាប់ចោទនោះបានប្រព្រឹត្តបទល្មើសនាពេលបច្ចុប្បន្ន នោះតុលាការអាចសម្រេចក្នុងការប្រកាសការព្យួរទោសបាន ប៉ុន្តែប្រសិនបើក្នុងករណី ដែលគិតតាំងពីលើកមុនមកជាស្ថាពរ រហូតមិនទាន់ផុត ០៥ ឆ្នាំ ស្រាប់តែមានការប្រព្រឹត្តបទល្មើសលើកក្រោយទៀតគឺថាតុលាការមិនអាចយកករណីបទល្មើសក្រោយ នេះទៅធ្វើការប្រកាសការព្យួរទោសបានទេ។

ឧទាហរណ៍ ៖ ជនជាប់ចោទ "**ក**" នៅក្នុងរយៈពេល៤ (បួន) ឆ្នាំមុន គិតមកទល់នឹងថ្ងៃដែលតុលាការប្រកាស ទោសលើខ្លួនអំពីបទល្មើសថ្មីដែលខ្លួនបានប្រព្រឹត្ត ជនជាប់ចោទនេះបានប្រព្រឹត្តបទល្មើសហិង្សាដោយចេតនា និងត្រូវបានតុលាការប្រកាសផ្តន្ទាទោសជាស្ថាពររួចហើយ ដូចនេះទោសដែលនឹងត្រូវប្រកាសចំពោះបទល្មើសថ្មី ដែលជនជាប់ចោទ "**ក**" បានប្រព្រឹត្ត គឺមិនអាចប្រកាសដោយធ្វើការព្យួរទោសធម្មតាបានឡើយ។

### ២.២.១.១.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ

លក្ខខណ្ឌទោសដែលអាចនាំឲ្យមានការព្យួរទោសនេះសំដៅដល់ទោស ដែលត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលតិចជាង ឬស្មើនឹង ៥ ឆ្នាំ មានន័យថាត្រឹម ៥ ឆ្នាំ តុលាការប្រកាសថាជនជាប់ចោទមានទោសត្រូវដាក់ពន្ធនាគារត្រឹម ៥ ឆ្នាំ ឬក្រោមចំនួន៥ឆ្នាំ គឺតុលាការអាចជ្រើសរើសយកការព្យួរទោសនេះបាន។ ហើយករណីទោសពិន័យជាប្រាក់ ដែលជួនកាលតុលាការប្រកាសទោសពិន័យជាប្រាក់ ប្រសិនបើជាគាត់មិនចង់ឲ្យមានការអនុវត្តទេក៏គាត់អាចប្រកាសការព្យួរទោសបានដែរ។[164]

### ២.២.១.១.៣. ការព្យួរទោសមួយផ្នែក

ចំពោះការព្យួរទោសនេះ តុលាការអាចប្រកាសព្យួរទាំងស្រុងក៏បាន ឬព្យួរមួយផ្នែកក៏បានពីព្រោះតុលាការអាចសម្រេចថាការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសជាប់ពន្ធនាគារដែលតុលាការ គឺជាអ្នកកំណត់ចិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកមានសមត្ថកិច្ចក្នុងការកំណត់ចំនួនទឹកប្រាក់។[165] ក្នុងករណីប្រសិនបើតុលាការចង់ប្រកាសឲ្យព្យួរទោសមួយផ្នែកនោះគឺតុលាការត្រូវតែកំណត់ថារយៈពេលប៉ុន្មានដែលត្រូវឲ្យទណ្ឌិតអនុវត្ត និងរយៈពេលដែលតុលាការធ្វើការពិនិត្យសម្រេចតម្រូវឲ្យព្យួរមិនឲ្យជាប់ពន្ធនាគារ។

[163] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៦។

[164] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៧ ដល់មាត្រា ១០៧។

[165] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៧ ដល់មាត្រា ១០៨។

ឧទាហរណ៍ ៖ តុលាការប្រកាសទោសចំពោះទណ្ឌិតណាមួយ ដោយត្រូវផ្តន្ទាទោសដាក់ក្នុងពន្ធនាគារ ចំនួន៣ ឆ្នាំ ក្នុងករណីនេះ ប្រសិនបើតុលាការសម្រេចថាមិនចង់ឲ្យមានការព្យួរទាំងស្រុងទេ ត្រូវព្យួរចំនួន១ឆ្នាំ នោះគឺត្រូវព្យួរទោសចំនួន០១ ឆ្នាំ ចំណែក០២ ឆ្នាំទៀតគឺត្រូវអនុវត្តទោស។ តុលាការត្រូវតែប្រកាស និងកំណត់ឲ្យបានច្បាស់លាស់នៅក្នុងសាលក្រមថាផ្តន្ទាទោសដាក់ពន្ធនាគារ ៣ ឆ្នាំ ប៉ុន្តែ ១ ឆ្នាំ ត្រូវព្យួរនេះគឺត្រូវកំណត់ឲ្យជាក់លាក់។

តុលាការប្រកាសការព្យួរទោសមួយផ្នែកនេះគឺច្រើនតែមានការឃុំខ្លួនបណ្តោះអាសន្នដោយឧទាហរណ៍ បុគ្គលម្នាក់ត្រូវបានចៅក្រមស៊ើបសួរចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន។ ក្រោយពីបានឃុំខ្លួនបណ្តោះអាសន្នរួចហើយតុលាការសម្រេចដាក់ទោសពន្ធនាគារលើសពីចំនួនដែលឃុំខ្លួនបណ្តោះអាសន្ន ព្រោះឃុំខ្លួនបណ្តោះអាសន្នក្នុងករណីបទមជ្ឈិមច្បាប់កំណត់មិនឲ្យលើសពីកម្រិតពាក់កណ្តាលនៃអប្បបរមាឡើយដូចជា ៦ខែ គឺមិនឲ្យឃុំខ្លួនលើសពី ៣ ខែទេ។ ដូច្នេះហើយតុលាការសម្រេចព្យួរទោសមួយផ្នែកបានន័យថា ៣ខែ ដែលជាប់ឃុំខ្លួនបណ្តោះអាសន្ននោះត្រូវព្យួរទោស។

ចំពោះទោសពិន័យជាប្រាក់វិញក៏ដូចគ្នាដែរ បើកាលណាតុលាការប្រកាសទោសពិន័យជាប្រាក់ បើតុលាការមិនចង់ព្យួរទាំងស្រុងទេ ក៏អាចព្យួរមួយផ្នែកបានដូចគ្នា។ ហេតុនេះហើយ បើព្យួរមួយផ្នែកត្រូវកំណត់ចំនួនទឹកប្រាក់ទៅតាមអ្វីដែលគាត់ត្រូវព្យួរ។ នេះទាក់ទងនឹងការព្យួរទោសពិន័យមួយផ្នែក។

**២.២.១.១.៤. ការដកហូតការព្យួរទោស**

ប្រសិនបើក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតាហើយ មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ការព្យួរទោសធម្មតានេះត្រូវដកហូតពេលគឺត្រូវដកហូតដោយស្វ័យប្រវត្តិ។ ទោសទី១ ត្រូវអនុវត្តដោយមិនអាចស្រូបចូលជាមួយទោសទី២បានឡើយ។[166]

យោងទៅតាមអត្ថន័យខាងលើនេះ គឺបានសេចក្តីថាចំពោះការព្យួរទោសធម្មតា បើសិនជាក្នុងរយៈពេល ៥ ឆ្នាំ មិនទាន់ហួសរយៈពេល ៥ ឆ្នាំផងជននោះក៏ទៅប្រព្រឹត្តបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមណាមួយទៀត។

ដូច្នេះក្នុងករណីនេះប្រសិនបើមានសាលក្រម ឬ សាលដីកាក្រោយផ្តន្ទាទោសជាស្ថាពរធ្វើឲ្យដកហូតការព្យួរទោសដោយកំណត់នៅក្នុងសាលក្រមទី១ ដែលកំណត់ទោសនោះ គឺត្រូវដកហូតយកមកអនុវត្តទោសពេញលេញ និង សាលក្រមទី២ ដែលកំណត់នោះដែរត្រូវយកមកអនុវត្ត ដោយមិនត្រូវបានស្រូបបញ្ចូលគ្នាទេ។

[166] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១០៩។

### ២.២.១.១.៥. ការមិនដកហូតការព្យួរទោស

តុលាការអាចសម្រេចថាការផ្តន្ទាទោសថ្មីមិននាំឲ្យមានការដកហូតនូវការព្យួរទោសធម្មតាដែលបានសម្រេចពីមុននោះទេ។ សេចក្តីសម្រេចរបស់តុលាការត្រូវតែមានសំអាងហេតុជាពិសេស។[167] យោងតាមអត្ថន័យនេះ អាចបញ្ជាក់ឲ្យយល់អំពីខ្លឹមសារលម្អិតទាក់ទងនឹងការមិនដកហូតការព្យួរទោសកាន់តែច្បាស់ថាក្រមទុកសិទ្ធិឲ្យចៅក្រមដែរ ប្រសិនបើគាត់យល់ឃើញថាការផ្តន្ទាទោសក្រោយនេះ ទោះបីជាស្ថិតនៅក្នុងកម្រិតរយៈពេល ៥ ឆ្នាំ ដែលជននេះបានទៅប្រព្រឹត្តចំពោះសាលក្រមទី១ ដែលបានកំណត់ការព្យួររួចហើយក៏ដោយ បើពិនិត្យមើលទៅលើបទប្បញ្ញត្តិនៃមាត្រា ១០៩ ឃើញថាត្រូវមានការដកហូតការព្យួរទោស។

ប៉ុន្តែមាត្រា ១១០ នៃក្រមព្រហ្មទណ្ឌនេះ គឺបានចែងឲ្យចៅក្រមអាចមានសិទ្ធិក្នុងការសម្រេចមិនដកហូតការព្យួរទោសនោះបាន ដោយចែងយ៉ាងជាក់លាក់ នៅក្នុងសាលក្រមហើយសាលក្រមនេះត្រូវតែមានសំអាងហេតុជាពិសេស បើសិនជាគាត់យល់ឃើញថាមិនគួរដកហូតការព្យួរទោស ចៅក្រមត្រូវតែចែងក្នុងសាលក្រមឲ្យបានច្បាស់លាស់ ថាមិនមានការដកហូតការព្យួរទោសទេ ហើយក៏ត្រូវបញ្ជាក់អំពីសំអាងហេតុថាហេតុអ្វីបានខ្លួនមិនដកហូតការព្យួរទោស។

ឧទាហរណ៍ទី១ ៖ ជនម្នាក់ក្រីក្រខ្លាំងពេកក៏ទៅប្រព្រឹត្តបទលួច។ នៅពេលដែលនគរបាលយុត្តិធម៌ចាប់ខ្លួនបានក៏បញ្ជូនទៅតុលាការដើម្បីជំនុំជម្រះលើគាត់។ ពេលជំនុំជម្រះរួចចៅក្រមដែលមានមនុស្សធម៌ក៏សម្រេចព្យួរទោសជននេះ។ គាត់ក៏ខិតខំអប់រំកែប្រែខ្លួន ស្រាប់តែនៅថ្ងៃដែលជិតផុតពេលកំណត់របស់ច្បាប់ថាចំនួន ៥ ឆ្នាំនោះទៅហើយ គាត់ក៏អត់មានអ្វីពិសារទាល់តែសោះដោយសារតែគាត់ឃ្លានខ្លាំងពេក គាត់ក៏ទៅលួចគេម្តងទៀត ករណីថ្មីនេះតុលាការអាចមិនដកហូតការព្យួរទោសបាន។

ឧទាហរណ៍ទី២ ៖ គេវាយធ្វើបាបអ្នកមានគុណ (ឪពុក-ម្តាយ) យើងទាំងពីរយ៉ាងឃោរឃៅ យើងរំជួលចិត្តខ្លាំងពេកក៏ទៅវាយអ្នកនោះដើម្បីការពារពួកគាត់។ ក៏ប៉ុន្តែការការពាររបស់យើងគឺជាការការពារមិនស្របច្បាប់ ដូច្នេះតុលាការសម្រេចផ្តន្ទាទោសយើងរួចហើយតែត្រូវព្យួរទោសធម្មតា។ យើងក៏បានទៅកែខ្លួនយ៉ាងល្អ ស្រាប់តែអ្នកនោះចងគំនុំជាមួយអ្នកមានគុណយើង ក៏ទៅវាយធ្វើបាបគាត់ទៀតយើងក៏ទៅវាយអ្នកនោះវិញទៀតដែរ។ ករណីថ្មីនេះតុលាការក៏អាចមិនដកហូតការព្យួរទោសបានដែរ។

### ២.២.១.១.៦. ការទុកជាអសារបង់នូវការផ្តន្ទាទោស

ចំពោះការព្យួរទោសនេះ នៅពេលដែលផុតចិរវេលា ៥ ឆ្នាំបន្ទាប់ពីមានសាលក្រមកំណត់អំពីការព្យួរទោសនេះហើយគឺទោសនោះត្រូវចាត់ទុកជាអសារបង់ មានន័យថាគេលែងយកមកអនុវត្តតទៅទៀតហើយ ទោះបីជាទោសដាក់ពន្ធនាគារក្តី ឬទោសពិន័យជាប្រាក់ក្តី។[168] ព្រោះបើយោងតាមមាត្រា ១១១ បានចែងថា

---

[167] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១០។

[168] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១១។

*"ប្រសិនបើរយៈពេល ៥ (ប្រាំ) ឆ្នាំ បន្ទាប់ពីការផ្តន្ទាទោសជាស្ថាពរពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយមានការព្យួរទោសធម្មតាហើយក៏គ្មានការផ្តន្ទាទោសថ្មីជាស្ថាពរមួយទៀតពីបទឧក្រិដ្ឋ ឬបទមជ្ឈិមនោះទេ ការផ្តន្ទាទោសដោយមានព្យួរនេះត្រូវចាត់ទុកថាជា អសារបង់។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។*

*បើកាលណាការព្យួរទោស ត្រូវបានប្រកាសទៅលើតែផ្នែកមួយនៃទោស នោះការផ្តន្ទាទោសត្រូវចាត់ទុកជាអសារបង់ទាំងស្រុង។ ទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។"*

ខាងលើនេះ គឺសម្រាប់ទោសដែលទាក់ទងជាមួយនឹងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិម។

**២.២.១.២. ការចោទប្រកាន់ចំពោះបទលហុ**

ចំពោះការព្យួរទោសក្នុងបទលហុវិញ គឺមានលក្ខណៈខុសផ្លែកគ្នាខ្លះអំពីចិរវេលាដែលទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន។ វាគឺជាលក្ខខណ្ឌនៅក្នុងការចោទប្រកាន់អំពីបទលហុនេះគឺមាន ២ ដែរ ហើយក៏មានចំណុចសំខាន់ផ្សេងៗទៀតដូចគ្នានឹងការចោទប្រកាន់ចំពោះបទឧក្រិដ្ឋ ឬបទមជ្ឈិមដែរ គឺខុសត្រង់តែចិរវេលាប៉ុណ្ណោះ។ ភាពខុសគ្នានៃចិរវេលាចំពោះការចោទប្រកាន់ចំពោះបទលហុ និងបទឧក្រិដ្ឋ ឬបទមជ្ឈិមដូចជា៖

**២.២.១.២.១. លក្ខខណ្ឌទាក់ទងជាមួយនឹងការផ្តន្ទាទោសពីមុន**

ក្នុងករណីជននោះ មិនដែលទទួលការផ្តន្ទាទោសពីមុនក្នុងរយៈពេល០១ ឆ្នាំ មានន័យថាគាត់មិនត្រូវបានចៅក្រមផ្តន្ទាទោសណាមួយពីបទល្មើសណាមួយក្នុងរយៈពេល០១ ឆ្នាំទេ។ ប្រសិនបើមានការផ្តន្ទាទោសពីមុននៅក្នុងរយៈពេល០១ឆ្នាំមិនអាចយកការព្យួរទោសចំពោះបទលហុនេះមកប្រើបានទេ ពីព្រោះក្រមព្រហ្មទណ្ឌយើងបានបញ្ញត្តិថាក្នុងករណីចោទប្រកាន់ពីបទលហុការព្យួរទោសធម្មតាអាចត្រូវបានប្រកាស ប្រសិនបើជនជាប់ចោទមិនទាន់ត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារជាស្ថាពរនៅឡើយនៅក្នុងពេល ០១ ឆ្នាំមុនបទល្មើសនេះ។[169]

**២.២.១.២.២. លក្ខខណ្ឌទាក់ទងជាមួយនឹងទោសដែលអាចនាំឲ្យមានការព្យួរ**

ទោសអាចព្យួរបានចំពោះបទលហុនេះមានទាំងទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ពីព្រោះក្រមថ្មីបានចែងថា ក្នុងករណីចោទប្រកាន់ពីបទសហាការព្យួរទោសធម្មតាត្រូវអនុវត្តទៅលើទោសដូចតទៅនេះ៖

- ទោសដាក់ពន្ធនាគារ
- ទោសពិន័យជាប្រាក់។[170]

**២.២.១.២.៣. ការដកហូតការព្យួរទោស**

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំក្រោយការផ្តន្ទាទោសជាស្ថាពរពីបទលហុដោយមានការព្យួរទោសធម្មតាផង រួចកើតមានការផ្តន្ទាទោសថ្មីជាស្ថាពរពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ការព្យួរទោសធម្មតានេះត្រូវ

[169] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១២។

[170] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៣។

ដកហូតចេញដោយពេញច្បាប់។ ទោសទី ១ ត្រូវអនុវត្តដោយគ្មានស្រូបជាមួយទោសទី ២ ឡើយ។ ដូច្នេះការព្យួរទោសក្នុងបទលហុ បើគាត់បានប្រព្រឹត្តបទល្មើសថ្មីទៀត ទាំងបទឧក្រិដ្ឋក្តី បទមជ្ឈិមក្តី បទលហុក្តីនៅក្នុងរយៈពេល០១ឆ្នាំគិតពីពេលសាលក្រមលើកមុនចូលជាស្ថាពរមក ដែលមានការព្យួរទោសពីបទលហុនេះ គឺថាការដកហូតការព្យួរទោសនៃសាលក្រមមុនត្រូវដកហូតដោយពេញច្បាប់ ឬដោយស្វ័យប្រវត្តិ។

ដូចនេះសាលក្រមទី១ ត្រូវយកមកអនុវត្តបូកជាមួយនឹងសាលក្រមទី ២ គឺថាទោសទាំងប៉ុន្មានដែលសាលក្រមទី១ បានកំណត់និងសាលក្រមទី ២ បានកំណត់នឹងត្រូវអនុវត្តដោយបូកបញ្ចូលគ្នា ផ្ទុយទៅវិញគឺអត់មានស្រូបបញ្ចូលគ្នាទេ។[171]

### ២.២.១.២.៤. ការមិនដកហូតការព្យួរទោស

ដូចគ្នានឹងការចោទប្រកាន់ពីបទមជ្ឈិម និងបទឧក្រិដ្ឋដែរ ទាក់ទងជាមួយនឹងការមិនដកហូតអំពីការព្យួរទោសនេះ ប្រសិនបើជាចៅក្រមនោះយល់ឃើញថា ទោះបីជាទណ្ឌិតបានប្រព្រឹត្តបទ ល្មើសនៅក្នុងចិរវេលា ១ ឆ្នាំ បន្ទាប់ពីមានសាលក្រមព្យួរទោសលើកទី១ រួចក៏ដោយ ប្រសិនបើតុលាការយល់ឃើញថាមិនត្រូវដកហូតការព្យួរទោសធម្មតាហ្នឹងទេ គឺគាត់ត្រូវតែចែងឲ្យបានជាក់លាក់នៅក្នុងសាលក្រម និងមានចែងបញ្ជាក់អំពីសំអាងហេតុជាពិសេសផងដែរ[172] ព្រោះមកពីក្រមព្រហ្មទណ្ឌបានចែងដោយបង្ហាញថា ៖ ជាបដិប្បញ្ញត្តិនៃមាត្រា ១១៤ (ការដកហូតព្យួរទោស) នៃក្រមយើងនេះតុលាការអាចសម្រេចថាការផ្តន្ទាទោសថ្មី មិនអាចឲ្យមានការដកហូតនូវការព្យួរទោស ធម្មតានេះដែលសម្រេចពីមុននោះទេ។ សេចក្តីសម្រេចនេះត្រូវតែមានសំអាងហេតុជាពិសេស។

ឧទាហរណ៍ ៖ ជនម្នាក់មនុស្សស្រវឹងខ្ចួប គាត់បានប្រព្រឹត្តបទលហុមួយ ពោលគឺបទស្រវឹងជាក់ស្តែង។ តុលាការក៏ផ្តន្ទាទោសពិន័យជាប្រាក់ចំពោះគាត់ តែត្រូវបានព្យួរទោស។ លុះក្រោយមកគាត់ខំប្រឹងប្រែងកែខ្លួនដែរតែកែទៅមិនរួចដោយសារតែគាត់ដុសមេស្រារួចទៅហើយ ទើបគាត់ទៅប្រព្រឹត្ត "បទស្រវឹងជាក់ស្តែង" ម្តងទៀតដោយដើរឡូឡាពេញថ្នល់សាធារណៈទាំងខ្លួនឯងស្រវឹងជោគជាំ។ ហេតុនេះបើបែបហ្នឹងមែនតុលាការអាចសម្រេច មិនដកហូតការព្យួរទោសរបស់គាត់បាន។

### ២.២.១.២.៥. ការចាត់ទុកជាអសារបង់នូវការផ្តន្ទាទោស

ប្រសិនបើក្នុងរយៈពេល ១ (មួយ) ឆ្នាំបន្ទាប់ពីការផ្តន្ទាទោសចូលជាស្ថាពរពីបទហុ ដែលមានការព្យួរទោសធម្មតា ហើយក៏គ្មានការផ្តន្ទាទោសថ្មីណាមួយបានកើតឡើងពីបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុទេ ការផ្តន្ទាទោសដែលព្យួរនោះត្រូវទុកជាអសារបង់ រីឯទោសក៏មិនអាចយកមកអនុវត្តបានទៀតឡើយ។ ដូច្នេះ

---

[171] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៤។

[172] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៥។

ប្រសិនបើជាហួសរយៈពេល០១ ឆ្នាំ ផុតពីសាលក្រមដែលបានកំណត់អំពីការព្យួរទោសស្តីពីបទលហុនោះបាន កន្លងផុតទៅគឺទោសនេះត្រូវទុកជាអសារបង់ មានន័យថាលែងយកទោសមកអនុវត្តទៀតហើយ។[173]

### ២.២.២. លក្ខខណ្ឌនៃការព្យួរទោសសាកល្បង

ការព្យួរទោសសាកល្បង គឺជាការដាក់ឲ្យទណ្ឌិតស្ថិតនៅក្រោមវិធានការត្រួតពិនិត្យ និងគោរពនូវលក្ខខណ្ឌដោយឡែកមួយ ឬច្រើនក្នុងរយៈពេលព្យួរទោសសាកល្បងមុនអនុវត្តទោសព្យួរ។ ការព្យួរទោសសាកល្បងមានលក្ខណៈខុសគ្នាជាមួយការព្យួរទោសធម្មតា។

ដើម្បីអាចព្យួរទោសសាកល្បងបាន ទាល់តែទណ្ឌិតនេះត្រូវបានតុលាការគាត់ប្រកាសទោសនៅចន្លោះពី ៦ខែ ទៅ ៥ឆ្នាំ មានន័យថាទោសដែលគាត់ត្រូវបានទទួលរងដូចជាតុលាការយល់ឃើញថាដាក់គុកគាត់ ១(មួយ) ឆ្នាំ ឬមួយក៏ ៤ (បួន) ឆ្នាំ បែបនេះគឺនៅចន្លោះពី ៦ខែទៅ ៥ ឆ្នាំ។[174] ដូច្នេះតុលាការអាចជ្រើសរើសយកនូវការព្យួរទោសសាកល្បងបានពីព្រោះមាត្រា ១១៧ កថាខណ្ឌទី ១ កំណត់ថាតុលាការអាចសម្រេចព្យួរសាកល្បងនូវទោស ដែលបានសម្រេចដាក់ពន្ធនាគារដែលមានរយៈពេលពី ៦ខែ ទៅ ៥ ឆ្នាំ។

#### ២.២.២.១. រយៈពេលនៃការព្យួរទោសសាកល្បង

ចំពោះថិរវេលាដែលតុលាការកំណត់ឲ្យសាកល្បងនោះ អាចកំណត់មិនឲ្យតិចជាងមួយឆ្នាំ ហើយក៏មិនឲ្យលើសពីបីឆ្នាំដែរ ដូច្នេះត្រូវនៅចន្លោះពី ១ឆ្នាំ ទៅ ៣ឆ្នាំ តុលាការអាចកំណត់ថិរវេលាឲ្យគាត់សាកល្បងគឺៈ

- ទីមួយៈ បំពេញនូវកាតព្វកិច្ចដោយឡែកមួយឬច្រើនដែលតុលាការកំណត់។
- ទីពីរៈ ស្ថិតនៅក្រោមវិធានការត្រួតពិនិត្យទាំងឡាយដែលច្បាប់បានកំណត់។

ដូច្នេះនៅក្នុងការព្យួរទោសសាកល្បងនេះ តុលាការត្រូវកំណត់ថិរវេលាថាប៉ុន្មានឆ្នាំដែលគាត់ត្រូវមានរយៈពេលសាកល្បង។ រយៈពេលនេះអាច ១ ឆ្នាំ ឬ ២ ឆ្នាំ មិនអាចលើស ឬខ្វះនោះទេ។[175]

#### ២.២.២.២. វិធានការត្រួតពិនិត្យ និងកាតព្វកិច្ចដោយឡែក

##### ២.២.២.២.១. វិធានការត្រួតពិនិត្យ

វិធានការត្រួតពិនិត្យដែលតម្រូវទៅលើទណ្ឌិតត្រូវបានសម្រេចដោយតុលាការដែលមានដូចតទៅៈ

- ទណ្ឌិតត្រូវគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។
- ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យ។
- ទណ្ឌិតត្រូវមកប្រគល់ដល់ព្រះរាជអាជ្ញា ឬដល់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឲ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ជូលឲ្យទៅរស់នៅក្នុងសង្គមវិញ។

---

[173] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៦។

[174] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៧។

[175] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៨។

- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាអំពីការផ្លាស់ប្តូរអាសយដ្ឋានរបស់ខ្លួន។
- ទណ្ឌិតត្រូវជូនដំណឹងដល់ព្រះរាអាជ្ញាអំពីការផ្លាស់ប្តូរមុខរបររបស់ខ្លួន។
- ទណ្ឌិតត្រូវតែមានការអនុញ្ញាតពីព្រះរាជអាជ្ញាមុនពេលធ្វើដំណើរទៅបរទេស។[176]

ចំនុចខាងលើទាំងអស់នេះ គឺជាវិធានការត្រួតពិនិត្យដែលតុលាការដាក់ទៅលើទណ្ឌិតមួយណា ដែលត្រូវបានប្រកាសអំពីការព្យួរទោសសាកល្បង។

### ២.២.២.២.២. ភារកិច្ចដោយឡែក

ក្រៅពីវិធានការត្រួតពិនិត្យ ដែលតុលាការដាក់ទៅលើទណ្ឌិត តុលាការក៏អាចដាក់កាតព្វកិច្ចដោយឡែក ចំពោះទណ្ឌិតផងដែរ ដែលមានដូចជា៖

- បំពេញសកម្មភាពខាងវិជ្ជាជីវៈ។
- ទទួលការបង្ហាត់បង្រៀនឬទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- រស់នៅក្នុងទីកន្លែងណាមួយជាកំណត់។
- បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។
- ធ្វើការជួសជុលការខូចខាតដែលបណ្តាលមកពីបទល្មើសតាមលទ្ធភាពនៃធនធានរបស់ខ្លួន។
- បញ្ជាក់ថាខ្លួនបានបង់ប្រាក់ជូនរដ្ឋបន្ទាប់ពីការផ្តន្ទាទោសតាមលទ្ធភាពនៃធនធានរបស់ខ្លួន។
- មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈឬសង្គមដែលអនុញ្ញាត ឬសម្រួលដល់ការប្រព្រឹត្តបទល្មើស។ ក្នុងករណីនេះ តុលាការបញ្ជាក់អំពីសកម្មភាពដែលហាមឃាត់។
- មិនត្រូវមានមុខនៅទីកន្លែងខ្លះ។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីទីកន្លែងដែលហាមឃាត់។
- មិនត្រូវសេពគប់បនល្បែង។
- មិនត្រូវសេបគប់តៀមភេសជ្ជៈស្រវឹង។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ពិសេសចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។ ក្នុងករណីនេះតុលាការបញ្ជាក់អំពីបុគ្គល ដែលមិនត្រូវសេពគប់ជាមួយ។
- មិនត្រូវកាន់កាប់ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។[177]

នៅក្នុងសេចក្តីសម្រេចរបស់ខ្លួន តុលាការគាត់ត្រូវចែងអំពីកាតព្វកិច្ចដោយឡែក ដែលតម្រូវទៅលើទណ្ឌិត។ រីឯកាតព្វកិច្ចដោយឡែករួមទាំងអស់ចំនួន ១៣ ចំណុចខាងលើនេះគឺតុលាការអាចប្រកាសយកមួយ ឬច្រើនទៅ តាមអ្វីដែលគាត់យល់ឃើញថាគួរដាក់ឲ្យទណ្ឌិតនេះបំពេញ។ តែប្រសិនបើគាត់មិនអាច បំពេញបានទេនោះ គឺថាចៅក្រមអាចនឹងដកហូតអំពីការព្យួរទោសសាកល្បងនោះចោលវិញបាន។ ដូច្នេះហើយមាត្រា ១២០

[176] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១១៩។

[177] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១២០។

នេះជាកាតព្វកិច្ចដោយឡែកដែលតុលាការរើសយកមកដាក់ដោយក្នុងនោះគាត់ត្រូវមើលថា តើអ្វីដែលពាក់ព័ន្ធជាមួយនឹងជននោះ ដែលគាត់បានប្រព្រឹត្តបទល្មើស។ ចៅក្រមមិនមែនចេះតែដាក់ទាំងអស់តាមតែចិត្តចង់នឹកឃើញដាក់ទៅលើគេនោះទេ តែគាត់អាចរើសដាក់មួយ ឬច្រើនលើសពីមួយបាន។ កាតព្វកិច្ចនេះគឺដាក់តែទៅលើនីតិជនដែលគាត់ប្រព្រឹត្តបទល្មើសប៉ុណ្ណោះ ពីព្រោះថាបទប្បញ្ញត្តិនៃមាត្រា ១២០ នេះគឺចែងចំពោះនីតិជន។

ឯចំពោះអនីតិជនវិញ កាតព្វកិច្ចដោយឡែកទាំង ៩ (ប្រាំបួន) ចំណុចដែលអាចអនុវត្តទៅលើអនីតិជនមានដូចជា៖

- ទទួលការបង្ហាត់បង្រៀនឬការបណ្តុះបណ្តាលវិជ្ជាជីវៈ។
- ស្ថិតនៅទីកន្លែងមួយជាកំណត់។
- ដាក់ខ្លួនឲ្យពេទ្យពិនិត្យ ឬព្យាបាល។
- ជួសជុលព្យសនកម្មដែលអាចបណ្តាលមកអំពីបទល្មើសទៅតាមធនធានរបស់ខ្លួន។
- បង្ហាញភស្តុតាងបញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួនបន្ទាប់ពីផ្តន្ទាទោស។
- មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ។
- មិនត្រូវសេពគប់ទីកន្លែងលក់ភេសជ្ជៈស្រវឹង។
- មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះដោយឡែកជាមួយសហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស។
- មិនត្រូវកាន់កាប់ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទ។[178]

កាតព្វកិច្ចទាំង ៩ (ប្រាំបួន) ចំណុចខាងលើ គឺជាកាតព្វកិច្ចដោយឡែកដែលប្រើចំពោះអនីតិជន។

### ២.២.២.២.៣. ការកែប្រែកាតព្វកិច្ចដោយឡែក

យុត្តាធិការគឺជាតុលាការ ឬស្ថាប័នទទួលបន្ទុកចាត់ការរឿងក្តីសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។ នៅគ្រប់ពេលវេលា តុលាការអាចធ្វើការកែប្រែកាតព្វកិច្ចដោយឡែកដែលតម្រូវលើទណ្ឌិតបានមានន័យថា នៅពេលដែលកាតព្វកិច្ចណាមួយលែងសមស្របតទៅទៀតហើយ តុលាការអាចកែប្រែកាតព្វកិច្ចនោះឲ្យសមស្របទៅតាមស្ថានភាពជាក់ស្តែងវិញ។[179]

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌ ដែលបានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាការលំបាកទាំងឡាយដែលទាក់ទងនឹងការអនុវត្តទោសត្រូវតែលើកជូនតុលាការជាន់ដំបូង ឬតុលាការជាន់ខ្ពស់ដែលបានសម្រេចផ្តន្ទាទោសនោះដោះស្រាយ។ តុលាការទទួលបណ្តឹងតាមពាក្យប្តឹងរបស់អយ្យការ ឬរបស់

---

[178] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១៦៥។

[179] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១២១។

ភាគីពាក់ព័ន្ធ។ តុលាការ ឬចៅក្រមនេះ ធ្វើការសម្រេចនៅពេលសវនាការសាធារណៈក្រោយពីបានស្តាប់តំណាងអយ្យការភាគីពាក់ព័ន្ធ និងមេធាវីរបស់ភាគីនោះ។ នេះគឺជាលក្ខខណ្ឌនៃក្រមនីតិវិធីព្រហ្មទណ្ឌពាក់ព័ន្ធនឹងបណ្តឹងដែលតុលាការត្រូវទទួល ។

**២.២.២.៣. ការដកហូត និងការចាត់ទុកជាអសារបង់**

ដូចគ្នាផងដែរ ចំពោះការព្យួរទោសសាកល្បងក៏អាចធ្វើការដកហូត ឬចាត់ទុកជាអសារបង់បានផងដែរ ដោយ យើងខ្ញុំនឹងបកស្រាយអំពីការដកហូត និងការចាត់ទុកជាអសារបង់ ។

**២.២.២.៣.១. ការដកហូត**

ការព្យួរទោសសាកល្បងអាចត្រូវបានដកហូតដោយតុលាការនៅក្នុងករណីខាងក្រោមនេះ៖

- ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតមិនគោរពតាមវិធានការត្រួតពិនិត្យ ឬ កាតព្វកិច្ចដោយឡែកទេ។
- ប្រសិនបើក្នុងរយៈពេលសាកល្បង ទណ្ឌិតត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាថ្មីទៀត។

តុលាការអាចបង្គាប់ឲ្យដកហូតការព្យួរទោសសាកល្បងនេះទាំងមូល ឬមួយផ្នែក។ នៅក្នុងករណីនេះ ទោសត្រូវយកមកអនុវត្តទាំងមូលឬមួយផ្នែក។[180]

តុលាការត្រូវបានទទួលបណ្តឹងនៅក្នុងលក្ខខណ្ឌ ដែលមានចែងដោយក្រមនីតិវិធីព្រហ្មទណ្ឌ។ ដូច្នេះការព្យួរទោសសាកល្បងមានន័យថាតុលាការ អាចដកហូតការព្យួរទោសសាកល្បងបាន ប្រសិនបើមានបណ្តឹង ប្តឹងដោយព្រះរាជអាជ្ញាទាក់ទងជាមួយការមិនគោរពកាតព្វកិច្ចរបស់គាត់ ព្រោះថាពេលដែលគាត់ធ្វើកិច្ចការនៅក្រោមវិធានការត្រួតពិនិត្យក្តី ឬការបំពេញនូវកាតព្វកិច្ចដោយឡែកក្តី ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ព្រះរាជអាជ្ញាទាំងអស់។ ហើយបើសិនជាអ្នកហ្នឹងមិនគោរពនូវកាតព្វកិច្ចណាមួយ ឬក៏មិនបំពេញនូវវិធានការត្រួតពិនិត្យណាមួយនោះទេ គឺព្រះរាជអាជ្ញាគាត់អាចប្តឹងសុំទៅចៅក្រម ដើម្បីឲ្យដកហូតនូវការព្យួរទោសសាកល្បងចោលទៅវិញ ព្រោះថាក្នុងរយៈពេលសាកល្បងនេះគាត់ត្រូវធ្វើឲ្យអស់នូវកាតព្វកិច្ចដោយឡែក ឬវិធានការត្រួតពិនិត្យនេះ។

ដូច្នេះ ព្រះរាជអាជ្ញាធ្វើការតាមដាន ហើយនៅក្នុងថិរវេលាដូចជារយៈពេល ដែលតុលាការកំណត់ឲ្យសាកល្បងនោះមានរយៈពេល ០២ ឆ្នាំ ស្រាប់តែគាត់មិនបានបំពេញនូវកាតព្វកិច្ចណាមួយ ឬក៏គាត់មិនគោរពនូវវិធានការត្រួតពិនិត្យណាមួយទេ។ ករណីបែបនេះ ទើបធ្វើឲ្យព្រះរាជអាជ្ញាប្តឹងទៅចៅក្រម ដើម្បីឲ្យតុលាការធ្វើការសម្រេចដកហូតអំពីការព្យួរទោសសាកល្បងវិញ។

ករណីមួយទៀត គឺក្នុងរយៈពេលសាកល្បងនេះ បើគាត់បានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយជាថ្មីទៀត ដោយមិនទាន់ហួសរយៈពេលកំណត់ផង គាត់ក៏ទៅប្រព្រឹត្តបទល្មើសតទៅទៀត វាក៏ជាមូលដ្ឋាននៅក្នុងការប្តឹងសុំរបស់ព្រះរាជអាជ្ញា ដើម្បីឲ្យធ្វើការដកហូតនូវការព្យួរទោសសាកល្បងនេះដែរ។ សម្រាប់បណ្តឹងសុំឲ្យដក

[180] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១២២។

ហួតការព្យួរទោសសាកល្បងនេះ គឺត្រូវធ្វើឡើងដោយគោរពទៅតាមលក្ខខណ្ឌដូច ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌពិសេសមាត្រា ៥០០ ជាដើម។

**២.២.២.៣.២. ការចាត់ទុកជាអសារបង់**

ការផ្តន្ទាទោសនេះត្រូវចាត់ទុកថាជាអសារបង់ ប្រសិនបើមុនការផុតរយៈពេលនៃការសាកល្បងការផ្តន្ទាទោស មិនមែនជាកម្មវត្ថុនៃពាក្យសុំដកហូត ដែលមានសេចក្តីសម្រេចដកហូតនោះទេ ក្នុងករណីនេះពោលគឺអំឡុងពេលនៃការសាកល្បង ដែលតុលាការលោកបានកំណត់ហើយនោះ ទណ្ឌិតក៏បានបំពេញចប់សព្វគ្រប់ហើយគាត់មិនបានប្រព្រឹត្តបទល្មើសថ្មីអ្វីទៀតទេ ហេតុដូច្នេះហើយការអនុវត្តទោសពីការផ្តន្ទាទោសនេះគឺត្រូវចាត់ទុកជាអសារបង់ទៅវិញ បានន័យថាចៅក្រមមិនយកទោសនោះទៅអនុវត្តលើទណ្ឌិតទៀតនោះទេ ពោលគឺស្មើនឹងគាត់ត្រូវបានរួចខ្លួនផុតពីការផ្តន្ទាទោសរបស់ច្បាប់ព្រហ្មទណ្ឌទៀតហើយ ។[181]

ឧទាហរណ៍ ៖ តុលាការលោកបានកំណត់ឲ្យទណ្ឌិតម្នាក់ត្រូវទទួលរងទោសដាក់ពន្ធនាគារចំនួន០២ឆ្នាំ។ ប៉ុន្តែតុលាការក៏ប្រកាសថាទោសនេះគឺត្រូវព្យួរសាកល្បងមើលសិន ដូច្នេះនៅក្នុងសេចក្តីសម្រេចលោកបានកំណត់ដូចជាមានវិធានការត្រួតពិនិត្យ និងមានកាតព្វកិច្ចដោយឡែកមួយឬច្រើន។ ហេតុនេះនៅក្នុងករណីនេះគឺលោកបានកំណត់ឲ្យទណ្ឌិតបំពេញកិច្ចការនេះរយៈពេលសាកល្បង ១៨ខែ។ ប្រសិនបើហួសរយៈពេល ១៨ខែទៅហើយទណ្ឌិតនោះបានបំពេញចប់សព្វគ្រប់ដោយល្អតតទាស់តាមការកំណត់របស់ចៅក្រម ដូចនេះទោសដែលតុលាការកំណត់ ២ ឆ្នាំនោះគឺគេលែងយកមកអនុវត្តទៀតហើយគេអត់មានយកទៅអនុវត្តទៀតទេមានន័យស្មើនឹងគាត់ត្រូវរួចខ្លួនហើយ។ ទាំងនេះគឺជាការបំពេញចប់សព្វគ្រប់របស់ទណ្ឌិតទៅតាមអ្វីដែលតុលាការបានកំណត់ឲ្យគាត់ធ្វើ។

ម្យ៉ាងទៀត ទាក់ទងជាមួយបញ្ហានៃការផ្តន្ទាទោសនេះត្រូវទុកជា អសារបង់ដែរ ប្រសិនបើផុតរយៈពេលនៃការសាកល្បងរួចទៅហើយ ហើយការផ្តន្ទាទោសថ្មីនេះមិនមែនជា កម្មវត្ថុនៃការប្តឹងសុំរបស់ព្រះរាជអាជ្ញាទេ មានន័យថាមិនមានបណ្តឹងសុំដាក់ចូលមកនោះ គឺជាកម្មវត្ថុដែល ពាក់ព័ន្ធជាមួយនឹងការដកហូតការព្យួរទោសសាកល្បងនោះទេ នោះវាក៏បានសេចក្តីថាការអនុវត្តទោស ក៏ត្រូវចាត់ទុកជាអសារបង់ផងដែរ។

[181] ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩, មាត្រា ១២៣។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការសិក្សាស្រាវជ្រាវអំពីប្រធានបទ **ការអនុវត្តទោស និងការព្យួរទោស** នេះរួចមក យើងខ្ញុំបានយល់កាន់តែច្បាស់អំពីនីតិវិធីក្នុងការអនុវត្តទោសទៅតាមបទល្មើសនីមួយៗ ព្រមទាំងដំណាក់កាលនៃការផ្ដន្ទាទោសដែលគួរធ្វើឡើងនៅពេលណាខ្លះ និងតាមរយៈអ្វីខ្លះ។ ការអនុវត្តទោសគឺជាវិធានមួយក្នុងការផ្ដល់ឱកាសដល់ទណ្ឌិតក្នុងការកែប្រែកំហុសរបស់ខ្លួន ដោយឈប់ប្រព្រឹត្តបទល្មើសធ្វើតែអំពើល្អ នឹងជួយរក្សាសណ្ដាប់ធ្នាប់សុខសន្តិភាពក្នុងសង្គម។ ក្រៅពីនេះការអនុវត្តទោស យើងបានយល់បន្ថែមអំពីការរៀបចំ និងលក្ខខណ្ឌណាខ្លះក្នុងការព្យួរទោស ហើយនរណាខ្លះដែលមានសិទ្ធិ និងសមត្ថកិច្ចក្នុងការប្រកាសទោសទាំងនេះនៅក្នុងច្បាប់ព្រហ្មទណ្ឌ។ ការអនុវត្តទោស និងការព្យួរទោសនេះ ត្រូវធ្វើឡើងយ៉ាងយកចិត្តទុកដាក់ និងឆ្លងកាត់ជាច្រើនដំណាក់កាលមុននឹងឈានដល់សេចក្ដីសម្រេច។

មួយវិញទៀត ទោសដែលត្រូវអនុវត្តសម្រាប់រូបវន្តបុគ្គល គឺត្រូវបានចាត់ថ្នាក់ជាបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ទៅតាមទម្ងន់នៃបទល្មើសនីមួយៗ។ គោលបំណងក្នុងការរៀបចំចំណាត់ថ្នាក់នៃបទល្មើស គឺបង្ការកុំឲ្យមានភាពរញ៉េរញ៉ៃក្នុងការចោទប្រកាន់បទល្មើស និងក្នុងការយកទៅអនុវត្តផ្ដន្ទាទោសទៀតផង។ ជាធម្មតាទោសព្រហ្មទណ្ឌ សំដៅទៅលើទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ហើយគេចាត់ទុកទោសទាំងនោះជាកំហុស ឬអំពើរបស់ចារី ឬសហចារីដែលបានប្រព្រឹត្តអំពើល្មើសទាំងនោះ។ ដូច្នេះតួនាទីរបស់តុលាការ គឺត្រូវពិចារណា ស្វែងរកភាពពិត និងយុត្តិធម៌ជូនជនរងគ្រោះដោយវិធីបង្ក្រាប កែប្រែ និងបង្ការនូវអំពើល្មើសនោះកុំឲ្យកើតមានតទៅទៀត។ ស្របជាមួយគ្នានេះផងដែរ តុលាការមានសមត្ថកិច្ចក្នុងការអនុវត្តផ្ដន្ទាទោសទៅលើចារីពេលដែលបានរកឃើញថាជននោះបានប្រព្រឹត្តអំពើ ឬបទល្មើសទាំងនោះមែន ប៉ុន្តែតុលាការក៏មានសិទ្ធិក្នុងការបន្ធូរបន្ថយទោស ឬព្យួរទោសក្នុងករណីទណ្ឌិតបានអនុវត្តទៅតាមលក្ខខណ្ឌនៃការព្យួរទោសបានចែង ហើយជននោះត្រូវគេមើលឃើញថាបានកែប្រែក្លាយជាមនុស្ស និងអាចជួយជាប្រយោជន៍ដល់រដ្ឋ និងសង្គមទាំងមូល។

ក្នុងនោះព្រះរាជអាជ្ញាក៏ជាអ្នកដែលមានតួនាទីពិសេសក្នុងការតាមដានរាល់ទង្វើ ឬកិច្ចការដែលទណ្ឌិតត្រូវអនុវត្ត ហើយប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាជននោះពិតជាបានកែប្រែខ្លួនទៅជាមនុស្សល្អពិតមែន ព្រះរាជអាជ្ញានឹងធ្វើការស្នើសុំឲ្យបន្ធូរបន្ថយ ឬលើកលែងទោសដល់ជននោះដោយយោងទោតាមបទប្បញ្ញត្តិដែលបានចែងជាសាធារណៈ។ ដូច្នេះប្រសិនបើទណ្ឌិតត្រូវបានលើកលែងទោសក្នុងលក្ខខណ្ឌណាមួយជននោះនឹងទទួលបានសិទ្ធិសេរីភាពក្នុងការចេញទៅរស់នៅក្នុងសង្គមសារជាថ្មី។

សរុបសេចក្ដីមក នីតិវិធីក្នុងការអនុវត្តទោស និងការព្យួរទោសមានយន្តការ និងលក្ខខណ្ឌជាច្រើនដែលទាមទារឲ្យទណ្ឌិតគោរព និងអនុវត្តតាម ហើយវាគឺជាឱកាសមួយដ៏ល្អសម្រាប់ទណ្ឌិតក្នុងការកែប្រែ ឬសងនូវព្យសនកម្មដែលបានធ្វើឲ្យខូចខាតដល់សង្គម ឬជនរងគ្រោះជាជាងទទួលរងនូវទោសទណ្ឌផ្សេងៗ។ យន្តការទាំងនេះសុទ្ធតែមានសារៈសំខាន់ខុសៗគ្នា ដែលជាប្រយោជន៍ដល់ទណ្ឌិត និងមនុស្សនៅក្នុងសង្គមក្នុងការយល់ដឹង

បន្ថែមអំពីច្បាប់ដែលមានចែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដើម្បីជាប្រយោជន៍ដល់សង្គមក្នុងការកាត់បន្ថយកំណើននៃបទល្មើស និងជាពិសេសកាត់បន្ថយក្នុងការចំណាយរបស់រដ្ឋទៅលើការគ្រប់គ្រងពន្ធនាគារ និងចំណាយដទៃទៀតក្នុងការអនុវត្តដំណើរការនីតិវិធីតុលាការឲ្យកាន់តែមានភាពរហ័ស និងប្រកបដោយភាពសុក្រឹត្យ និងយុត្តិធម៌ជូនប្រជាពលរដ្ឋទាំងអស់គ្នា។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីការបកស្រាយនូវប្រធានបទខាងលើនេះរួចមកយើងឃើញថាក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានយន្តការច្រើនក្នុងការអនុវត្ត និងប្រកាសទោសព្រហ្មទណ្ឌ ចំពោះជនណាដែលបានប្រព្រឹត្តបទល្មើសដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ។ បន្ថែមពីនេះ ប្រភេទនៃទោសដែលក្រមព្រហ្មទណ្ឌបានចែងមាន មូលទោស ទោសបន្ថែម និងទោសជំនួស ដែលប្រភេទនៃទោសទាំងបីនេះមានលក្ខខណ្ឌ និងនិតិវិធីក្នុងការអនុវត្តខុសៗគ្នា អាស្រ័យទៅលើទម្ងន់នៃទោសដែលជនល្មើសបានប្រព្រឹត្ត។ ក្រមព្រហ្មទណ្ឌក៏បានបញ្ញត្តិអំពីផ្សេងៗដែលអាចនាំឲ្យមានផលប៉ះពាល់ដល់ការអនុវត្តទោស ដូចជាការព្យួរទោស ការបន្ធូរបន្ថយទោស ការលើកលែងទោស និងកត្តាគតិយុត្តមួយចំនួនទៀត ដែលត្រូវបានប្បញ្ញត្តិឡើងដែលមានលក្ខណៈងាយស្រួលដល់ទណ្ឌិត។ ហេតុនេះហើយទើបយន្តការផ្សេងៗទៀតមិនសូវបានយកទៅអនុវត្ត និងនាំឲ្យមានកំណើនទណ្ឌិតនៅក្នុងពន្ធនាគារច្រើនលើសលប់ដែលនាំឲ្យមានផលពិបាកជាច្រើនដល់រដ្ឋ។ ចំពោះបណ្ដាទាំងនេះ តុលាការបានប្រើប្រាស់ទៅជំនួស (ទោសការងារសហគមន៍ និងការស្ដីបន្ទោស) មកអនុវត្តដែលជួយសម្រួលដល់បញ្ហាស្ថានភាព ទីកន្លែង ពេលវេលា និងថវិកាក្នុងការជួលមនុស្សឲ្យឃ្លាំមើលជា។

ជាការពិតណាស់ ក្រមព្រហ្មទណ្ឌ និងច្បាប់ដទៃទៀតបានចែងយ៉ាងលំអិតអំពីបទល្មើស និងទោសទៅលើជនដែលបានប្រព្រឹត្តបទល្មើស ដើម្បីជានាកុំឲ្យមានការខូចខាត់ដល់សណ្ដាប់ធ្នាប់ របៀបរៀបរយសាធារណៈ ឬអំពើប្រឆាំងទៅនឹងសិទ្ធិមនុស្ស ដែលអាចប៉ះបាល់ដល់បូរណភាពនៃបុគ្គល ប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរ សិទ្ធិសេរីភាព ឬសិទ្ធិក្នុងការបញ្ចេញមតិ និងអំពើផ្សេងៗដែលប៉ះពាល់ធ្ងន់ធ្ងរ ដូចជាលួច ឆក់ ប្លន់ និងសម្លាប់ជាដើម។ គួរបញ្ជាក់ផងដែរថា ទោះបីជាច្បាប់បានចែងយ៉ាងលម្អិតអំពីទោសទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តក៏ដោយ អ្វីដែលសំខាន់ គឺការយកទៅអនុវត្តផ្ទាល់ និងការផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋទាំងអស់អំពីការចេះទទួលកំហុសដែលខ្លួនបានធ្វើ និងព្រមចូលខ្លួនមកអនុវត្តទោសទៅតាមទំហំនៃអំពើដែលខ្លួនបានល្មើស។ ដើម្បីរួមចំណែកធ្វើឲ្យវិស័យតុលាការនៃព្រះរាជាណាចក្រកម្ពុជាកាន់តែមានប្រសិទ្ធភាពនោះ យើងខ្ញុំជានិស្សិតសរសេរសារណា សូមចូលរួមផ្ដល់ជាអនុសាសន៍មួយចំនួនដូចជា ៖

- ❖ ចៅក្រមត្រូវតែធានារក្សាភាពមិនលំអៀង ប្រកាននៅជំហរ និងសមត្ថកិច្ចរបស់ខ្លួន ក្នុងការវិនិច្ឆ័យមុននឹងប្រកាសសេចក្ដីសម្រេចដោយផ្អែកតាមច្បាប់យ៉ាងម៉ឺងម៉ាត់បំផុត។
- ❖ ពង្រឹងការអនុវត្តនីតិវិធីទៅតាមដំណាក់កាល និងធានាការជំនុំជម្រះក្ដីដោយយុត្តិធម៌ និងលុបបំបាត់ចោលនូវអំពើពុករលួយ ដែលមាននៅក្នុងវិស័យតុលាការ។
- ❖ ពង្រឹងវិស័យអប់រំ លើកទឹកចិត្តឲ្យដល់ឪពុកម្ដាយឲ្យបញ្ជូនកូនៗ ទៅរៀនឲ្យបានគ្រប់ៗគ្នា ដើម្បីអនាគតរបស់ពួកគេ។

- ពង្រឹងការផ្សព្វផ្សាយច្បាប់ដល់ប្រជាពលរដ្ឋ ឲ្យយល់ដឹងបន្ថែមអំពីការអនុវត្តច្បាប់ និងការពារកុំឲ្យមានការប្រព្រឹត្តបទល្មើសកើតឡើង ដែលអាចបណ្តាលឲ្យខាតបង់នូវពេលវេលា ទ្រព្យសម្បត្តិ កិត្តិយស និងអាយុជីវិតជាដើម។

ជាចុងក្រោយ ប្រសិនបើប្រទេសមួយមានច្បាប់ល្អ ហើយប្រជាពលរដ្ឋបានយល់ដឹងពីតម្លៃ និងអនុវត្តទៅតាមការបទប្បញ្ញត្តិដែលមានចែង ប្រទេសនោះនឹងមានតែសុខសន្តិភាព ហើយការអភិវឌ្ឍនឹងកាន់តែមានភាពរីកចម្រើន ព្រមជាមួយនឹងការស្ញប់ស្ញែង កោតសរសើរពីបណ្តាប្រទេសដទៃទៀតនៅលើពិភពលោក។

# ឯកសារយោង

# ឯកសារយោង

## ១. ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ

### ១.១. រដ្ឋធម្មនុញ្ញ

- ❖ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ២៤ កញ្ញា ១៩៩៣។

### ១.២. ច្បាប់

- ❖ ច្បាប់ស្តីពីយុត្តិធម៌អនីតិជននៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/០៧១៦/០០៩, ៣០ ឧសភា ២០១៦។
- ❖ ច្បាប់ស្តីពីពន្ធនាគារ, លេខ នស/រកម/១២១១/០២១, ២១ ធ្នូ ២០១១។
- ❖ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩។
- ❖ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧។
- ❖ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា, លេខ នស/រកម/១២១១/០២១, ១០ សីហា ២០០៧។

### ១.៣. ព្រះរាជក្រឹត្យ

- ❖ ព្រះរាជក្រឹត្យស្តីពីការបន្ធូរបន្ថយទោស និងការលើកលែងទោស, លេខ នស/រកត/០១២១/០៣០, ១២ មករា ២០២១។

## ២. សៀវភៅ និងអត្ថបទផ្សេងៗ

- ❖ មាសប្ញា, ២០១៧, *យុត្តិធម៌ និងច្បាប់*, ភ្នំពេញ។
- ❖ ន.ស.រ, ផ្សព្វផ្សាយដោយទំព័រស្វែងយល់ពីច្បាប់, ប្រធានបទ៖ *ប្រភេទនៃទោស*, ខែមករា ឆ្នាំ២០១៧។
- ❖ សៀវភៅសំណួរចម្លើយសម្រាប់ការត្រៀមប្រលងរៀបចំដោយបណ្ណាគារភក្តីឡដឺ ចេញថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០១៦។
- ❖ រុន ពណ្ណារិទ្ធ និងចាំង ស៊ីណាត, ២០១២, *នីតិព្រហ្មទណ្ឌទូទៅ*, ភ្នំពេញ។
- ❖ មេរៀននីតិព្រហ្មទណ្ឌរៀបចំដោយផ្អែកលើអត្ថបទនៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ចុះនៅខែធ្នូ ឆ្នាំ២០០៧។
- ❖ ហ៊ាង ឡេង, (មិនស្គាល់ឆ្នាំ), *នីតិព្រហ្មទណ្ឌទូទៅ*, ភ្នំពេញ។

## ៣. គេហទំព័រ និងប្រសាសន៍ផ្សេងៗ

### ៣.១. គេហទំព័រ

- ❖ https://m.facebook.com/permalink.php?story_fbid=1204217719612119&id=1081941058506453&locale2=ar_AR, (ចូលទស្សនាថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២១)។
- ❖ https://www.rfi.fr/km/about-punishment-in-cambodia-criminal-law, (ចូលទស្សនាថ្ងៃទី២០ ខែឧសភា ឆ្នាំ២០២១)។

- https://ciclg.com/cn/article/105, (ចូលទស្សនាថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០២១)។
- https://ciclg.com/cn/article/137, (ចូលទស្សនាថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១)។

### ៣.២. ប្រសាសន៍ផ្សេងៗ

- នាទីច្បាប់, ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន , អត្ថបទដោយកញ្ញា អ៊ុំ ច័ន្ទលក្ខិណា , ចុះថ្ងៃអង្គារ ទី ១០ ខែមីនា ឆ្នាំ ២០២០។
- **ឯកឧត្តម កើត រិទ្ធ** (អនុប្រធានក្រុមការងារចូលរួមតាក់តែង និងការពារសេចក្តីព្រាងក្រមព្រហ្មទណ្ឌ) , បទសម្ភាសន៍ដោយក្រសួងយុត្តិធម៌សហការជាមួយក្រសួងព័ត៌មានតាមរយៈទូរទស្សន៍ជាតិកម្ពុជា,២០១០។
- **ឯកឧត្តម ហ៊ី សោភា** (រដ្ឋលេខាធិការលំដាប់ថ្នាក់ទីមួយនៃក្រសួងយុត្តិធម៌), បទសម្ភាសន៍, ១៨ សីហា ២០១០។

# ឧបសម្ព័ន្ធ

# បញ្ជីរាយនាមឧបសម្ព័ន្ធ

- **ឧបសម្ព័ន្ធទី១៖** សាលក្រម ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៩។
- **ឧបសម្ព័ន្ធទី២៖** សាលក្រម ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២០ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២០។
- **ឧបសម្ព័ន្ធទី៣៖** សាលក្រម ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០១១ ក្នុងសំណុំរឿងព្រហ្មទណ្ឌ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១០។
- **ឧបសម្ព័ន្ធទី៤៖** ព្រះរាជក្រមស្ដីពី ច្បាប់ស្ដីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ។
- **ឧបសម្ព័ន្ធទី៥៖** សារាចរ ស្ដីពីការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍។

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

**សាលក្រម**

លេខ [redacted]
ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]
ចុះថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៩
ស៊ើបសួរលេខ [redacted]
ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ ២០១៩
ជំនុំជម្រះលេខ [redacted]
ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០២០

**តាងនាមប្រជារាស្ត្រខ្មែរ**
**សាលាដំបូងរាជធានីភ្នំពេញ**

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ២០២០
វេលាម៉ោង ០៨ និង ០០ នាទីព្រឹក ដោយមានសមាសភាព:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាប្រធាន
លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៩ ដែលមានជនជាប់ចោទ៖

១. ឈ្មោះ [redacted] ភេទប្រុស អាយុ ៣៣ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ កម្មករ ទីកន្លែងកំណើតនៅភូមិតាង៉ូវ សង្កាត់ព្រែកប្រា ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ១០៥A ផ្លូវលំ ភូមិបឹងឈូក សង្កាត់ច្រាំងចំរេះទី១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ឃាត់ខ្លួនថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៩ , ឃុំខ្លួនថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២០ (ម១)

លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

២. ឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ គ្មាន ទីកន្លែងកំណើតនៅភូមិតាអុង ឃុំតាអុង ស្រុកចំការលើ ខេត្តកំពង់ចាម មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួល ភូមិពោងពាយ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្រពន្ធឈ្មោះ [redacted] កូនគ្មាន ទោសពីមុនគ្មាន ជានីតិជន ។

ឃាត់ខ្លួនថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៩ , ឃុំខ្លួនថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២០ (ម១)

លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យ បណ្ដោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ។

៣. ឈ្មោះ [redacted] ភេទស្រី អាយុ ៤៥ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ លក់ដូរនៅផ្ទះ ទីកន្លែងកំណើតនៅឃុំស្វាយពពែឡ ស្រុកសូទ្រនិគម ខេត្តសៀមរាប មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួលលេខ៨ ផ្លូវបេតុង សង្កាត់កាកាបខាងត្បូង ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្ដីឈ្មោះ [redacted] កូនគ្មាន ទោសពីមុនគ្មាន ជានីតិជន ។

ឃាត់ខ្លួនថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ , ឃុំខ្លួនថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២០ (មប)

៤. ឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ នៅផ្ទះ ទីកន្លែងកំណើតនៅសង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៩២ ផ្លូវរថភ្លើង សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "ស" ម្ដាយឈ្មោះ [redacted] "ស" ប្ដីឈ្មោះ [redacted] មានកូន ០៥នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ឃាត់ខ្លួនថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ , ឃុំខ្លួនថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២០ (មប)

៥. ឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ មុខរបរ បុគ្គលិកខារ៉ាអូខេ ទីកន្លែងកំណើតនៅភូមិខ្សុំ ឃុំបន្ទាយដែក ស្រុកគៀនស្វាយ ខេត្តកណ្ដាល មានទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅផ្ទះលេខ៩២ ផ្លូវរថភ្លើង សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] "រ" ម្ដាយឈ្មោះ [redacted] "រ" ប្ដីឈ្មោះ [redacted] មានកូន ០២នាក់ ទោសពីមុនគ្មាន ជានីតិជន ។

ឃាត់ខ្លួនថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៩ , ឃុំខ្លួនថ្ងៃទី ២៧ ខែវិច្ឆិកា ឆ្នាំ ២០២០ (មប)

លោក [redacted] និងលោក [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទទាំងបី

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យ បណ្ដោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន។

**អង្គហេតុនៃរឿងមានដូចតទៅ**

កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៩ វេលាម៉ោង ១៩ និង ៣០នាទី ត្រង់ចំណុចគល់ស្ពានស្ទឹងមានជ័យ បណ្ដោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន កម្លាំងជំនាញអន្តរគមន៍ (កជ) នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានឃាត់ខ្លួនជនត្រូវចោទចំនួន ០២ នាក់ ឈ្មោះ [redacted] ភេទប្រុស អាយុ ៥៥ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៤៦ ឆ្នាំ ដោយដកហូតបានថ្នាំញៀនមានទម្ងន់ ៤៩,៧៣ (សែសិបប្រាំបួនក្បៀសចិត្តសិបបី)ក្រាម ។ លុះដល់ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០២០ ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៣ ឆ្នាំ នៅម្ដុំចំណុចទល់មុខស្ថានីយទូរសេទស្សន៍ [redacted] ដោយដកហូតបានថ្នាំញៀនទម្ងន់ ២០៧,៩៨១ (ពីររយសូន្យប្រាំពីរកណ្ដុកសញ្ញាកៅសិបបួន) ក្រាម ចំណែកជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ ឃាត់ខ្លួនបាននៅចំណុចមុខ [redacted] ច្បារអំពៅ នៅពេលជនជាប់ចោទទាំងពីរនាក់បានទៅយកឥវ៉ាន់ដែលអតីតប្ដីរបស់ឈ្មោះ [redacted] មានឈ្មោះ [redacted] ផ្ញើមកពីប៉ោយប៉ែត ។ ពេលធ្វើតេស្ដ៍ទឹកនោមជនជាប់ចោទទាំងអស់ឃើញថាមានផ្ទុកនូវសារធាតុញៀន ។

បានឃើញរបាយការណ៍សំយោគលេខ [redacted] រ.ប.ក ចុះថ្ងៃទី២៣ ខែ វិច្ឆិកា ឆ្នាំ ២០១៩ របស់មន្ទីរប្រឆាំងគ្រឿងញៀន ។

បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ [redacted] អ.យ.ជ ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ [redacted] អ.យ.ជ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ [redacted] «ល» ដ.ជ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា នៅថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០២០ វេលាម៉ោងប្រហែលដប់ប្រាំបី ខ្លួនកំពុងអង្គុយលេងនៅមុខផ្ទះជួល ស្រាប់តែប្តីខ្លួនឈ្មោះ [redacted] បានបបួលនាងខ្ញុំឲ្យជិះម៉ូតូទៅជាមួយគាត់ ដើម្បីទៅជួបគេនៅម្តុំស្ពានអាកាសស្ទឹងមានជ័យ ដោយគោលដៅខ្លួនចង់ទៅទិញចេកនៅទីនោះដែរ ខ្លួនក៏ជិះទៅជាមួយគាត់ លុះមកដល់ចំណុចមុខពេទ្យរុស្ស៊ីបំរុងទៅទិញចេក តែពុំទាន់បានទិញផងស្រាប់តែមានបុរសម្នាក់បានហៅប្តីខ្លួនឈ្មោះ [redacted] ទៅជួប ដោយឲ្យខ្លួនអង្គុយរងចាំលើម៉ូតូ ខ្លួនមិនដឹងថាគាត់និយាយគ្នាអំពីរឿងអ្វីទេ ស្រាប់តែឃើញមានការប្រទាញប្រទុងគ្នា ហើយសមត្ថកិច្ចមកឃាត់ខ្លួនប្តីខ្លួនតែម្តង ខ្លួនមិនដឹងថា ប្តីរបស់ខ្លួនឈ្មោះ [redacted] យកថ្នាំញៀនទៅឲ្យគេនោះទេ ។ ខ្លួនពិតជាប្រើប្រាស់គ្រឿងញៀនជាមួយមិត្តភក្តិ តែមិនដែលប្រើប្រាស់ថ្នាំញៀនជាមួយប្តីខ្លួនឈ្មោះ [redacted] ទេ។

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៩ វេលាម៉ោងប្រហែលប្រាំបួនព្រឹក អតីតប្តីរបស់ខ្លួនឈ្មោះ [redacted] អាយុប្រហែល ៣៣ឆ្នាំ បានទូរស័ព្ទឲ្យនាងខ្ញុំចាំទទួលយកឥវ៉ាន់ផ្ញើពីប៉ោយប៉ែត ហើយចាំគាត់ឲ្យលុយចំនួន ចំនួន ២០ម៉ឺនរៀល ទុកចាយជាមួយកូន ហើយគាត់បានប្រាប់ថា បន្តិចទៀតមានគេទូរស័ព្ទមក ហើយធ្វើតាមតែគេទៅ ។ លុះនៅវេលាម៉ោង ១១ មានមនុស្សប្រុសម្នាក់បានទូរស័ព្ទមកខ្លួនឲ្យទៅយកឥវ៉ាន់នៅឫស្សីកែវ [redacted] លុះបានប្រហែលជាងមួយម៉ោងមនុស្សប្រុសម្នាក់នោះ បានទូរស័ព្ទមកម្តងទៀត ដោយប្រាប់ថា មិនចាំបាច់ទៅយកឥវ៉ាន់នៅឫស្សីកែវទេ គឺមកយកឥវ៉ាន់នៅច្បារអំពៅនៅទល់មុខ [redacted] វិញ ហើយខ្ញុំក៏យល់ព្រម ។ នៅវេលាម៉ោង ដប់ពីរជាង នាងខ្ញុំបានបបួលប្អូនថ្លៃខ្ញុំម្នាក់ឈ្មោះ [redacted] ជិះ Pass App ទៅយកឥវ៉ាន់ផ្ញើពីប៉ោយប៉ែតបានជាគ្នា ដោយសារនាងខ្ញុំមិនស្ទូវស្គាល់ផ្លូវច្បារអំពៅ លុះដល់ម៉ោងប្រហែលដប់បីជាង នាងខ្ញុំនិងប្អូនថ្លៃបានជិះ Pass App មកដល់ច្បារអំពៅទល់មុខ Cellcardមានមនុស្សម្នាក់អត់ស្គាល់ឈ្មោះ បានទូរស័ព្ទមកនាងខ្ញុំម្តងទៀត ហើយនាងខ្ញុំបានប្រាប់ថា នាងខ្ញុំបានមកដល់ហើយ ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនតែម្តង ។ នាងខ្ញុំចេះប្រើប្រាស់ថ្នាំញៀនតាំងពីឆ្នាំ ២០១៥ មកម្លេះ ដោយប្រើប្រាស់ជាមួយមិត្តភក្តិធ្វើការនៅខារ៉ាអូខេជាមួយគ្នា ។

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ ២០១៩ វេលាម៉ោងប្រហែលជាង ១៣រសៀល ឈ្មោះ [redacted] ដែលត្រូវជាបងថ្លៃស្រីបានបបួលខ្លួនជិះ Pass App ពីផ្ទះទៅយកឥវ៉ាន់ ដែគេផ្ញើមកពីប្រទេសថៃ ពេលបងថ្លៃស្រីបបួល ខ្លួនក៏បានយល់ព្រមជិះមកច្បារអំពៅជាមួយគាត់ ដើម្បីបានចំណេញប្រាក់ខ្លះ ព្រោះខ្លួនមានបំណងចុះនៅច្បារអំពៅ រួចបន្តដំណើរតាមរយយន្តទូរីសទៅស្រុកកំណើតនៅឯភូមិខ្សំ ឃុំបន្ទាយដែក ស្រុកគៀនស្វាយ ខេត្តកណ្តាល ដើម្បីទៅមើលកូនឈឺ លុះពេលទៅដល់ចំណុចជិតស្តុបច្បារអំពៅគល់ស្ពាន ខ្លួនបាននិយាយទូរស័ព្ទជំនួសបងស្រី ដើម្បីប្រាប់ទីតាំងជំនួសបងស្រីដែលខ្លួនកំពង់ឈប់ក៏ឃើញមានសមត្ថកិច្ចមកឃាត់ខ្លួនតែម្តង។ ខ្លួនបានប្រើប្រាស់ថ្នាំញៀនរយៈពេលជាងមួយខែមកហើយ ។

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា៖ នៅថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ម៉ោងប្រហែល ដប់ប្រាំមួយជាង មានម៉ូយអ្នកទិញគ្រឿងញៀនម្នាក់បានមកទំនាក់ទំនងរកទិញគ្រឿងញៀន ពីរខ្ញុំបាទចំនួន កន្លះខាំក្នុងតម្លៃ ៥០០$ ពេលនោះខ្ញុំបាទបានទទួយលយកលុយពីរយ រួចហើយក៏ទំនាក់ទំនងទៅបុរសមិនស្គាល់ឈ្មោះខាងលើតាមរយៈទូរស័ព្ទ ហើយបុរសនោះបានឲ្យខ្លួនវេលុយតាមអ៥០០ ដុល្លារ ដោយទុកថ្លៃឈ្នួលឲ្យខ្លួនចំនួន ២០ម៉ឺនរៀល រយៈពេល ២០នាទីក្រោយមក បុរសនោះក៏ប្រើមនុស្សរបស់គេជិះម៉ូតូយកកញ្ចប់គ្រឿងញៀនមកប្រគល់ឲ្យខ្លួននៅម្តុំពោធិ៍ចិនតុងក្បែរក្រុមហ៊ុនស្រាបៀអង្គរ ក្រោយពីបានទទូកកញ្ចប់គ្រឿងញៀន ខ្លួនក៏បានយកទៅប្រគល់ឲ្យម៉ូយអ្នកទិញនៅម្តុំគល់ស្ពានស្ទឹងមានជ័យពេលនោះក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួតែម្តង។ ថ្នាំ

ញៀនដែលសមត្ថកិច្ចដកហូតពីខ្លួនមានទម្ងន់ ៩៩,៧៣ (សែសិបប្រាំបួនក្បៀសចិត្តសិបបី) ក្រាម ។ ចំពោះប្រពន្ធរបស់ខ្លួនឈ្មោះ [redacted] មិនបានដឹងពីការរកស៊ីលក់ដូរគ្រឿងញៀនរបស់ខ្លួនទេ ។

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៩ វេលាម៉ោងប្រហែល ១២ និង ៣០ នាទីថ្ងៃត្រង់ ខ្លួនបានដឹកប្រពន្ធ និងកូនទៅសាលារៀនបឋមសិក្សាឬស្សីកែវ ស្រាប់តែមានមិត្តភ័ក្រខ្ញុំឈ្មោះ [redacted] (មិនស្គាល់ត្រកូល) បានទូរស័ព្ទមកខ្លួនឲ្យដឹកឥវ៉ាន់ឲ្យគេពីការ៉ាសាំងសូគីម៉ិចគីឡូតម៉ែត្រលេខ៧ ទៅឲ្យគេនៅចំណុចទល់មុខស្ថានីយទូរទស្សន៍ CTN ដោយគេឲ្យប្រាក់មកខ្លួនចំនួន ៦ម៉ឺនរៀល ខ្ញុំសួរថា ម៉េចឲ្យប្រាក់ច្រើនម្លេះ គេថាអត់អីទេ យកឥវ៉ាន់ទៅឲ្យគេទៅ ចាំគេផ្ញើលុយឲ្យតាមវីន ខ្លួនក៏យល់ព្រមដោយដឹកទាំងប្រពន្ធ និងកូន ទៅយកឥវ៉ាន់នៅការ៉ាសាំងសូគីមិចនៅគីឡូត៍លេខ៧ ពេលទៅដល់ឈ្មោះ [redacted] បានហុចកញ្ចប់ឥវ៉ាន់នោះទៅ គេហ្នឹងមកយកហើយ ពេលនោះប្រពន្ធបើកមើលកញ្ចប់ឥវ៉ាន់ឃើញថា កញ្ចប់នោះជាសៀវភៅ ៥ក្បាល ហើយប្រពន្ធខ្ញុំប្រាប់ថា ជាសៀវភៅទេអត់អីទេ តោះចេញទៅ ខ្ញុំក៏បើកម៉ូតូចេញទៅពេលទៅដល់មុខ CTN មិនទាន់បានទូរស័ព្ទតាមលេខនៅលើកញ្ចប់ឥវ៉ាន់ផង ក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួនខ្ញុំបាទ និងប្រពន្ធនិងកូនខ្លួនតែម្តង ។ សមត្ថកិច្ចបានដកហូតថ្នាំញៀនពីខ្លួនមានទម្ងន់ ២០៧,៩៨១ (ពីររយសូន្យប្រាំពីរកណ្តុកសញ្ញាកៅសិបបួន) ក្រាម ខ្លួនចេះប្រើប្រាស់គ្រឿងញៀនអស់រយៈពេលមួយខែកន្លងមកហើយ ។

ក្រឡាបញ្ជីបានអានលទ្ធផលកោសល្យវិច័យលេខគ្រឿងញៀនលេខ [redacted] ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា សំណាកគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកំរិតភាពសុទ្ធ ៧៥,៨៣% នៃទម្ងន់សរុប ,វាស្ថិតនៅក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា។

ក្រឡាបញ្ជីបានអានលទ្ធផលកោសល្យវិច័យលេខគ្រឿងញៀនលេខ [redacted] ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០ របស់មន្ទីរពិសោធន៍ នៃអគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន បានសន្និដ្ឋានថា សំណាកគ្រឿងញៀនប្រភេទក្រាមម្សៅ ឈ្មោះ មេតំហ្វេតាមីន (ហៅក្រៅ អាយ ឬម៉ាទឹកកក) ដែលមានកំរិតភាពសុទ្ធ ២០,៧៥% នៃទម្ងន់សរុប ,វាស្ថិតនៅក្នុងតារាងទី២ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា និងកេតាមីនដែលមានកម្រិតភាពសុទ្ធ ២១.៥៦% នៃទម្ងន់សរុប ,វាស្ថិតនៅក្នុងតារាងទី៣ មាត្រា ៥ ចំណាត់ថ្នាក់គ្រឿងញៀន ដូចមានចែងលម្អិតក្នុងតារាងឧបសម្ព័ន្ធ ច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនកម្ពុជា ។

**តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថ្កោលទោស**

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ ឃើញថា ជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៣ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៥៨ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ,ឈ្មោះ [redacted] ភេទស្រី អាយុ ៣៩ ឆ្នាំ ,ឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៩៥ ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ២០១៩ ប្រាកដមែន។ ដូច្នេះតំណាងអយ្យការសុំតម្កល់ការចោទប្រកាន់តាមដីកាសន្និដ្ឋានស្ថាពរលេខ [redacted] អ.យ.ជ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ ដដែល សូមតុលាការពិនិត្យពិចារណា និងសម្រេចតាមច្បាប់។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា**

នៅក្នុងរឿងនេះ កូនក្តីខ្លួនឈ្មោះ [redacted] និងឈ្មោះ [redacted] ពិតជាបានឆ្លើយសារភាពថា ពួកគេដើម្បីជីវភាពគ្រួសារ ដោយមានការខ្វះខាត មិនសូវមានចំណេះដឹងក្នុងខ្លួន ទើបបង្ខំចិត្តរកស៊ីទទួលកម្រៃជើងសារយកថ្នាំញៀនទៅឲ្យគេ ដើម្បីបានប្រាក់កម្រៃខ្លះដើម្បីចិញ្ចឹមគ្រួសារមែន ។ ហេតុនេះ សុំឲ្យតុលាការ

ជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង ។ ចំពោះកូនក្តីខ្លួនឈ្មោះ [redacted] មិនបានដឹងថាប្តីរបស់ខ្លួនឈ្មោះ [redacted] យកថ្នាំញៀនទៅម៉ូយនៅម្តុំគល់ស្ពានស្ទឹងមានជ័យនោះទេ ហើយកូនក្តីនេះបានទទួលស្គាល់ថាពិតជាបបានប្រើប្រាស់ថ្នាំញៀនជាមួយមិត្តភ័ក្រមែន ។ ចំណែកឈ្មោះ [redacted] និងឈ្មោះ [redacted] កូនក្តីខ្លួនទាំងពីរនាក់នេះ គ្រាន់តែមានការពឹងពាក់ឲ្យទៅយកឥវ៉ាន់ដែលគេផ្ញើពីប៉ោយប៉ែត ហើយក៏ត្រូវសមត្ថកិច្ចឃាត់ខ្លួននៅម្តុំផ្សារអំពៅនៅតែម្តង ហើយកូនក្តីខ្លួនទាំងបីនាក់នេះបានទទួលស្គាល់ថា ពិតជាបានប្រើប្រាស់ថ្នាំញៀនប្រាកដមែន ដោយសារកូនក្តីខ្លួនមានជីវភាពខ្វះខាត មានគ្រួសារត្រូវចិញ្ចឹម និងមានកំរិតវប្បធម៌ទាប ។ ដូច្នេះ សុំឲ្យតុលាការគិតពីស្ថានសម្រាលទោសឲ្យកូនក្តីខ្លួនផង ។

**មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ សុផល កុសល បានធ្វើសេចក្តីសន្និដ្ឋានថា**

នៅក្នុងរឿងនេះ កូនក្តីខ្លួនឈ្មោះ [redacted] ពិតជាបានឆ្លើយសារភាពថា ពិតជាបានដឹកជញ្ជូនថ្នាំញៀនទៅឲ្យគេ តាមរយៈមិត្តភក្តិ ដោយសារកូនក្តីខ្លួនមានជីវភាពខ្វះខាត មានគ្រួសារត្រូវចិញ្ចឹម និងមានកំរិតវប្បធម៌ទាប ។ ដូច្នេះ សុំឲ្យតុលាការគិតពីស្ថានសម្រាលទោសឲ្យកូនក្តីខ្លួនផង ។

**ជនជាប់ចោទទាំងប្រាំនាក់បាននិយាយសំដីចុងក្រោយ**

សុំឲ្យតុលាការជួយបន្ធូរបន្ថយទោសដល់ពួកខ្លួនផង ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**<u>សំអាងហេតុ</u>**

១. តាមរបាយការណ៍សំយោគរបស់មន្ទីរប្រឆាំងគ្រឿងញៀន និងភស្តុតាងទាំងអស់ដែលស្វែងរកដោយចៅក្រមស៊ើបសួរ ពុំមានភាពផ្ទុយគ្នាទេ ។ យោងតាមមាត្រា ១១០ និងមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចឲ្យតុលាការជឿបានថា កាលពីថ្ងៃទី ២០ ខែវិច្ឆិកា ឆ្នាំ ២០១៩ វេលាម៉ោង ១៩ និង ៣០នាទី ត្រង់ចំណុចគល់ស្ពានស្ទឹងមានជ័យ បណ្តោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន កម្លាំងជំនាញអន្តរគមន៍ (ក៨) នៃមន្ទីរប្រឆាំងបទល្មើសគ្រឿងញៀន បានឃាត់ខ្លួនជនត្រូវចោទចំនួន ០២ នាក់ ឈ្មោះ [redacted] ភេទប្រុស អាយុ ៥៥ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៨៦ ឆ្នាំ (រួមដំណើរ) ដោយដកហូតបានថ្នាំញៀនចំនួន ៨៩,៧៣ (សែសិបប្រាំបួនក្បៀសចិត្តសិបបី) ក្រាម ពីឈ្មោះ [redacted] ។ លុះដល់ថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០២០ ឃាត់ខ្លួនជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ៣៣ ឆ្នាំ នៅម្តុំចំណុចទល់មុខស្ថានីយទូរសទស្សន៍ [redacted] ដោយដកហូតបានថ្នាំញៀនទម្ងន់ ២០៧,៩៤ៀ (ពីររយសូន្យប្រាំពីរកណ្តុកសញ្ញាកៅសិបបួន) ក្រាម ចំណែកជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ៣៨ ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ ឃាត់ខ្លួនបាននៅចំណុចមុខ Cellcard ផ្សារអំពៅ នៅពេលទៅទទួលយកឥវ៉ាន់ដែលអតីតប្តីរបស់ឈ្មោះ [redacted] មានឈ្មោះ [redacted] បានផ្ញើមកពីប៉ោយប៉ែត ។ ពេលធ្វើតេស្តទឹកនោមជនជាប់ចោទទាំងអស់ ឃើញថាមានផ្ទុកនូវសារធាតុញៀន ។

២. តាមចម្លើយជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា កាលពីថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ ២០១៩ ខ្លួនពិតជាបានស៊ីស្នួលដឹកថ្នាំញៀនយកទៅឲ្យគេ នៅម្តុំចំណុចទល់មុខស្ថានីយទូរទស្សន៍CTN មែន ចំពោះថ្នាំញៀនដែលសមត្ថកិច្ចដកហូតពីខ្លួនមានទម្ងន់ ២០៧,៩៤ៀ (ពីររយសូន្យប្រាំពីរកណ្តុសញ្ញាកៅសិបបួន) ក្រាម , ចំពោះជនជាប់ចោទឈ្មោះ [redacted] ឆ្លើយថា ខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅម្តុំគល់ស្ពានស្ទឹងមានជ័យបាននៅពេលកំពង់ឈររងចាំប្រគល់ថ្នាំញៀនឲ្យម៉ូយគេកម្មង់ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតពីខ្លួនមានទម្ងន់

៤៩,៧៣g (សែសិបប្រាំបួនក្បៀសចិតសិបបី) ក្រាម ។ ចំណែកជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយថា ខ្លួនពិតជាជិះម៉ូតូទៅជាមួយតា [redacted] ដើម្បីទៅទិញចេក នៅម្តុំតល់ស្ពានស្ទឹងមានជ័យមែន តែខ្លួនមិនដឹងថា តា ប៊ុន ឃឹម រកស៊ីលក់ដូរគ្រឿងញៀននោះទេ ហើយខ្លួនទទួលស្គាល់ថាពិតជាបានប្រើប្រាស់គ្រឿងញៀនជាមួយមិត្តភក្តិមែន ,ចំពោះជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានឆ្លើយថា កាលពីថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ២០១៩ ពួកខ្លួនត្រូវបានសមត្ថកិច្ចឃាត់ខ្លួននៅចំណុចមុខ Cellcard ច្បារអំពៅ ដោយសារតែពួកខ្លួនទៅយកឥវ៉ាន់ ដែលឈ្មោះ [redacted] នថា ជាអតិតបន្តីខ្លួនផ្ញើមក ពួកខ្លួនពិតជាប្រើប្រាស់គ្រឿងញៀនពិតប្រាកដមែន ។

ភស្តុតាងទាំងអស់នេះតុលាការអាចលើកយកមកពិចារណាបានតាមមាត្រា៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

៣. ជនជាប់ចោទឈ្មោះ [redacted] ,ឈ្មោះ [redacted] ,ឈ្មោះ [redacted] ,ឈ្មោះ [redacted] និងឈ្មោះ [redacted] ជានីតិជនដែលពុំមានភស្តុតាងណាមួយបញ្ជាក់ថា មានបញ្ហាស្មារតីឡើយ ដូច្នេះជនជាប់ចោទពិតជាមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន ។ ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ។

៤. អំពើប្រព្រឹត្តរបស់ជនជាប់ចោទ បានធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយ សណ្តាប់ធ្នាប់សាធារណៈសន្តិសុខសង្គម ដែលក្រមព្រហ្មទណ្ឌត្រង់មាត្រា ២ និង ៣ បានហាមឃាត់ដាច់ខាត និងត្រូវតែផ្តន្ទាទោស ។ ម្យ៉ាងទៀតអំពើនេះមានធាតុផ្សំគ្រប់គ្រាន់ពីបទ ជួញដូរ និងចាត់ចែងដោយខុសច្បាប់នូវសារធាតុញៀន ។

៥. តាមលទ្ធផលកោសលវិច័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលេខ ២៣២១៤/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០ បានបញ្ជាក់ថា ថ្នាំញៀនដែលសមត្ថកិច្ចចាប់យកបានពីជនជាប់ចោទឈ្មោះ [redacted] មាន៖

- ភិនភាគសំណាក៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌សបិទជិតមានហត្ថលេខាគណៈកម្មាការ និងស្នាមមេដៃឈ្មោះ [redacted] ។

- សំណាកជាប្រភេទក្រាមម្សៅថ្លា,ពណ៌ស,ទម្ងន់ ១,២៨៣១ ក្រាម ។

- លទ្ធផល៖ វិជ្ជមាន,ដែលមានសារធាតុញៀនឈ្មោះ មេតំហ្វេតាមីន មានបរិមាណសារធាតុ គិតជាភាគរយនៃទម្ងន់គឺ៖ ៧៥,៤៣% ។

វាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដូច្នេះ យើងអាចគណនាភាគសុទ្ធសរុបទាំងអស់មានទម្ងន់ស្មើ $\frac{៧៥.៤៣\times២០៧.៩៤}{១០០}$ = ១៥៦.៨៤៩g ។

៦. តាមលទ្ធផលកោសលវិច័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលេខ ២៣២១៥/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២០ បានបញ្ជាក់ថា ថ្នាំញៀនដែលសមត្ថកិច្ចចាប់យកបានពីជនជាប់ចោទឈ្មោះ [redacted] មានពីរប្រភេទ៖

- ភិនភាគសំណាក៖ សំណាកនៅក្នុងស្រោមសំបុត្រពណ៌សបិទជិតមានហត្ថលេខាគណៈកម្មាការ និងស្នាមមេដៃឈ្មោះ [redacted] ។

- សំណាកជាប្រភេទក្រាមម្សៅថ្លា,ពណ៌ស,ទម្ងន់ ១,១៦២៦ ក្រាម ។

- លទ្ធផល៖ វិជ្ជមាន,វត្តមានសារធាតុញៀនចំនួន ០២ (ពីរ) ប្រភេទ៖

ឈ្មោះ មេតំហ្វេតាមីន (Methamphetamine) គិតជាភាគរយនៃទម្ងន់គឺ៖ ២០,៥៧% ។

វាស្ថិតនៅក្នុងតារាងទី២ មាត្រា៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដូច្នេះ យើងអាចគណនាភាគសុទ្ធសរុបទាំងអស់មានទម្ងន់ស្មើ $\frac{២០.៥៧\times៤៩.៧៣}{១០០}$ = ១០.២២៩g ។

ឈ្មោះ កេតាមីន (Ketamine) គិតជាភាគរយនៃទម្ងន់គឺ៖ ២១,៥៦% ។

វាស្ថិតនៅក្នុងតារាងទី៣ មាត្រា៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។ ដូច្នេះ យើងអាចគណនាភាគសុទ្ធសរុបទាំងអស់មានទម្ងន់ស្មើ $\frac{២១.៥៦\times៤៩.៧៣}{១០០}$ = ១០.៧២១g ។

៦. វត្ថុចាប់យករួមមាន៖

-ស្រោមសំបុត្រពណ៌លឿងបិទជិត ដែលសមត្ថកិច្ចសរសេរថា ម្សៅក្រាមពណ៌សថ្លា ទម្ងន់ ២០៧,៩៨១ (ពីររយសូន្យប្រាំពីរក្បៀសប្រាំបួនរយប៉ែតសិបមួយ) ក្រាម ជារបស់ឈ្មោះ [redacted] ។

-ស្រោមសំបុត្រពណ៌លឿងបិទជិត ដែលសមត្ថកិច្ចសរសេរថា ម្សៅក្រាមពណ៌សថ្លា ទម្ងន់ ៩៩,៧៣១ (សែសិបប្រាំបួនក្បៀសប្រាំពីររយសាមសិបមួយ) ក្រាម ជារបស់ឈ្មោះ [redacted] ។

- ទូរស័ព្ទដៃចំនួន ០៤គ្រឿង (មិនដំណើរការ) មានម៉ាក SAMSUNG ប៉ែកកញ្ចក់មុខ ម៉ាកមិនស្គាល់ពណ៌មាសបែកកញ្ចក់មុខ និងម៉ាក NOKIA ចុកពិលចំនួន ០២គ្រឿង ។

គប្បីតុលាការសម្រេចរឹបអូសតាមមាត្រា ៩២, មាត្រា ៩៣ នៃច្បាប់ស្តីពីគ្រឿងញៀន និងមាត្រា ៦២, មាត្រា ៦៣ នៃក្រមព្រហ្មទណ្ឌ ។

៧. មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៥៩ ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៦ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ,ឈ្មោះ [redacted] ភេទប្រុស អាយុ ៥៤ ឆ្នាំ ពីបទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ,ឈ្មោះ [redacted] ភេទស្រី អាយុ ៣៤ ឆ្នាំ ,ឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៥៥ ឆ្នាំ ពីបទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យបណ្តោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៨. ជនជាប់ចោទឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ ,ឈ្មោះ [redacted] ភេទស្រី អាយុ ៣៤ ឆ្នាំ និងឈ្មោះ [redacted] ភេទស្រី អាយុ ៥៥ ឆ្នាំ ជាប់ចោទពីបទចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ហើយជនជាប់ចោទទាំងបីនាក់នេះមិនត្រូវបានសមត្ថកិច្ចដកហូតគ្រឿងញៀននៅនឹងខ្លួនទេ គ្រាន់សមត្ថកិច្ចធ្វើតេស្តទឹកនោមឃើញមានសារធាតុញៀននៅនឹងខ្លួនតែប៉ុណ្ណោះ ។ យោងតាមស្មារតីមាត្រា ១០៤ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ តុលាការអាចប្រកាសព្យួរទោស និងការព្យួរទោសមួយផ្នែកបាន ។ ហេតុនេះ គប្បីតុលាការអាចសម្រេចថា ការព្យួរទោសធម្មតានេះអាចនឹងអនុវត្តទៅលើមួយផ្នែកនៃទោសពន្ធនាគារ ដែលតុលាការជាអ្នកកំណត់ថិរវេលា ឬលើមួយផ្នែកនៃប្រាក់ពិន័យដែលតុលាការជាអ្នកកំណត់ចំនួនទឹកប្រាក់ ស្របតាមមាត្រា ១០៤ និងមាត្រា ១០៨ នៃក្រមព្រហ្មទណ្ឌ។

**<u>ហេតុដូច្នេះសម្រេច</u>**

**១**. ផ្តន្ទាទោសលើ៖

**ក**. ឈ្មោះ [redacted] ភេទប្រុស អាយុ ២៥ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ១០ឆ្នាំ (ដប់ឆ្នាំ) និងពិន័យជាប្រាក់ដាក់ចូលថវិការដ្ឋចំនួន ២០.០០០.០០០ (ម្ភៃលាន)រៀល ។

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យបណ្តោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៦ ចំណុចទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**ខ**. ឈ្មោះ [redacted] ភេទប្រុស អាយុ ៥៩ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ(បីឆ្នាំ)

ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យបណ្តោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ បទល្មើស

ព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៤ និងមាត្រា ៤៨ កថាខណ្ឌទី៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**គ**. ឈ្មោះ [redacted] ភេទស្រី អាយុ ២២ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ(ពីរឆ្នាំ) តែឲ្យអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០៨ខែ(ប្រាំបីខែ) ទោសសល់ពីនេះព្យួរធម្មតា ។

**ឃ**. ឈ្មោះ [redacted] ភេទស្រី អាយុ ៣៤ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ(ពីរឆ្នាំ) តែឲ្យអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០១ ឆ្នាំ(មួយឆ្នាំ) ទោសសល់ពីនេះព្យួរធម្មតា ។

**ង**. ឈ្មោះ [redacted] ភេទស្រី អាយុ ៤៥ ឆ្នាំ សញ្ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ(ពីរឆ្នាំ) តែឲ្យអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០១ ឆ្នាំ(មួយឆ្នាំ) ទោសសល់ពីនេះព្យួរធម្មតា ។

ពីបទ ចាត់ចែងឲ្យប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុចគល់ស្ពានស្ទឹងមានជ័យ បណ្តោយផ្លូវលេខ២៧១ សង្កាត់ទំនប់ទឹក ខណ្ឌចំការមន រាជធានីភ្នំពេញ កាលពីថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០១៩ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤២ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២. វត្ថុចាប់យករួមមាន៖

-គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬអាយ) ទម្ងន់ ២០៧,៩៨g (ពីររយសូន្យប្រាំពីរកណ្តកសញ្ញាកៅសិបបួន) ក្រាម ដែលមានកំរិតភាពសុទ្ធ ៧៥.៤៣%នៃទម្ងន់សរុប ។

-គ្រឿងញៀនប្រភេទក្រាមម្សៅឈ្មោះមេតំហ្វេតាមីន (ហៅក្រៅម៉ាទឹកកក ឬអាយ) ទម្ងន់ ៤៩,៧៣g (សែសិបប្រាំបួនកណ្តកសញ្ញាចិតសិបប្រាំបី) ក្រាម ដែលមានកំរិតភាពសុទ្ធ ២០.៥៧% នៃទម្ងន់សរុប និងកេតាមីន ដែលមានកម្រិតភាពសុទ្ធ ២១.៥៧%នៃទម្ងន់សរុប ។

- ទូរស័ព្ទដៃចំនួន ០៤គ្រឿង (មិនដំណើរការ) មានម៉ាក SAMSUNG បៃតកកញ្ចក់មុខ ម៉ាកមិនស្គាល់ពណ៌មាសបៃតកកញ្ចក់មុខ និងម៉ាក NOKIA ចុកពិលចំនួន ០២គ្រឿង ។

សម្រេចរឹបអូស ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២០ ចំពោះមុខជនជាប់ចោទ មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ ។

បើកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១០កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមលេខ [redacted]
ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០
សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]
ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២០
សំណុំរឿងស៊ើបសួរលេខ [redacted]
ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២០
សំណុំរឿងជំនុំជម្រះលេខ [redacted]
ចុះថ្ងៃ ១៣ ខែ មេសា ឆ្នាំ ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២០
វេលាម៉ោង ៨:០០ នាទីព្រឹក ដោយមានសមាសភាព ៖

### ក្រុមប្រឹក្សាជំនុំជម្រះ

លោក [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ប្រធានក្រុមប្រឹក្សា
លោកស្រី [redacted] អនុប្រធានសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា
លោកស្រី [redacted] ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ ចៅក្រមប្រឹក្សា

### តំណាងអយ្យការ

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

### ក្រឡាបញ្ជីសវនាការ

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ [redacted] ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២០ ដែលមានជនជាប់ចោទ៖

១.ឈ្មោះ [redacted] ហៅ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួល ភូមិចុងថ្នល់ខាងលិច សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ [redacted] “រ” នៅលីវ ជានីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

ឃាត់ខ្លួនថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ ,ឃុំខ្លួនថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២០។

២.ឈ្មោះ [redacted] ហៅ [redacted] ភេទស្រី អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ សាសនាព្រះពុទ្ធ ទីកន្លែងកំណើតនៅភូមិស្វាយជួល ឃុំចំការអណ្តូង ស្រុកចំការលើ ខេត្តកំពង់ចាម ទីលំនៅមុនពេលឃាត់ខ្លួនស្នាក់នៅបន្ទប់ជួល សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] “រ” ម្តាយឈ្មោះ [redacted] “រ” នៅលីវ ជាអនីតិជន ទោសពីមុនគ្មាន។ (ក្នុងឃុំ)

ឃាត់ខ្លួនថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ ,ឃុំខ្លួនថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២០។

ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុចផ្លូវលេខ១១០ កែងផ្លូវលេខ១៣២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-លោក [redacted] អត្តលេខ [redacted] និងមេធាវី [redacted] អត្តលេខ [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទតាមការចាត់តាំងមេធាវីការពារសិទ្ធិជនក្រីក្រ។

**អង្គហេតុនៃរឿងមានដូចតទៅ៖**

នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ វេលាម៉ោង ០៩ និង ១៥ នាទី នៅចំណុចផ្លូវលេខ១១០ កែងផ្លូវលេខ១៣២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កម្លាំងសមត្ថកិច្ចបានចុះល្បាតតាមមូលដ្ឋាន ដោយបានប្រទះឃើញជនជាប់ចោទចំនួន០៣នាក់ ១.ឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ២.ឈ្មោះ [redacted] ភេទស្រី អាយុ ១៧ឆ្នាំ ៣.ឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ដោយមានការសង្ស័យ បានហៅត្រួតពិនិត្យ និងឆែកឆេររកឃើញ ក្រាមពណ៌សថ្លាសង្ស័យជាគ្រឿងញៀនចំនួន០២កញ្ចប់ ទម្ងន់សរុប០,៤៦៧ ក៏ឃាត់ខ្លួនជនជាប់ចោទ និងដកហូតវត្ថុតាង រួចកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញតែម្តង។ ក្រោយពីធ្វើការសាកសួរបានឱ្យដឹងថាឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ពុំមានពាក់ព័ន្ធនឹងបទល្មើសអ្វីទេ ទើបតំណាងអយ្យការសម្រេចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ។

-បានឃើញរបាយការណ៍សំយោគលេខ [redacted] ក.ប.គ.ញ ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០២០ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ [redacted] អ.យ.ធ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសន្និដ្ឋានស្ថាពរលេខ [redacted] អ.យ.ន ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០២០ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះលេខ [redacted] "ង" ដ.ដ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

**នាពេលសវនាការ**

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា: កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ វេលាម៉ោង១០និង៣០នាទីព្រឹក ខ្លួនបានជិះម៉ូតូឌុបឈ្មោះ [redacted] និងឈ្មោះ [redacted] ដើម្បីទៅទិញគ្រឿងញៀននៅម្តុំក្តាន់ពីរ។ លុះពេលទៅដល់ខ្លួនបានទិញថ្នាំញៀនពីបុរសម្នាក់មិនស្គាល់ឈ្មោះ ចំនួន០២កញ្ចប់តូចក្នុងតម្លៃ ៣០០០០៛ ដើម្បីយកមកប្រើប្រាស់ក្រោយពីទិញបានហើយខ្លួនបានឱ្យឈ្មោះ [redacted] រក្សាទុកបន្ទាប់មកក៏ជិះម៉ូតូត្រឡប់មកវិញពេលជិះម៉ូតូចេញបានចម្ងាយប្រហែល១០ម៉ែត្រ ស្រាប់តែសមត្ថកិច្ចហៅឆែកឆេរឃើញថ្នាំញៀនក៏ឃាត់ខ្លួនតែម្តង។

ជនជាប់ចោទឈ្មោះ [redacted] បានឆ្លើយសារភាពថា: កាលពីថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ វេលាម៉ោងប្រហែល ៩:៣០នាទីព្រឹក ពួកខ្លួនមានឈ្មោះ [redacted] ,ឈ្មោះ [redacted] និងរូបខ្លួនបាននាំគ្នាជិះម៉ូតូទៅទិញគ្រឿងញៀននៅម្តុំក្តាន់ពីរ លុះពេលជិះទៅដល់ឈ្មោះ [redacted] បានចូលទៅទិញថ្នាំញៀនបានហើយ ខ្លួនជាអ្នករក្សាទុក បន្ទប់មកក៏ជិះម៉ូតូចេញមកវិញ បានចម្ងាយប្រហែល១០ម៉ែត្រ ស្រាប់តែសមត្ថកិច្ចបានហៅសាកសួរ និងឆែកឆេរឃើញថ្នាំញៀនចំនួន០២កញ្ចប់តូចក៏ឃាត់ខ្លួនពួកខ្លួនតែម្តង។

**តំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ**

ក្រោយពីបានស្តាប់ជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី ព្រមទាំងពិនិត្យភស្តុតាងផ្សេងទៀត ដែលមាននៅក្នុងសំណុំរឿងអាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] និងឈ្មោះ [redacted] ហៅ [redacted] បានប្រព្រឹត្តអំពើ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រាកដមែន។ ដូច្នេះ តំណាងអយ្យការនៅតែ

តម្កល់ការចោទប្រកាន់ តាមដីកាសន្និដ្ឋានស្ថាពរ លេខ [redacted] អ.ឃ.ន ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២០ សូមតុលាការសម្រេច និងពិនិត្យតាមច្បាប់។

<u>**សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ**</u>

ក្នុងនាមខ្ញុំបាទ [redacted] និងលោកមេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] និងឈ្មោះ [redacted] ហៅ [redacted] ក្រោយពីបានស្តាប់ការសួរដេញដោលកូនក្តីខ្លួនបានឆ្លើយគ្រប់ដំណាក់កាល និងសារភាពពីទោសកំហុសហើយកូនក្តីខ្លួនទើបតែប្រព្រឹត្តលើកដំបូង និងមានអាយុតិច។ សំណូមពរសុំឱ្យតុលាការជួយសម្រាលទោស និងអនុវត្តទោសព្យួរឱ្យកូនក្តីខ្លួនផង។

**សម្តីចុងក្រោយរបស់ជនជាប់ចោទ:-**

-ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] បានសំណូមពរខ្លួនសុំឱ្យតុលាកាបន្ធូរបន្ថយទោសឱ្យរូបខ្លួនផង ព្រោះយល់ពីកំហុស និងកែខ្លួនហើយ។

-ជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] បានសំណូមពរខ្លួនសុំឱ្យតុលាកាបន្ធូរបន្ថយទោសឱ្យរូបខ្លួនផង ព្រោះយល់ពីកំហុស និងកែខ្លួនហើយ។

ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង

ក្រោយពីបានពិភាក្សា និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

**សំអាងហេតុ**

១.តាមរបាយការណ៍របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងភស្តុតាងនានាក្នុងសំណុំរឿងពុំមានភាពផ្ទុយគ្នាទេ យោងតាមមាត្រា ១១០ និងមាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អាចឱ្យតុលាការជឿបានថាជនជាប់ចោទឈ្មោះ [redacted] ហៅ [redacted] និងឈ្មោះ [redacted] ពិតជាមានករណី ***រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន*** ប្រព្រឹត្តនៅចំណុចផ្លូវលេខ១១០ កែងផ្លូវលេខ១៣២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រាកដមែន។

២.ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] បានឆ្លើយសារភាពដោយមានលក្ខណៈស៊ីសង្វាក់គ្នាថា៖ ពួកខ្លួនពិតជាបានចូលលុយគ្នាទៅទិញថ្នាំញៀននៅម្តុំពីរដោយមានចំនួន០២កញ្ចប់តម្លៃ៣០.០០០៛(បីម៉ឺនរៀល)។ ពួកខ្លួនទិញថ្នាំញៀនក្នុងគោលបំណងយកទៅប្រើប្រាស់ ហើយពួកខ្លួនទើបតែចេះប្រើប្រាស់ថ្នាំញៀនអស់រយៈពេល៣ទៅ៤ខែតែប៉ុណ្ណោះ។

ភស្តុតាងខាងលើទាំងអស់នេះ តុលាការអាចលើយកមកពិចារណាបានតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៣.ជនជាប់ចោទឈ្មោះ [redacted] ជានីតិជនមាន ស្មារតីគ្រប់គ្រាន់នៅពេលប្រព្រឹត្តបទល្មើសពុំមានជំងឺវិបល្លាសស្មារតីទេ ប៉ុន្តែជនជាប់ចោទទាំងពីររូបនេះជាអនីតិជន ពុំទាន់មានសមត្ថភាពពេញលេញក្នុងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់នៅឡើយទេ។ គប្បីតុលាការពិចារណាតាមមាត្រា១៦០ នៃក្រមព្រហ្មទណ្ឌ

និងមាត្រា៤០ អនុសញ្ញាស្តីពីសិទ្ធិកុមារ។ រីឯឈ្មោះ [redacted] ជានីតិជនដែលពុំមានភស្តុតាងណាមួយបញ្ជាក់ថាមានបញ្ហាវិបល្លាសស្មារតីឡើយ ដូច្នេះសមត្ថជនសុទ្ធតែមានស្មារតីយល់ដឹងពីផលវិបាកដែលកើតចេញពីការប្រព្រឹត្តរបស់ខ្លួន និងការទទួលខុសត្រូវនូវអំពើរបស់ខ្លួនតាមផ្លូវច្បាប់ស្របតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ។

៤.អំពើប្រព្រឹត្តរបស់ជនជាប់ចោទ ដែលបានលួចបៅអ៊ីឈើរបស់ជនរងគ្រោះ បានធ្វើឱ្យប៉ះពាល់ដល់របៀបរៀបរយសាធារណៈ សន្តិសុខសង្គម ដែលក្រមព្រហ្មទណ្ឌត្រង់មាត្រា ២ និងមាត្រា ៣ បានហាមឃាត់ដាច់ខាត និងត្រូវផ្តន្ទាទោស។ ម្យ៉ាងទៀតអំពើនេះវាមានធាតុផ្សំគ្រប់គ្រាន់ពីបទ **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។**

៥.តាមលទ្ធផលកោសលវិច័យរបស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនលេខ ២៤១៩២/២០ ម.ព.អ.ជ.ប.គ.ញ ចុះថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០២០ បានបញ្ជាក់ថា ថ្នាំញៀនដែលសមត្ថកិច្ចចាប់យកបានពីជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] ជាប្រភេទមេតហ្វេតាមីន ដែលមានកំរិតភាពសុទ្ធ ៧៨.៧៣% វាស្ថិតនៅក្នុងតារាងទី ២ មាត្រា ៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។ ដូច្នេះ យើងអាចគណនាភាគសុទ្ធសរុបទាំងអស់មានទម្ងន់ស្មើ $\frac{៧៨.៧៣ \times ០.៤៦}{១០០} = ០.៣៦២g$ វាមានធាតុផ្សំគ្រប់គ្រាន់តាមមាត្រា ៤០ កថាខណ្ឌទី១ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៦.វត្ថុចាប់យករួមមាន៖

-ស្រោមសំបុត្រពណ៌សបិទជិតដែលមានសរសេរថា៖ កញ្ចប់រក្សាវត្ថុតាង ក្រាមសថ្លា ចំនួន០២កញ្ចប់ ដែលមានតម្រុយសង្ស័យជាសារធាតុញៀនមានទម្ងន់ជាក្រាមសរុប ០,៤៦g ដោយមានស្នាមផ្តិតមេដៃរបស់ជនជាប់ចោទឈ្មោះ [redacted] និងឈ្មោះ [redacted] និងចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌។ គប្បីសម្រេចរឹបអូសតាមមាត្រា ៩៣ និងមាត្រា ៩៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៧.មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ភេទស្រី អាយុ ១៧ឆ្នាំ ជនជាតិខ្មែរ ពីបទ: **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវលេខ១១០ និងកែងផ្លូវ១៣២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

## <u>ហេតុដូច្នេះសម្រេច</u>

១.ផ្តន្ទាទោសលើឈ្មោះ [redacted] ភេទប្រុស អាយុ ១៧ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ (មួយឆ្នាំ) តែឱ្យអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០៦ខែ និងឈ្មោះ [redacted] ភេទប្រុស អាយុ ១៨ឆ្នាំ ដាក់ពន្ធនាគារកំណត់រយៈពេល ០២ឆ្នាំ (ពីរឆ្នាំ) តែឱ្យអនុវត្តទោសក្នុងពន្ធនាគាររយៈពេល ០៨ខែ (ប្រាំបីខែ) ទោសសល់ព្យួរសាកល្បងតាមបញ្ញាត្តិមាត្រា ១១៧ និងមាត្រា ១២២ នៃក្រមព្រហ្មទណ្ឌ ដោយឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ និងអនុវត្តកាតព្វកិច្ចដូចខាងក្រោម៖

ក.ទណ្ឌិតឱ្យគោរពតាមដីកាកោះរបស់ព្រះរាជអាជ្ញា ឬ របស់បុគ្គលដែលព្រះរាជរាជ្ញាបានប្រគល់អំណាចឱ្យ។

ខ.ទណ្ឌិតត្រូវមកទទួលនូវការមកពិនិត្យមើលរបស់បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យ។

គ.ទណ្ឌិតត្រូវប្រគល់ដល់ព្រះរាជអាជ្ញា ឬ បុគ្គលដែលព្រះរាជអាជ្ញាបានប្រគល់អំណាចឱ្យនូវគ្រប់ឯកសារសម្រាប់ធ្វើការផ្ទៀងផ្ទាត់លើការបញ្ចូលឱ្យទៅរស់នៅក្នុងសង្គមវិញ។

ឃ.ទទួលឱ្យពេទ្យធ្វើការពិនិត្យ ឬ ការព្យាបាល។

ង.បញ្ជាក់ថាខ្លួនរួមចំណែកក្នុងការចិញ្ចឹមបីបាច់គ្រួសារ។

ច.មិនត្រូវសេបគប់ជាមួយបុគ្គលជួញដូរ ឬ ប្រើប្រាស់គ្រឿងញៀន។

ពីបទ: **រក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅចំណុច ផ្លូវលេខ១១០ និងកែវផ្លូវ១៣២ សង្កាត់ផ្សារដេប៉ូ៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០២០ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**២.វត្ថុចាប់យករួមមាន៖**

-គ្រឿងញៀនប្រភេទមេតំហ្វេតាមីន (ហៅម៉ាក់ទឹកកក ឬ អាយ) ដែលមានកំរិតធាតុសុទ្ធ ៧៨.៧៣% នៃទម្ងន់សរុប ០,៤៦ៗ។ សម្រេចរឹបអូស។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ,ឈ្មោះ [redacted] ។

ភាគីមានសិទ្ធិប្តឹងឧទ្ធរណ៍ក្នុងរយៈពេលដែលច្បាប់កំណត់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ចៅក្រមជំនុំជម្រះ** |
|---|---|---|---|
| ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា | ហត្ថលេខា និងត្រា |
| [redacted] | [redacted] | [redacted] | [redacted] |

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"

ថ្ងៃអង្គារ ១០កើត ខែអាសាឍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០២០

**ក្រឡាបញ្ជីសវនាការ**

[redacted]

បានឃើញ

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

សាលក្រមលេខ [redacted]

ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១

សំណុំរឿងព្រហ្មទណ្ឌលេខ [redacted]

ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១០

## សំរង់សាលក្រមព្រហ្មទណ្ឌ

ដែលមានសមាសភាពដូចតទៅ :

**-ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធានក្រុមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**-តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារង

**-ក្រឡាបញ្ជីសវនាការ**

លោក [redacted]

កញ្ញា [redacted]

តាមសាលក្រមព្រហ្មទណ្ឌ លេខ [redacted] ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលបានបើកសវនាការជាសាធារណៈ នៅសាលាដំបូង ខេត្តបន្ទាយមានជ័យ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១១ និងប្រកាសជាសាធារណៈ នៅថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០១១ ដើម្បីជំនុំជម្រះលើជនជាប់ចោទ :

១-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៥៥( ៥៦ឆ្នាំ) ទីកន្លែងកំណើត ភូមិពន្លៃ ឃុំព្រែកឈ្មៀង ស្រុកពាមរក៏ ខេត្តព្រៃវែង។

អាស័យដ្ឋានបច្ចុប្បន្ន ភូមិអូរអំបិល សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មុខរបរនគរបាល ( អតីតស្នងការនគរបាលខេត្តបន្ទាយមានជ័យ) សញ្ជាតិ ខ្មែរ ទោសពីមុន គ្មាន។

ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted]។

***( ថ្ងៃឃុំខ្លួន ១៤-០១-២០១១)***

ត្រូវជាប់ចោទពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីប្រមូលប្រាក់ប្រចាំខែអំពីការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច :*** កាលពីអំឡុងឆ្នាំ ២០០៨ ដល់ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀន និងផែកនៅផ្ទះ*** [redacted] កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ***និងដីកាចាប់ខ្លួន*** [redacted]***:*** កាលពីខែឧសភា ឆ្នាំ២០១០ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀននៅមុខស្ថានីយ៍ប្រេងឥន្ធនៈ*** [redacted]កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

២-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៥(៤៦ឆ្នាំ) ទីកន្លែងកំណើត ភូមិព្រៃតូច ឃុំទួលព្រហ្ម ស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

អាស័យដ្ឋានបច្ចុប្បន្ន ភូមិរោងម៉ាស៊ីន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មុខរបរនគរបាល (អតីតស្នងការរងនគរបាលខេត្តបន្ទាយមានជ័យ) សញ្ជាតិ ខ្មែរ ទោសពីមុន គ្មាន ។

ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted]"រ" ប្រពន្ធឈ្មោះ [redacted]។

***(ថ្ងៃឃុំខ្លួន ១៤-០១-២០១១)***

ត្រូវជាប់ចោទពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀន និងផែកនៅផ្ទះ*** [redacted] កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ***និងដីកាចាប់ខ្លួន*** [redacted] កាលពីខែឧសភា ឆ្នាំ២០១០ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀននៅផ្ទះ*** [redacted] ***ខាងលិចផ្សារអត្ថ:*** កាលពីខែសីហា ឆ្នាំ២០០៩ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀននៅផ្ទះ*** [redacted] ***:*** កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៩ នៅសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀននៅមុខស្ថានីយ៍ប្រេងឥន្ធនៈ*** [redacted]កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

៣-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៨(៤៣ឆ្នាំ) ទីកន្លែងកំណើត ភូមិចក ឃុំចក ស្រុករំដួល ខេត្តស្វាយរៀង ។

អាស័យដ្ឋានបច្ចុប្បន្ន ភូមិ១ សង្កាត់ព្រះពន្លា ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មុខរបរនគរបាល (អតីតអនុប្រធានការិយាល័យព្រហ្មទណ្ឌកិរិតស្រាលនៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ) សញ្ជាតិ ខ្មែរ ទោសពីមុន គ្មាន ។

ឪពុកឈ្មោះ [redacted]"ស" ម្តាយឈ្មោះ [redacted]"ស" ប្រពន្ធឈ្មោះ [redacted]។

***(ថ្ងៃឃុំខ្លួន ០៤-៤-២០១១)***

ត្រូវជាប់ចោទពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀន និងផែកនៅផ្ទះ*** [redacted] កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ***និងដីកាចាប់ខ្លួន*** [redacted] កាលពីខែឧសភា ឆ្នាំ២០១០ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

៤-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៨(៤៣ឆ្នាំ) ទីកន្លែងកំណើត ភូមិរការ ឃុំរការ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។

អាស័យដ្ឋានបច្ចុប្បន្ន សង្កាត់ផ្សារកណ្តាលទី២ ខណ្ឌដូនពេញ រាជធានីភ្នំពេញ មុខរបរនគរបាល (អតីតមន្ត្រីនគរបាលនៃមន្ទីរប្រឆាំងគ្រឿងញៀន) សញ្ជាតិ ខ្មែរ ទោសពីមុន គ្មាន។

ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted]។ ***(ក្រៅឃុំ)***

ត្រូវជាប់ចោទពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀននៅផ្ទះ*** [redacted] ***ខាងលិចផ្សារអត្ត:*** កាលពីខែសីហា ឆ្នាំ២០០៩ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀននៅផ្ទះ*** [redacted] : កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៩ នៅសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

៥-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៧៣(៣៨ឆ្នាំ) ទីកន្លែងកំណើត សង្កាត់លេខ៥ ក្រុងភ្នំពេញ។

អាស័យដ្ឋានបច្ចុប្បន្ន ភូមិរោងម៉ាស៊ីន សង្កាត់អូរអំបិល ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ មុខរបរនគរបាល (អតីតមន្ត្រីនគរបាលការិយាល័យប្រឆាំងការជួញដូរគ្រឿងញៀននៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ) សញ្ជាតិ ខ្មែរ ទោសពីមុន គ្មាន។

ឪពុកឈ្មោះ [redacted] "ស" ម្តាយឈ្មោះ [redacted] "ស" ប្រពន្ធឈ្មោះ [redacted]។

***(ថ្ងៃឃុំខ្លួន ២០-៥-២០១១)***

ត្រូវជាប់ចោទពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀននៅមុខស្ថានីយ៍ប្រេងឥន្ធនៈ*** [redacted]:កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

## ហេតុដូច្នេះសាលាដំបូងខេត្តបន្ទាយមានជ័យ

## វិនិច្ឆ័យសេចក្តី

១-ឱ្យរួចខ្លួនពីបទចោទប្រកាន់ បទ ស៊ីសំណូក លើឈ្មោះ :

១-១-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៥៥(៥៦ឆ្នាំ) ករណីដីកាចាប់ខ្លួន [redacted] កាលពីខែឧសភា ឆ្នាំ២០១០ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

១-២-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៥(៤៦ឆ្នាំ) ករណីបង្ក្រាបគ្រឿងញៀន លើឈ្មោះ [redacted] នៅខាងលិចផ្សារអត្ត: កាលពីខែសីហា ឆ្នាំ២០០៩ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

បទល្មើស ព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា៣៨ នៃច្បាប់ ព្រហ្មទណ្ឌអន្តរកាល ចាប់ពីពេលនេះតទៅ តាមបញ្ញត្តិមាត្រា ៣៥០ ក្រមនីតិវិធីព្រហ្មទណ្ឌ។

២-ផ្តន្ទាទោស

**២-១**-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៥៥(៥៦ឆ្នាំ) ដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ (បួនឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១៤ ខែ មករា ឆ្នាំ ២០១១ និងពិន័យជាប្រាក់ ចំនួន២ដងនៃប្រាក់សំណូក ស្មើនឹងចំនួន២៨០,០០០ដុល្លា (ម្ភៃប្រាំបីម៉ឺនដុល្លា) និង ១៦០,០០០,០០០រៀល (មួយរយហុកសិបលានរៀល) បង់ចូលថវិការដ្ឋ។

ពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីប្រមូលប្រាក់ប្រចាំខែអំពីការិយាល័យប្រឆាំងបទល្មើសសេដ្ឋកិច្ច*** : កាលពីអំឡុងឆ្នាំ ២០០៨ ដល់ ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀន និងឆែកឆេរផ្ទះ*** [redacted] : កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀននៅមុខស្ថានីយ៍ប្រេងឥន្ធនៈ*** [redacted] : កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**២-២**-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៥(៤៦ឆ្នាំ)ដាក់ពន្ធនាគារកំណត់ ៤ឆ្នាំ (បួនឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី១៤ ខែមករា ឆ្នាំ២០១១ និងពិន័យជាប្រាក់ ចំនួន២ដងនៃប្រាក់សំណូក ស្មើនឹងចំនួន ១០,៦០០ដុល្លា (មួយម៉ឺនប្រាំមួយរយដុល្លា) បង់ចូលថវិការដ្ឋ ។

ពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀន និងឆែកឆេរផ្ទះ*** [redacted] កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ***និងដីកាចាប់ខ្លួន*** [redacted] កាលពីខែឧសភា ឆ្នាំ២០១០ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀនលើឈ្មោះ*** [redacted] : កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៩ នៅសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ។

***-ករណីបង្ក្រាបគ្រឿងញៀននៅមុខស្ថានីយ៍ប្រេងឥន្ធនៈ*** [redacted] : កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ ។

**២-៣**-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៨(៤៣ឆ្នាំ) ដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ (បីឆ្នាំ) តែទោសនេះត្រូវអនុវត្តទោស ក្នុងពន្ធនាគារ ចំនួន១ឆ្នាំ (មួយឆ្នាំ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី០៤ ខែ មេសា ឆ្នាំ២០១១ ទោសលើសពីនេះត្រូវព្យួរ តាមបញ្ញត្តិ មាត្រា ១០៦,មាត្រា ១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ ចំនួន២ដងនៃប្រាក់សំណូក ស្មើនឹងចំនួន៣,២០០ដុល្លា (បីពាន់ពីររយដុល្លា) បង់ចូលថវិការដ្ឋ ។

ពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀន និងឆែកឆេរផ្ទះ*** [redacted] កាលពីថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០៩ ***និងដីកាចាប់ខ្លួន*** [redacted] កាលពីខែឧសភា ឆ្នាំ២០១០ ក្នុងដែនដីខេត្តបន្ទាយមានជ័យ ។

**២-៤**-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៧៣(៣៨ឆ្នាំ) ដាក់ពន្ធនាគារកំណត់៣ឆ្នាំ (បីឆ្នាំ) តែទោសនេះត្រូវអនុវត្តទោស ក្នុងពន្ធនាគារ ចំនួន៦ ខែ(ប្រាំមួយខែ) គិតពីថ្ងៃឃុំខ្លួនថ្ងៃទី២០ ខែ ឧសភា

ឆ្នាំ ២០១១ ទោសលើសពីនេះត្រូវព្យួរ តាមបញ្ញត្តិ មាត្រា ១០៦.មាត្រា ១០៧ និងមាត្រា១០៨ នៃក្រមព្រហ្មទណ្ឌ និងពិន័យជាប្រាក់ ចំនួន២ដងនៃប្រាក់សំណូក ស្មើនឹងចំនួន៤០០ដុល្លា (បួនរយដុល្លា) បង់ចូលថវិការដ្ឋ។

ពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀននៅមុខស្ថានីយ៍ប្រេងឥន្ធនៈ*** [redacted] ***:*** កាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១០ នៅភូមិកំពង់ស្វាយ សង្កាត់កំពង់ស្វាយ ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

**២-៥**-ឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៨(៤៣ឆ្នាំ) ដាក់ពន្ធនាគារកំណត់ ៣ឆ្នាំ (បីឆ្នាំ) គិតពីថ្ងៃចាប់ជននេះមកអនុវត្តទោស និងពិន័យជាប្រាក់ ចំនួន២ដងនៃប្រាក់សំណូក ស្មើនឹងចំនួន៦៤.០០០ដុល្លា (ប្រាំមួយម៉ឺនបួនពាន់ដុល្លា) បង់ចូលថវិការដ្ឋ។

ពីបទ **ស៊ីសំណូក** បទល្មើសព្រហ្មទណ្ឌ ដែលមានចែងឱ្យផ្តន្ទាទោស តាមមាត្រា ៣៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ប្រព្រឹត្តនៅ:

***-ករណីបង្ក្រាបគ្រឿងញៀនលើឈ្មោះ*** [redacted] ***ខាងលិចផ្សារអត្ត:*** កាលពីខែសីហា ឆ្នាំ២០០៩ ក្នុងដែនដីខេត្តបន្ទាយមានជ័យ។

***-ករណីបង្ក្រាបគ្រឿងញៀនលើឈ្មោះ*** [redacted] ***:*** កាលពីថ្ងៃទី០៩ ខែសីហា ឆ្នាំ២០០៩ នៅសង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

៣-បង្គាប់ឱ្យធ្វើការចាប់ខ្លួនឈ្មោះ [redacted] ភេទ ប្រុស ឆ្នាំកំណើត ១៩៦៨(៤៣ឆ្នាំ) ដើម្បីយកមកអនុវត្តទោសតាមអំណាចសាលក្រមនេះ។

៤-វត្ថុតាង ថ្នាំញៀន មាននៅក្នុងសំណុំរឿង ដែលច្រកក្នុងស្រោមសំបុត្រសបិតជិតចំនួន៤ ដែលមានស្នាមម្រាមដៃជនល្មើស ឈ្មោះ [redacted] និងមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងថ្នាំញៀនដែលច្រកក្នុងស្រោមសំបុត្រពណ៌ត្នោត ចំនួន២បិតជាប់គ្នា ដែលមានស្នាមម្រាមដៃជនល្មើស ឈ្មោះ [redacted] និងមន្ត្រីនគរបាលយុត្តិធម៌ ត្រូវរឹបអូសហើយបំផ្លាញចោល។

សាលក្រមនេះប្រកាសជាសាធារណៈ នៅសាលាដំបូង ខេត្តបន្ទាយមានជ័យ ថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ ២០១១ សម្រេចសេចក្តី ចំពោះមុខ ជនជាប់ចោទ ឈ្មោះ [redacted] , ឈ្មោះ [redacted] , ឈ្មោះ [redacted] និងឈ្មោះ [redacted] កំបាំងមុខជនជាប់ចោទ ឈ្មោះ [redacted] បើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|
| ហត្ថលេខា [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា [redacted] |

---

| បានឃើញ | បានសម្រង់ចេញត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| បន្ទាយមានជ័យ,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១១ | បន្ទាយមានជ័យ,ថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ២០១១ |
| **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |

# ព្រះរាជក្រម

នស/រកម/០២១៨/០០៣

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើក្រមព្រហ្មទណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១១ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖



ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •
ព្រះរាជវាំង

# ច្បាប់

# ស្ដីពី

# វិសោធនកម្មក្រមព្រហ្មទណ្ឌ

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

**មាត្រាមួយ.-**

ក្រមព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ត្រូវបានធ្វើវិសោធនកម្មដោយបន្ថែម មាត្រា៤៣៧ (ស្ទួន) ដូចខាងក្រោម៖

**មាត្រា៤៣៧.- (ស្ទួន) បទប្រមាថចំពោះអង្គព្រះមហាក្សត្រ**

ការប្រមាថ គឺជាវាចា កាយវិការ សំណេរ គំនូរ ឬវត្ថុដែលប៉ះពាល់ដល់សេចក្ដីថ្លៃថ្នូរនៃបុគ្គល។

ការប្រមាថចំពោះអង្គព្រះមហាក្សត្រ ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យជាប្រាក់ពី ២.០០០.០០០ (ពីរលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល។

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមនេះ ចំពោះបទប្រមាថចំពោះអង្គព្រះមហាក្សត្រ។

នីតិបុគ្គលត្រូវផ្ដន្ទាទោសពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៥០.០០០.០០០ (ហាសិបលាន) រៀល ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ៖

១-ការរំលាយតាមបែបបទកំណត់ដោយមាត្រា១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមនេះ។

២-ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តាមបែបបទកំណត់ដោយមាត្រា១៧១ (ការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) នៃក្រមនេះ។

៣-ការហាមឃាត់ចំពោះការធ្វើសកម្មភាពណាមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមនេះ។

៤-ការបិទគ្រឹះស្ថានដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៦ (ការបិទគ្រឹះស្ថាន) នៃក្រមនេះ។

៥-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុណាមួយដែលប្រើប្រាស់សម្រាប់ប្រព្រឹត្តបទល្មើស ឬដែលមានគោលដៅសម្រាប់ប្រព្រឹត្តបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៦-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៧-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស តាមបែបបទកំណត់ដោយមាត្រា១៧៨ (ការរឹបអូសកម្មសិទ្ធិ ការលក់ ការបំផ្លាញចោលវត្ថុរឹបអូស) និងមាត្រា១៧៩ (ការរឹបអូស និងសិទ្ធិតតិយជន) នៃក្រមនេះ។

៨-ការបិទផ្សាយសេចក្ដីសម្រេចផ្ដន្ទាទោស តាមបែបបទកំណត់ដោយមាត្រា១៨០ (ការបិទផ្សាយសេចក្ដីសម្រេច) នៃក្រមនេះ។

៩-ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរ ឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ជាអាទិ៍) នៃក្រមនេះ ។

**មាត្រាពីរ..**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់។

ថ្ងៃ *អង្គារ ១៣កើត* ខែ *ផល្គុន* ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី *២៧* ខែ *កុម្ភៈ* ឆ្នាំ ២០១៨

**ក្នុងព្រះបរមនាមនិងតាមព្រះរាជបញ្ជាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងព្រះរាជលញ្ឆករ**

**សម្តេចវិបុលសេនាភក្តី សាយ ឈុំ**

*ពរម.០២០២.២៣២*

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**ហត្ថលេខា**

**អង្គ វង្ស វឌ្ឍនា**

លេខៈ២៥៧ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

ថ្ងៃពុធ ទី១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក.ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៨

**ឧ.អគ្គលេខាធិការរាជរដ្ឋាភិបាល**

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ជាង អេងធួន**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងយុត្តិធម៌**

លេខ :..០៣ កយធ.សរ/១៤

# សារាចរ
# ស្តីពី
# ការអនុវត្តបទប្បញ្ញត្តិនៃ ការអនុវត្តទោសការងារសហគមន៍

ក្រសួងយុត្តិធមិបានកត់សម្គាល់ឃើញថា បទប្បញ្ញត្តិ និងគោលការណ៍ស្តីពីការអនុវត្តទោសការងារសហគមន៍ ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌចាប់ពីមាត្រា ៧២ ដល់ មាត្រា ៧៥ មាត្រា ៩៨ មាត្រា ១០១ ដល់ ១០៣ និងមាត្រា ១៦២ មិនទាន់អនុវត្តបានគ្រប់ជ្រុងជ្រោយនៅឡើយ ដែលជាហេតុធ្វើឲ្យការអនុវត្តទោសការងារសហគមន៍ មិនទាន់មានប្រសិទ្ធិភាព និងមិនទាន់មានភាពរលូន។

ដើម្បីធានាការអនុវត្តបទប្បញ្ញត្តិ និងគោលការណ៍ទាំងនេះឲ្យមានប្រសិទ្ធភាព ក្រសួងយុត្តិធមិសូមធ្វើការណែនាំដូចខាងក្រោម ៖

**ក-ចៅក្រមជំនុំជម្រះ**

១-គប្បីធានាឲ្យបាននូវការអនុវត្តតាមបទប្បញ្ញត្តិ និងគោលការណ៍ដែលមានចែងក្នុងក្រមព្រហ្មទណ្ឌស្តីពីទោសការងារសហគមន៍ ចំពោះទណ្ឌិតណាដែលតុលាការប្រកាសទោសដាក់ពន្ធនាគារតិចជាង ឬស្មើ ៣ (បី) ឆ្នាំ ។

២-តុលាការត្រូវប្រគល់សម្រង់សាលក្រម ជូនព្រះរាជអាជ្ញាមួយច្បាប់ និងប្រគល់ឲ្យទៅទណ្ឌិតមួយច្បាប់។

**ខ-ព្រះរាជអាជ្ញា**

១-ត្រូវសហការជាមួយអង្គការរដ្ឋ សមាគមន៍ ឬអង្គការមិនមែនរដ្ឋាភិបាល ដើម្បីកសាង និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះនីតិបុគ្គល និងប្រភេទការងារ ដែលមានតម្រូវការផ្តល់ការងារឲ្យទណ្ឌិតធ្វើ។ បញ្ជីនេះត្រូវដាក់បង្ហាញជូនតុលាការដើម្បីជ្រើសរើសការងារ ឲ្យទណ្ឌិតដែលយល់ព្រមទទួលយក។

២-ការផ្តល់ការងារសហគមន៍ដល់អនីតិជន ត្រូវពិភាក្សាបន្ថែមជាមួយមន្ត្រីសង្គមកិច្ចអំពីការងារដែលមានលក្ខណៈជាការងារបណ្តុះបណ្តាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ។

មហាវិថីសម្តេចសុធារស.ខ័ណ្ឌដូនពេញ.រាជធានីភ្នំពេញ ទូរស័ព្ទ : 023 216 322 , 023 217 841

៣-ត្រូវរៀបចំបែបបទនៃការអនុវត្តទោសការងារសហគមន៍ សម្រាប់នីតិបុគ្គលដែលទទួលទណ្ឌិតឲ្យធ្វើការងារ ដោយឲ្យនីតិបុគ្គលនោះ បំពេញនូវកាតព្វកិច្ចដូចតទៅ ៖

-ណែនាំដល់ទណ្ឌិតអំពីការបំពេញកាតព្វកិច្ច និងអប់រំទណ្ឌិតឲ្យយកចិត្តទុកដាក់ក្នុងការកសាងខ្លួនចូលក្នុងសង្គមវិញ

-គ្រប់គ្រងតាមដានសកម្មភាពរបស់ទណ្ឌិត ក្នុងពេលបំពេញកាតព្វកិច្ច

-ធ្វើរបាយការណ៍អំពីសកម្មភាពរបស់ទណ្ឌិតជូនដល់ព្រះរាជអាជ្ញា

-ត្រូវចុះហត្ថលេខាលើកំណត់ហេតុទទួលស្គាល់ អំពីការអនុវត្តការងាររបស់ទណ្ឌិត

៤-ត្រូវយកចិត្តទុកដាក់តាមដានត្រួតពិនិត្យការអនុវត្តការងាររបស់ទណ្ឌិតដែលមានដូចខាងក្រោម ៖

-គ្រប់គ្រង តាមដាន រក្សាទុករបាយការណ៍ កំណត់ហេតុអំពីការអនុវត្តការងារសហគមន៍

-តាមដានការអនុវត្តរបស់ទណ្ឌិតទៅតាមលក្ខខណ្ឌរបស់សាលក្រម

-ណែនាំទណ្ឌិតអំពីការអនុវត្តការងារសហគមន៍ និងកាតព្វកិច្ចដែលត្រូវអនុវត្ត

-ណែនាំដល់នីតិបុគ្គលដែលទទួលទណ្ឌិត អំពីបែបបទអនុវត្តការងារគ្រប់គ្រង

-ចេញដីកាសម្រេចបញ្ចប់ការអនុវត្តទោសរបស់ទណ្ឌិត ដែលបានអនុវត្តទោសការងារសហគមន៍ដោយជោគជ័យ។

សូមលោក លោកស្រី ជាចៅក្រម ព្រះរាជអាជ្ញា គ្រប់ស្ថាប័នតុលាការ និងអយ្យការ ត្រូវអនុវត្តសារាចរនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី..២២...ខែ..មករា.. ឆ្នាំ..២០១៤.

**រដ្ឋមន្ត្រី**

អង្គ វង្សវឌ្ឍនា

<u>ចម្លងជូន</u> ៖

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី

ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី

-តុលាការ និងមហាអយ្យការអមតុលាការកំពូល

-សាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍

-សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី-ខេត្ត

-ឯកសារ-កាលប្បវត្តិ